ក្រសួងអប់រំ យុវជន និងកីឡា

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

# អក្ខរកម្មហិរញ្ញវត្ថុ

## មធ្យមសិក្សា




### សម្រាប់គ្រូបង្រៀន

WOORI BANK ChildFund Korea ChildFund Cambodia Teach For Cambodia

# អក្សរកម្មហិរញ្ញវត្ថុ

## មធ្យមសិក្សា

សម្រាប់គ្រូបង្រៀន

ឆ្នាំ២០២៤

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងអប់រំ យុវជន និងកីឡា**
លេខ: ១៩៣៨ អយក.ប្រក

# ប្រកាស
## ស្ដីពី
## ការអនុញ្ញាតឱ្យបោះពុម្ពផ្សាយ
## សៀវភៅអក្ខរកម្មហិរញ្ញវត្ថុ មធ្យមសិក្សា សម្រាប់គ្រូបង្រៀន

## ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

- បានឃើញ រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រឹត្យ លេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្ដីពី ការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រម លេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃ២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពី ការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញ ព្រះរាជក្រម លេខ នស/រកម/០១៩៦/០១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពី ការបង្កើតក្រសួងអប់រំ យុវជន និងកីឡា
- បានឃើញ ព្រះរាជក្រម លេខ នស/រកម/១២០៧/០៣២ ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពី ការអប់រំ
- បានឃើញ អនុក្រឹត្យ លេខ ២០ អនក្រ.បក ចុះថ្ងៃទី៣០ ខែមេសា ឆ្នាំ១៩៩៦ ស្ដីពី ការរៀបចំ និងការប្រព្រឹត្តទៅ នៃក្រសួង និងរដ្ឋលេខាធិការដ្ឋាន
- បានឃើញ អនុក្រឹត្យ លេខ ១០១ អនក្រ.បក ចុះថ្ងៃទី២៩ ខែមេសា ឆ្នាំ២០២៤ ស្ដីពី ការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងអប់រំ យុវជន និងកីឡា
- យោងសេចក្ដីសម្រេចលេខ ១១ អយក.សសរ. ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០១៦ របស់ក្រសួងអប់រំ យុវជន និងកីឡា ស្ដីពីប្រព័ន្ធអនុម័តសៀវភៅសិក្សា និងសម្ភារឧបទេស
- យោងលិខិតលេខ ១១៨៩-២៤ ចុះថ្ងៃព្រហស្បតិ៍ ៧កើត ខែកត្ដិក ឆ្នាំរោង ឆស័ក ព.ស.២៥៦៨ ត្រូវនឹងថ្ងៃទី៧ ខែវិច្ឆិកា ឆ្នាំ២០២៤ របស់អង្គការឆោលហ្វានកម្ពុជា
- យោងលិខិតលេខ ៣៦៦ អគ.អរ ចុះថ្ងៃអង្គារ ១២កើត ខែកត្ដិក ឆ្នាំរោង ឆស័ក ព.ស.២៥៦៨ ត្រូវនឹងថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ២០២៤ របស់អគ្គនាយកដ្ឋានអប់រំ

អាសយដ្ឋានលេខ៨០ មហាវិថី ព្រះនរោត្តម ភ្នំពេញ កម្ពុជា ទូរស័ព្ទ: (៨៥៥-២៣) ២២០ ៦៧៣ / ២២០ ៣០៤ ទូរសារ: (៨៥៥-២៣) ២១៧ ២៥០ / ២១២ ៥១២
អ៊ីមែល: info@moeys.gov.kh / administration@moeys.gov.kh គេហទំព័រ: www.moeys.gov.kh

## សម្រេច

**ប្រការ១.**_ អនុញ្ញាតឱ្យបោះពុម្ពផ្សាយសៀវភៅ **«អក្ខរកម្មហិរញ្ញវត្ថុ មធ្យមសិក្សា សម្រាប់គ្រូបង្រៀន»** ដែលរៀបចំឡើងដោយក្រសួងអប់រំ យុវជន និងកីឡា ក្រោមកិច្ចសហការពីអង្គការឆាលហ្វានកម្ពុជា អង្គការឆាលហ្វានកូរ៉េ និងអង្គការបង្រៀនដើម្បីកម្ពុជា តាមរយៈជំនួយឧបត្ថម្ភពីមូលនិធិធនាគារអ៊ូរី(ខេមបូឌា) ដើម្បីប្រើប្រាស់ជាឯកសារជំនួយការបង្រៀននិងរៀន កម្រិតមធ្យមសិក្សា នៅតាមសាលារៀនមធ្យមសិក្សាចំណេះទូទៅ ទូទាំងព្រះរាជាណាចក្រកម្ពុជា។

**ប្រការ២.**_ អគ្គលេខាធិការដ្ឋាន អគ្គនាយកដ្ឋានអប់រំ នាយកដ្ឋានមធ្យមសិក្សាចំណេះទូទៅ នាយកដ្ឋានអប់រំក្រៅប្រព័ន្ធនិងបរិយាបន្ន នាយកដ្ឋានបរិវត្តកម្មឌីជីថល នាយកដ្ឋានអភិវឌ្ឍកម្មវិធីសិក្សា មន្ទីរអប់រំ យុវជន និង កីឡារាជធានី ខេត្ត ការិយាល័យអប់រំ យុវជន និងកីឡានៃរដ្ឋបាលក្រុង ស្រុក ខណ្ឌ សាលារៀនមធ្យមសិក្សាចំណេះទូទៅ និងអង្គការឆាលហ្វានកម្ពុជា មានភារកិច្ចអនុវត្តប្រកាសនេះ។

ថ្ងៃ សុក្រ ៦រោច ខែកត្តិក ឆ្នាំរោង ឆស័ក ព.ស.២៥៦៨
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ២០២៤

**កន្លែងទទួល៖**
- គ្រប់រដ្ឋបាលរាជធានី ខេត្ត
- អគ្គលេខាធិការដ្ឋាន
- គ្រប់អគ្គនាយកដ្ឋាន និងអគ្គាធិការដ្ឋាន
- ខុទ្ទកាល័យឯកឧត្តមបណ្ឌិតសភាចារ្យឧបនាយករដ្ឋមន្ត្រី «ដើម្បីជ្រាបជាព័ត៌មាន»
- ដូចប្រការ២ «ដើម្បីអនុវត្ត»
- កាលប្បវត្តិ
- ឯកសារ នាយកដ្ឋានអភិវឌ្ឍកម្មវិធីសិក្សា

**បណ្ឌិតសភាចារ្យ ហង់ជួន ណារ៉ុន**

# អារម្ភកថា

ការសិក្សាស្រាវជ្រាវស្តីពីអក្ខរកម្មហិរញ្ញវត្ថុនៅក្នុងប្រទេសកម្ពុជាបានបង្ហាញថា មនុស្សភាគច្រើនមិនទាន់មានចំណេះដឹងផ្នែកហិរញ្ញវត្ថុទូលំទូលាយនៅឡើយ ដោយសារអក្ខរកម្មហិរញ្ញវត្ថុមាននិយមន័យផ្សេងៗគ្នាច្រើន ប៉ុន្តែគោលគំនិតរួមគឺមានលក្ខណៈចម្រុះ ដែលឆ្លុះបញ្ចាំងមិនត្រឹមតែចំណេះដឹងប៉ុណ្ណោះទេ ថែមទាំងឆ្លុះបញ្ចាំងនូវជំនាញជាក់ស្តែង អាកប្បកិរិយា និងឥរិយាបថជាក់ស្តែងផងដែរ។ ដូច្នេះអក្ខរកម្មហិរញ្ញវត្ថុមានគោលបំណងអភិវឌ្ឍចំណេះដឹងនិងជំនាញហិរញ្ញវត្ថុ ដែលអាចឱ្យសិស្សប្រើប្រាស់ធនធានបានឱ្យល្អប្រសើរបំផុត។

ឯកសារណែនាំនេះ អភិវឌ្ឍឡើងដើម្បីណែនាំសិស្សានុសិស្សបានត្រៀមខ្លួនរួចជាស្រេចក្នុងការប្រឈមមុខនឹងបញ្ហាហិរញ្ញវត្ថុនាពេលអនាគតដែលពួកគេអាចនឹងជួបប្រ ព្រមទាំងទទួលបានជំនាញក្នុងការគ្រប់គ្រងប្រាក់ ការសម្រេចចិត្ត ការគ្រប់គ្រងខ្លួនឯង និងទំនួលខុសត្រូវសង្គម រួមទាំងរៀនពីរបៀបរៀបចំថវិកា សន្សំ ចំណាយ និងបរិច្ចាគ ដែលអាចឱ្យសិស្សមានភាពវិជ្ជមានលើទម្លាប់ហិរញ្ញវត្ថុ និងបង្កើនសុខុមាលភាព។ ឯកសារនេះរួមមាន សម្ភារៈសម្រាប់សិស្សដូចជាសន្លឹកកិច្ចការ ផ្ទាំងរូបភាព ព្រមទាំងគន្លឹះសំខាន់ៗនិងចំណេះដឹងផ្សេងៗសម្រាប់គ្រូ ដែលជាជំនួយក្នុងការបង្រៀនដោយប្រើវិធីសាស្ត្របង្រៀនដ៏មានប្រសិទ្ធភាពក្នុងពេលបង្រៀនក្នុងថ្នាក់។

មេរៀននីមួយៗត្រូវបានបែងចែកជាផ្នែកផ្សេងៗ។ ផ្នែកទីមួយគឺ ជាសេចក្តីផ្តើមដែលយើងព្យាយាមផ្សារភ្ជាប់ទៅកាន់ចំណេះដឹងដែលមានស្រាប់ ឬរំឭកមេរៀនមុន។ នៅក្នុងផ្នែកទី២ បង្រៀនពីសកម្មភាពសំខាន់ដោយផ្អែកលើវិធីសាស្ត្របង្រៀនបែបគម្រោង និងយុទ្ធសាស្ត្របង្រៀនផ្សេងៗ និងផ្នែកចុងក្រោយ គឺត្រូវធានានូវលទ្ធផលសិក្សារបស់តាមរយៈយុទ្ធសាស្ត្រផ្សេងៗគ្នា។

យើងខ្ញុំសង្ឃឹមថា ឯកសារនេះ នឹងចូលរួមចំណែកអភិវឌ្ឍចំណេះដឹងអំពីអក្ខរកម្មហិរញ្ញវត្ថុដល់សិស្សានុសិស្សឱ្យបំណិនច្បាស់លាស់ក្នុងការគ្រប់គ្រងប្រាក់កាន់តែប្រសើរ។ ទោះជាយ៉ាងណាក៏ដោយ យើងខ្ញុំនៅតែរង់ចាំទទួលនូវទទួលនូវមតិកែលម្អនិងស្វាគមន៍ពីសំណាក់លោកគ្រូ អ្នកគ្រូ អ្នកសិក្សា អ្នកអាន និងអ្នកចាប់អារម្មណ៍នានា ដើម្បីធ្វើឱ្យឯកសារនេះកាន់តែសុក្រឹត៕

**គណៈកម្មការនិពន្ធ**

## គណៈកម្មការគ្រប់គ្រង

ឯកឧត្តម បណ្ឌិតសភាចារ្យ ឧបនាយករដ្ឋមន្ត្រី **ហង់ជួន ណារ៉ុន**

ឯកឧត្តម **អ៊ុំ ឈិនណា** អគ្គនាយកនៃអគ្គនាយកដ្ឋានអប់រំ

លោក **សុភ ថា** ប្រធាននាយកដ្ឋានបច្ចេកវិទ្យាព័ត៌មាន

លោក **ស៊ុន ម៉ុណ្ណា** ប្រធាននាយកដ្ឋានអភិវឌ្ឍកម្មវិធីសិក្សា

លោក **លឹម ចណ្ណា** ប្រធាននាយកដ្ឋានសំណង់

លោក **អ៊ិត ជេដ្ឋា** អនុប្រធាននាយកដ្ឋានមធ្យមសិក្សាចំណេះទូទៅ

លោកស្រី **អ៊ុក ណារិន** មន្ត្រីគ្រប់គ្រងកម្មវិធីនៃអង្គការឆាលហ្វានកម្ពុជា

លោក **ស៊ីវ មុនីរ័ត្ន** នាយកប្រតិបត្តិនិងជាតំណាងដៃគូអភិវឌ្ឍន៍

## គណៈកម្មការនិពន្ធ

កញ្ញា **សេង ស៊ីណែត**

លោកស្រី **អឿន ចំរុង**

លោក **អ៊ិន ដាវី**

លោក **ស៊ីន ដារ៉ា**

លោក **លឹម សុត្ថារិទ្ធ**

លោកស្រី **អ៊ិត ចណ្ណា**

កញ្ញា **ឈឿង ថាលីណា**

## ជំនួយការបច្ចេកទេស

Ms. Namhee Yoon, ChildFund Korea

Ms. HEM Mary, External Consultant

Ms. Pauline, External Consultant

លោក **នៅ សំណាង** អង្គការឆាលហ្វាន កម្ពុជា

# មាតិកា

ទំព័រ


១- សេចក្តីផ្តើម ..... 5
២- គោលបំណងនៃឯកសារណែនាំ ..... 6
៣- ការពន្យល់អំពីរបៀបប្រើប្រាស់ឯកសារណែនាំ ..... 6
៥- ការវាយតម្លៃ ..... 9

**ជំពូកទី១ ស្វាគមន៍មកកាន់អក្ខរកម្មហិរញ្ញវត្ថុ** ..... 10
មេរៀនទី១ ការគោរពគ្នាទៅវិញទៅមក ..... 10
មេរៀនទី២ ចាប់ផ្តើមដំណើរមេរៀនស្តីពីអក្ខរកម្មហិរញ្ញវត្ថុ ..... 16

**ជំពូកទី២ ការសន្សំទុកសម្រាប់ថ្ងៃស្អែក** ..... 22
មេរៀនទី១ ចូរយើងឈ្វេងយល់ពីប្រវត្តិប្រាក់នៅក្នុងពិភពលោក ..... 22
មេរៀនទី២ ទម្លាប់សន្សំ ..... 34
មេរៀនទី៣ ប្រព័ន្ធធនាគារ ..... 40
មេរៀនទី៤ ការសម្រេចចិត្តក្នុងការសន្សំ ..... 56

**ជំពូកទី៣ សិទ្ធិក្នុងការរកប្រាក់** ..... 68
មេរៀនទី១ ពិភពការងាររបស់កុមារ ..... 68
មេរៀនទី២ ជម្រើសក្នុងការរកប្រាក់ ..... 74

**ជំពូកទី៤ តើខ្ញុំចំណាយប្រាក់ដោយឆ្លាតវៃដែរឬទេ?** ..... 78
មេរៀនទី១ ជម្រើសក្នុងការចំណាយ ..... 78

**ជំពូកទី៥ ការផ្តល់ត្រឡប់មកកាន់សហគមន៍វិញ** ..... 87
មេរៀនទី១ តម្រូវការរបស់សហគមន៍អ្នក ..... 87
មេរៀនទី២ ការបង្កើតគម្រោងតូចមួយសម្រាប់សហគមន៍យើង ..... 91

**ជំពូកទី៦ ការបញ្ចប់មេរៀនអក្ខរកម្មហិរញ្ញវត្ថុ** ..... 98
មេរៀនទី១ ការបញ្ចប់ដំណើរការមេរៀនស្តីពីអក្ខរកម្មហិរញ្ញវត្ថុ ..... 98

**ទម្រង់វាយតម្លៃឥរិយាបថសិស្ស** ..... 100
**តារាងពិន្ទុវាយតម្លៃឥរិយាបថសិស្ស** ..... 101
**ការសង្កេតថ្នាក់រៀន - ស្វ័យវាយតម្លៃគ្រូបង្រៀន** ..... 102

# ១- សេចក្តីផ្តើម

ចំណេះដឹងផ្នែកហិរញ្ញវត្ថុ គឺជាជំនាញមួយដ៏សំខាន់សម្រាប់មនុស្សគ្រប់រូបដែលត្រូវទទួលបាន។ ការពិតវាផ្តល់ចំណេះដឹងផ្នែកហិរញ្ញវត្ថុដល់មនុស្ស ដើម្បីធ្វើការសម្រេចចិត្តបានត្រឹមត្រូវ និងជៀសវាងកំហុសឆ្គងផ្នែកហិរញ្ញវត្ថុ។ វាជួយឱ្យយើងចេះរៀបចំថវិកាសម្រាប់គ្រាមានអាសន្ន សម្រេចបានស្ថិរភាពថវិកា ធ្វើឱ្យប្រសើរឡើងនូវគុណភាពជីវិត សម្រេចបានគោលដៅ និងបង្កើនទំនុកចិត្ត។

Standard & Poor's Ratings Services បានសិក្សាស្រាវជ្រាវជាសកលក្នុងឆ្នាំ២០១៥ ដើម្បីស្ទង់ចំណេះដឹងអំពីមូលដ្ឋានចំនួនបួននៃទស្សនៈហិរញ្ញវត្ថុ៖ ហានិភ័យផ្សេងៗ អតិផរណា អក្ខរកម្មលេខ និងការប្រាក់ បានបង្ហាញថា មនុស្សពេញវ័យមួយភាគបីនៅលើពិភពលោកមានចំណេះដឹងផ្នែកហិរញ្ញវត្ថុ។ លើសពីនេះ វាបានបង្ហាញពីការប្រែប្រួលសំខាន់ៗរវាងប្រទេស និងក្រុមមនុស្សផ្សេងគ្នា។ ស្ត្រីដែលមានជីវភាពក្រីក្រនិងការអប់រំទាបទំនងជាទទួលរងពីគម្លាតនៃចំណេះដឹងផ្នែកហិរញ្ញវត្ថុ មិនថានៅក្នុងប្រទេសដែលបានអភិវឌ្ឍ ឬកំពុងអភិវឌ្ឍ។ ទន្ទឹមនឹងនេះ ការសិក្សាបានគូសបញ្ជាក់ពីភាពស្រដៀងគ្នារវាងមនុស្សដែលមានចំណេះដឹងខ្ពស់ផ្នែកហិរញ្ញវត្ថុ។ អ្នកដែលប្រើប្រាស់សេវាកម្មហិរញ្ញវត្ថុដូចជា គណនីធនាគារឬបណ្ណឥណទាន ទំនងជាមានចំណេះដឹងផ្នែកហិរញ្ញវត្ថុខ្ពស់ដោយមិនគិតពីប្រាក់ចំណូលរបស់ពួកគេ។

ការសិក្សានេះបានបង្ហាញថា "ទំនាក់ទំនងរវាងចំណេះដឹងហិរញ្ញវត្ថុនិងសេវាកម្មហិរញ្ញវត្ថុ អាចដំណើរការក្នុងទិសដៅពីរ គឺនៅពេលមានចំណេះដឹងផ្នែកហិរញ្ញវត្ថុខ្ពស់អាចនាំឱ្យមានបរិយាបន្នហិរញ្ញវត្ថុ និងមានប្រតិបត្តិការគណនីឬការប្រើប្រាស់ឥណទាន ដែលអាចឱ្យអ្នកប្រើប្រាស់មានជំនាញហិរញ្ញវត្ថុកកាន់តែស៊ីជម្រៅ។[1] ការវិភាគស្ថានភាពចំណេះដឹងហិរញ្ញវត្ថុបានគូសបញ្ជាក់ថា ១៨%នៃមនុស្សពេញវ័យនៅកម្ពុជាមានចំណេះដឹងផ្នែកហិរញ្ញវត្ថុ។

បន្ថែមលើការវិភាគនេះ ការសិក្សាអំពីចំណេះដឹងផ្នែកហិរញ្ញវត្ថុដែលធ្វើឡើងដោយធនាគារអភិវឌ្ឍន៍អាស៊ីបានបង្ហាញថា ប្រជាជនកម្ពុជាភាគច្រើនមានអត្រាទាបនៃចំណេះដឹងផ្នែកហិរញ្ញវត្ថុ[2] បើទោះជាវាត្រូវបានទទួលស្គាល់ថាមានសារៈសំខាន់ក៏ដោយ។ ការសិក្សាមួយផ្សេងទៀតដែលធ្វើឡើងដោយក្រុមហ៊ុនព្រូដិនសលនៅទូទាំងអាស៊ីបានបង្ហាញថា ទោះបីជាឪពុកម្តាយ៩៦%ទទួលស្គាល់ពីសារៈសំខាន់នៃការរៀនជំនាញជំនាញគ្រប់គ្រងប្រាក់ក៏ដោយ ប៉ុន្តែមានឪពុកម្តាយតែ១៣%ប៉ុណ្ណោះដែលជឿថា កូនរបស់ពួកគេមានជំនាញគ្រប់គ្រងប្រាក់។ ការវាយតម្លៃទូទៅមួយ[3] ធ្វើឡើងដោយ KAPE ក្នុងខែធ្នូ ឆ្នាំ២០២២បានបង្ហាញថា ក្នុងចំណោមសាលាដែលបានស្ទង់មតិមួយចំនួនធំ(42%)[4] បានរាយការណ៍ពីការបង្រៀនវគ្គចំណេះដឹងផ្នែកហិរញ្ញវត្ថុដែលជាផ្នែកមួយនៃកម្មវិធីបំណិនជីវិតរបស់ពួកគេ ទោះបីជាទាន់មិនច្បាស់ថា វាស្ថិតក្នុងកម្រិតណានៃចំណេះដឹងហិរញ្ញវត្ថុក៏ដោយ។

សរុបមក ការស្ទង់មតិទាំងនេះបានបង្ហាញពីសារៈសំខាន់នៃការរៀនអំពីអក្ខរកម្មហិរញ្ញវត្ថុ រួមទាំងនៅក្នុងប្រទេសកម្ពុជាផងដែរ ដើម្បីលើកកម្ពស់ជំនាញហិរញ្ញវត្ថុសម្រាប់កុមារនិងយុវជន។ អក្ខរកម្មហិរញ្ញវត្ថុ មាននិយមន័យផ្សេងៗគ្នា ប៉ុន្តែបញ្ញត្តិរួមគឺមានលក្ខណៈចម្រុះដែលមិនត្រឹមតែឆ្លុះបញ្ចាំងពីចំណេះដឹងប៉ុណ្ណោះទេ ថែមទាំងជំនាញឥរិយាបថ និងអាកប្បកិរិយាជាក់ស្តែងផងដែរ។ ដូច្នេះអក្ខរកម្មហិរញ្ញវត្ថុមានគោលបំណងអភិវឌ្ឍចំណេះដឹង និងជំនាញហិរញ្ញវត្ថុដែលជួយឱ្យសិស្សអាចប្រើប្រាស់ធនធានឱ្យបានល្អបំផុត ។

---

[1] ចំណេះដឹងផ្នែកហិរញ្ញវត្ថុជុំវិញពិភពលោក៖ ការយល់ដឹងពីការស្ទង់មតិ S&P Global Finlit ឆ្នាំ២០១៥

[2] ការសិក្សារបស់វិទ្យាស្ថានធនាគារអភិវឌ្ឍន៍អាស៊ី និងធនាគារជាតិនៃកម្ពុជា បានរកឃើញក្នុងឆ្នាំ២០១៧ថា ពិន្ទុសរុបនៃចំណេះដឹងផ្នែកហិរញ្ញវត្ថុនៅកម្ពុជា (11.5 ពិន្ទុក្នុងចំណោម 21) គឺនៅកម្រិតទាបនៃជួរដែលឃើញនៅក្នុងគំរូនៃប្រទេសចំនួន៣០ ដែលបានអនុវត្តទម្រង់ស្ទង់មតិស្តង់ដារដែលត្រូវបានបង្កើត ឡើងដោយ OECD/INFE ។

[3] អក្ខរកម្មហិរញ្ញវត្ថុចំពោះកុមារ ព្រូដិនសល ឆ្នាំ ២០១១

[4] ការវាយតម្លៃទូទៅនៃចំណេះដឹងផ្នែកឌីជីថល និងហិរញ្ញវត្ថុ ដែលបង្កើតឡើងដោយ KAPE សម្រាប់មូលនិធិកុមារកម្ពុជាក្នុងខែធ្នូ ឆ្នាំ២០២២។

## ២- គោលបំណងនៃឯកសារណែនាំ

ឯកសារណែនាំនេះមានគោលបំណងបង្រៀនសិស្សអំពីសារៈសំខាន់នៃអក្ខរកម្មហិរញ្ញវត្ថុនិងប្រាក់ ដើម្បីត្រៀមខ្លួនរួចរាល់ប្រឈមមុខនឹងបញ្ហាហិរញ្ញវត្ថុនាពេលអនាគតដែលពួកគេអាចជួបប្រទះ។

តាមរយៈកម្មវិធីសិក្សានេះ សិស្សនឹងទទួលបានជំនាញក្នុងការគ្រប់គ្រងប្រាក់ ការសម្រេចចិត្ត ការគ្រប់គ្រងខ្លួនឯង និងទំនួលខុសត្រូវសង្គម ព្រមទាំងរៀនពីរបៀបរៀបចំថវិកា សន្សំ ចំណាយ និងបរិច្ចាគ ដែលអាចឱ្យពួកគេមានភាពវិជ្ជមានលើទម្លាប់ហិរញ្ញវត្ថុ និងបង្កើនសុខមាលភាពរបស់ពួកគេ។

ឯកសារណែនាំនេះរៀបចំឡើងសម្រាប់គ្រូបង្រៀនប្រើប្រាស់ តាមការពន្យល់នៅក្នុងផ្នែកខាងក្រោម។ ទោះជាយ៉ាងណាក៏ដោយ ឯកសារនេះក៏រួមបញ្ចូលផងដែរនូវសម្ភារៈសម្រាប់សិស្សដែលយើងហៅថា ឯកសារចែក ឬសន្លឹកកិច្ចការ។ បន្ថែមលើនេះ វាផ្តល់ឱ្យគ្រូនូវគន្លឹះ និងចំណេះដឹងសំខាន់ៗដើម្បីជួយពួកគាត់ក្នុងការជ្រើសរើសវិធីសាស្ត្របង្រៀនដ៏ល្អបំផុតសម្រាប់បង្រៀនក្នុងថ្នាក់របស់ពួកគាត់។

## ៣- ការពន្យល់អំពីរបៀបប្រើប្រាស់ឯកសារណែនាំ

នៅក្នុងឯកសារណែនាំនេះ មេរៀននីមួយៗត្រូវបានបែងចែកជាផ្នែកផ្សេងៗគ្នា។ ផ្នែកនីមួយៗមានគោលបំណងខុសៗគ្នា។

| | |
|---|---|
|  | **រយៈពេល៖** និមិត្តសញ្ញានេះបង្ហាញពីពេលវេលាដែលត្រូវការដើម្បីបង្រៀនមេរៀនទាំងមូល។ |
|  | **ការត្រៀមមុនបង្រៀន៖** ផ្នែកនេះប្រាប់ព័ត៌មានអំពីរបៀបរៀបចំថ្នាក់របស់អ្នក ឬទីតាំងផ្សេងទៀតដែលត្រូវប្រើសម្រាប់សកម្មភាពសិក្សា។ វាក៏ផ្តល់ការណែនាំអំពីរបៀបរៀបចំសម្ភារៈចាំបាច់សម្រាប់សកម្មភាពផងដែរ។ |
|  | **សម្ភារៈដែលចាំបាច់៖** ផ្នែកនេះបង្ហាញទិដ្ឋភាពទូទៅនៃសម្ភារៈដែលចាំបាច់។ ភាគច្រើនជារបស់របរសាមញ្ញៗដូចជា ប៊ិក ឬក្រដាស។ សម្ភារៈផ្សេងទៀតនៅក្នុងមេរៀននឹងត្រូវបានផ្តល់ជូនតាមរយៈឯកសារដែលភ្ជាប់មកជាមួយ។ ពេលខ្លះលោកគ្រូ អ្នកគ្រូត្រូវថតចម្លងឯកសារទាំងនោះ។ |
|  | **លទ្ធផលសិក្សា៖** បង្ហាញនូវល្បះស្តីពីអ្វីដែលនឹងអាចសម្រេចបាន និងត្រូវវាយតម្លៃនៅចុងបញ្ចប់នៃមេរៀន។ |

### ✦ ជំហាន និងដំណើរការ

នេះជាមេរៀនជាក់ស្តែង។ ផ្នែកនេះមានព័ត៌មានលម្អិតអំពីវិធីសាស្ត្ររបស់គ្រូ រួមបញ្ចូលទាំងសកម្មភាពដែលអាចធ្វើបានសំណួរជំរុញ ឧទាហរណ៍ដើម្បីបញ្ជាក់លំហាត់ឱ្យច្បាស់ និងកិច្ចការបន្ថែមជាជម្រើស។

មេរៀននីមួយៗត្រូវបានបែងចែកជាផ្នែកផ្សេងៗ។ ផ្នែកទីមួយ គឺជាសេចក្តីផ្តើម ដែលផ្សាភ្ជាប់ទៅនឹងចំណេះដឹងដែលមានស្រាប់ឬរំឭកមេរៀនមុន។ នៅផ្នែកទីពីរ បង្រៀនសកម្មភាពសំខាន់ដោយផ្អែកលើវិធីសាស្ត្រ

បង្រៀនបែបគម្រោង និងវិធីបង្រៀនផ្សេងៗ។ សកម្មភាពសំខាន់មួយឬច្រើនគឺ អាស្រ័យលើមេរៀននីមួយៗ។ ក្នុងផ្នែកចុងក្រោយ គឺជានានូវលទ្ធផលសិក្សារបស់សិស្សតាមរយៈវិធីផ្សេងៗគ្នា។

### ✦ ប្រអប់ចំណេះដឹងគន្លឹះ ឬព័ត៌មានជំនួយ

ព័ត៌មានជំនួយ ឬព័ត៌មានសំខាន់ៗទាក់ទងនឹងប្រធានបទត្រូវបានផ្តល់ឱ្យនៅក្នុងផ្នែកនេះ។ នេះអាចសំដៅទៅលើធនធានបន្ថែមពាក់ព័ន្ធនឹងប្រធានបទ។

### ✦ ឯកសារចែក ឬសន្លឹកកិច្ចការ

បន្ទាប់ពីមេរៀននីមួយៗ មានឯកសារចែកសម្រាប់សិស្ស។ ភាគច្រើនត្រូវថតចម្លង និងកាត់ឯកសារទាំងនោះ ហើយនៅពេលខ្លះអ្នកគ្រាន់តែបង្ហាញដល់សិស្ស។ មិនមែនគ្រប់មេរៀនទាំងអស់សុទ្ធតែមានឯកសារចែកនោះទេ ប៉ុន្តែនៅផ្នែកខាងលើនៃឯកសារចែកនីមួយៗគឺជាចំណងជើងនៃមេរៀនដែលត្រូវគ្នា។

## ៤- ទិដ្ឋភាពទូទៅនៃមេរៀននៅក្នុងឯកសារណែនាំនេះ

| ជំពូក | ប្រធានបទ/មេរៀន | វត្ថុបំណងសិក្សា( សិស្សអាច... ) | រយៈពេល |
|---|---|---|---|
| **ជំពូកទី១៖** សូមស្វាគមន៍មកកាន់អក្ខរកម្មហិរញ្ញវត្ថុ | ១- ការគោរពគ្នាទៅវិញទៅមក | - ពណ៌នាអំពីខ្លួនឯងដោយវិជ្ជមាន និងអំពីឥទ្ធិពលនៃអត្តសញ្ញាណរបស់ខ្លួន។<br>- បង្កើតវិន័យក្នុងថ្នាក់រៀនដើម្បីឱ្យមានបរិយាកាស បរិយាបន្នជាមួយមិត្តភក្តិ និងគ្រូបង្រៀន។<br>- គោរពភាពចម្រុះនៃអត្តសញ្ញាណរបស់អ្នកដទៃ។ | ៤៥នាទី |
| | ២- ចាប់ផ្តើមដំណើររបស់អ្នកក្នុងមេរៀនស្តីពីអក្ខរកម្មហិរញ្ញវត្ថុ | - សរសេរពីគំនិត និងអារម្មណ៍នៅពេលចាប់ផ្តើមឆ្នាំសិក្សាថ្មី។<br>- បង្ហាញគំនិតនិងអារម្មណ៍ទាំងនោះទៅកាន់មិត្តភក្តិ។<br>- បង្កើតនិយមន័យនៃអក្ខរកម្មហិរញ្ញវត្ថុ។ | ៤៥ |
| **ជំពូកទី២៖** ការសន្សំទុកសម្រាប់ថ្ងៃស្អែក | ១- ចូរយើងស្វែងយល់ពីប្រវត្តិរបស់ប្រាក់នៅក្នុងពិភពលោក | - ពន្យល់ពីការវិវត្តរបស់ប្រាក់នៅក្នុងប្រវត្តិសាស្ត្រ។<br>- រាប់ឈ្មោះរូបិយប័ណ្ណរបស់ប្រទេសនៅតំបន់អាស៊ាន។<br>- ប្រៀបធៀបអត្រាប្តូរប្រាក់រៀលទៅនឹងរូបិយប័ណ្ណផ្សេងទៀត។ | ៤៥ |
| | ២- ទម្លាប់សន្សំ | - សង្ខេបពីសារៈសំខាន់នៃការសន្សំធនធាន និងអំពើល្អ សម្រាប់ការគ្រប់គ្រងបរិស្ថានផ្ទាល់ខ្លួន។<br>- បំពេញតារាងសន្សំប្រចាំថ្ងៃក្នុងថ្នាក់រៀន និងនៅផ្ទះ។ | ៤៥ |
| | ៣- ប្រព័ន្ធធនាគារ | - រាប់ឈ្មោះការងារទាំងអស់នៅក្នុងវិស័យធនាគារតាមរយៈការស្រាវជ្រាវ។<br>- រាយការណ៍អំពីអត្ថប្រយោជន៍នៃការសន្សំប្រាក់ដោយប្រើប្រព័ន្ធធនាគារ តាមរយៈការស្រាវជ្រាវ។<br>- ប្រៀបធៀបអត្ថប្រយោជន៍នៃការសន្សំពីធនាគារក្នុង | ១៨០ |

| | | | |
|---|---|---|---|
| | | ស្រុក។ | |
| | ៤- ការសម្រេចចិត្តរបស់អ្នកក្នុងការសន្សំ | - ប្រៀបធៀបគុណសម្បត្តិ និងគុណវិបត្តិនៃវិធីសន្សំផ្សេងៗ<br>- បង្កើតគោលដៅសន្សំរយៈពេលខ្លីនិងរយៈពេលវែង។ | ៤៥ |
| **ជំពូកទី៣៖** សិទ្ធិក្នុងការរកប្រាក់ | ១- ពិភពការងាររបស់កុមារ | - ពណ៌នាអំពីនិយមន័យនៃការងារកុមារ និងពលកម្មកុមារ។<br>- ចាត់ថ្នាក់ការងារកុមារ និងពលកម្មកុមារ។<br>- មានទំនុកចិត្តក្នុងការបដិសេធរាល់ទម្រង់នៃពលកម្មកុមារ។ | ៤៥ |
| | ២- ជម្រើសក្នុងការរកប្រាក់ | - វាយតម្លៃជំនាញរបស់ខ្លួនដើម្បីកំណត់នូវអ្វីជាទេព្យកោសល្យសម្រាប់ការងារណាមួយ។<br>- បញ្ជាក់វិធីផ្សេងៗនៃការរកប្រាក់<br>- បង្កើតផែនការផ្ទាល់ខ្លួនដើម្បីរកប្រាក់ និងពង្រឹងសុខុមាលភាពរបស់ខ្លួន។ | ៩០ |
| **ជំពូកទី៤៖** តើខ្ញុំចំណាយប្រាក់ដោយឆ្លាតវៃដែរឬទេ? | ១- ជម្រើសក្នុងការចំណាយ | - កំណត់និយមន័យ និងចាត់ថ្នាក់ភាពខុសគ្នារវាងការចង់បាន និងតម្រូវការ<br>- ធ្វើលំហាត់ដែលតម្រូវឱ្យពួកគេត្រូវកំណត់អាទិភាពលើតម្រូវការចំណាយផ្ទាល់ខ្លួនរបស់ពួកគេ។ | ៤៥ |
| **ជំពូកទី៥៖** សងគុណចំពោះសហគមន៍របស់អ្នកវិញ | ១- តម្រូវការសហគមន៍អ្នក | - កំណត់តម្រូវការរបស់សហគមន៍ដើម្បីបង្កើតដំណោះស្រាយ។<br>- មានទំនុកចិត្តក្នុងការប្រាស្រ័យទាក់ទងជាមួយប្រជាជនក្នុងសហគមន៍។ | ៤៥ |
| | ២- ការបង្កើតគម្រោងតូចមួយសម្រាប់សហគមន៍យើង | - កំណត់បានលក្ខណៈសម្បត្តិនៃពលរដ្ឋសកម្ម<br>- ចែករំលែកបទពិសោធន៍សកម្មភាពផ្សេងៗដែលឆ្លើយតបនឹងពលរដ្ឋសកម្ម<br>- កំណត់តម្រូវការសហគមន៍ដើម្បីចូលរួមដោះស្រាយ។<br>- មានទំនុកចិត្តក្នុងការប្រាស្រ័យទាក់ទងជាមួយប្រជាជនក្នុងសហគមន៍។ | ៩០ |
| **ជំពូកទី៦៖** ការបញ្ចប់មេរៀនអក្ខរកម្មហិរញ្ញវត្ថុ | ១- ការបញ្ចប់មេរៀនស្តីពីអក្ខរកម្មហិរញ្ញវត្ថុ | - រៀបរាប់អំពីគំនិត និងអារម្មណ៍របស់ពួកគេ នៅចុងឆ្នាំសិក្សា តាមរយៈដំណើរការឆ្លុះបញ្ចាំង។<br>- រៀបរាប់ពីភាពប្រសើរឡើងផ្នែកចំណេះដឹង និងអាកប្បកិរិយាស្តីពីអក្ខរកម្មហិរញ្ញវត្ថុ | ៤៥ |

## ៥- ការវាយតម្លៃ

ការវាយតម្លៃសិស្សមានពីរផ្នែក។ មួយផ្នែកជាការវាយតម្លៃមុនវគ្គ ឬក្រោយវគ្គ។ ការវាយតម្លៃសិស្សមុនវគ្គធ្វើឡើងក្នុងមេរៀនទី២ និងការវាយតម្លៃសិស្សក្រោយវគ្គ នឹងអនុវត្តនៅបញ្ចប់មេរៀនទី១០។ ផ្នែកមួយទៀត ជាការវាយតម្លៃឥរិយាបថសិស្ស។ គ្រូអាចបំពេញទម្រង់សង្កេតឥរិយាបថសិស្សនៅមេរៀនទី៨ ទី៩ ឬទី១០។ ការវាយតម្លៃទាំងពីរចំណុចនេះមានសារៈសំខាន់ក្នុងការវាស់ចំណេះដឹង និងឥរិយាបថសិស្សម្នាក់ៗ។ ចំពោះការវាយតម្លៃនេះ ពិន្ទុសរុបគឺ៥០ ដោយក្នុងនោះពិន្ទុ៣៥ ទៅលើឥរិយាបថសិស្ស និងពិន្ទុ១៥ ទៅលើការធ្វើតេស្តក្រោយវគ្គ។

ទម្រង់សង្កេតថ្នាក់រៀន រៀបចំឡើងដើម្បីជួយគ្រូធ្វើស្វ័យវាយតម្លៃលើការបង្រៀនរបស់គាត់ក្នុងការបង្រៀនមេរៀននេះ។ គ្រូអាចអភិវឌ្ឍការបង្រៀនរបស់ខ្លួនតាមរយៈការបំពេញទម្រង់នេះ។ នាយកសាលា ការិយាល័យនិងមន្ទីរអប់រំ យុវជន និងកីឡា និងអ្នកពាក់ព័ន្ធ អាចប្រើប្រាស់ទម្រង់នេះ ដើម្បីសង្កេតការបង្រៀនរបស់លោកគ្រូ អ្នកគ្រូនៅក្នុងថ្នាក់រៀន។

# ជំពូកទី១

# ស្វាគមន៍មកកាន់អក្ខរកម្មហិរញ្ញវត្ថុ

## មេរៀនទី១ ការគោរពគ្នាទៅវិញទៅមក

| | |
|---|---|
|  | រយៈពេល៖ ៤៥ នាទី |
|  | ការត្រៀមខ្លួនរបស់គ្រូ មុនចូលបង្រៀន<br>- អានមេរៀនទាំងមូល<br>- ថតចម្លងសន្លឹកកិច្ចការ<br>- អានឯកសារចែកទី៤៖ ព័ត៌មានជំនួយអំពីបទវិន័យម្រាមដៃទាំងប្រាំ។ |
|  | សម្ភារៈ ធនធានដែលចាំបាច់<br>- សន្លឹកកិច្ចការ ១.១៖ អត្តសញ្ញាណរបស់ខ្ញុំ<br>- សន្លឹកកិច្ចការ ១.២៖ អត្តសញ្ញាណដែលបានរងឥទ្ធិពល<br>- សន្លឹកកិច្ចការ ១.៣៖ រូបភាពនៃបទវិន័យម្រាមដៃទាំងប្រាំ<br>- ឯកសារចែក ១.៤៖ ព័ត៌មានជំនួយអំពីបទវិន័យម្រាមដៃទាំងប្រាំ<br>- ស្កុត/ ប្លាស្ទិក ក្រដាស A4 (ពណ៌ស និងពណ៌ផ្សេងៗ)<br>- ប៊ិក ខ្មៅដៃពណ៌ កន្ត្រៃ និងកាវ។ |
|  | លទ្ធផលសិក្សា៖<br>បន្ទាប់ពីបញ្ចប់មេរៀននេះ សិស្សនឹងអាច៖<br>- ពណ៌នាអំពីខ្លួនឯងដោយវិជ្ជមាន និងអំពីឥទ្ធិពលនៃអត្តសញ្ញាណរបស់ខ្លួន។<br>- បង្កើតវិន័យក្នុងថ្នាក់រៀនដើម្បីឱ្យមានបរិយាកាសបរិយាបន្នជាមួយមិត្តភក្តិ និងគ្រូបង្រៀន។<br>- គោរពភាពចម្រុះនៃអត្តសញ្ញាណរបស់អ្នកដទៃ។ |

### សេចក្តីផ្តើម ( ៥នាទី )

គ្រូស្វាគមន៍សិស្សទាំងអស់គ្នា និងគ្រប់គ្រងថ្នាក់រៀនឱ្យបានល្អដូចជា អវត្តមាន អនាម័យសិស្ស និងថ្នាក់រៀនស្អាត។ គ្រូបន្ថែមទៀតថា ប្អូនៗទាំងអស់គ្នានឹងសិក្សាថ្នាក់អក្ខរកម្មហិរញ្ញវត្ថុក្នុងសាលារបស់ពួកយើង។ មុននឹងចាប់ផ្តើមមេរៀន យើងគប្បីឈ្វេងយល់ពីគ្នាទៅវិញទៅមក។

មេរៀននេះ ប្អូននឹងយល់ដឹងអំពីខ្លួនឯង និងអត្តសញ្ញាណថាតើអត្តសញ្ញាណជាអ្វី? ហេតុអ្វីបានជាវាសំខាន់ដែលត្រូវយល់ដឹងអំពីខ្លួនឯង? ហេតុអ្វីបានជាតម្លៃខ្លួនឯងមានសារៈសំខាន់? វាក៏ទាក់ទាញការផ្តោតអារម្មណ៍ទៅលើរបៀបដែលការយល់ដឹងពីខ្លួនឯងរបស់យើង ជារឿយៗត្រូវបានផ្សារភ្ជាប់ជាមួយការយល់ឃើញរបស់អ្នកដទៃថា យើងជានរណា និងជុំវិញគំនិតនៃទំនុកចិត្តលើខ្លួនឯង និងការគោរពខ្លួនឯង។

## សកម្មភាពសំខាន់ទី១៖ អត្តសញ្ញាណរបស់ខ្ញុំ (៣០នាទី)

គ្រូឱ្យសិស្សចាប់ដៃគូជាមួយសិស្សម្នាក់ទៀតដែលពួកគេមិនស្គាល់ច្បាស់។ ពួកគេមិនគួរចាប់ដៃគូជាមួយមិត្តភក្តិជិតស្និទ្ធទេ។ ប្រសិនបើសិស្សណាម្នាក់មិនមានដៃគូ ពួកគេអាចចូលរួមជាក្រុមដែលមានគ្នាបីនាក់។

- សិស្សណែនាំខ្លួនដល់គ្នាទៅវិញទៅមកក្នុងរយៈពេលប្រាំនាទីដោយប្រើប្រយោគដែលបានផ្ដល់ឱ្យ។
- ប្អូនគួរតែស្ដាប់ដោយយកចិត្តទុកដាក់ នៅពេលដែលដៃគូរបស់ប្អូននិយាយប្រយោគទាំងនោះ។
- គ្រូបង្ហាញឧទាហរណ៍មួយនៅលើក្ដារខៀន៖
  - ✓ ខ្ញុំឈ្មោះ រក្សា។
  - ✓ ខ្ញុំមានអាយុ ១៥ឆ្នាំ។
  - ✓ ខ្ញុំរស់នៅភូមិ១ ឃុំឡាមិញ ស្រុកបកែវ ខេត្តរតនគិរី។
  - ✓ ខ្ញុំចូលចិត្តសត្វឆ្មា។
  - ✓ ខ្ញុំមិនចូលចិត្តសត្វឆ្កែទេ។




- នៅពេលដែលសិស្សទាំងអស់បាននិយាយប្រយោគទាំងប្រាំរបស់ពួកគេខាងលើ គ្រូចែក **ឯកសារទី១៖** សន្លឹកទទេនៃដ្យាក្រាមអត្តសញ្ញាណរបស់ខ្ញុំដល់សិស្សម្នាក់ៗ ដើម្បីនិយាយបន្ថែមអំពីខ្លួនគេផ្ទាល់។ ពួកគេមានពេលប្រាំនាទី ដើម្បីបំពេញអត្តសញ្ញាណរបស់ពួកគេ។
- នៅពេលដែលសិស្សគ្រប់គ្នាបានបំពេញអត្តសញ្ញាណរបស់ពួកគេចប់ សិស្សមានពេលប្រាំនាទីដើម្បីនិយាយជាមួយដៃគូអំពីអត្តសញ្ញាណរបស់ខ្លួន។
- គ្រូឱ្យសិស្សមួយគូឬពីរគូចែករំលែកអត្តសញ្ញាណមិត្តភក្តិរបស់ពួកគេជាមួយសិស្សក្នុងថ្នាក់ទាំងមូល។
- គ្រូកត់ចំណាំនៅលើក្ដារខៀនអំពីទិដ្ឋភាពទូទៅ៖
  **ឧ. អាយុ ភេទ ភាសានិយាយ ការអប់រំ ចំណូលចិត្ត (ចូលចិត្តឬមិនចូលចិត្ត) ឬចំណុចខ្លាំង** ជាដើម សម្រាប់ប្រើដើម្បីពណ៌នាអំពីខ្លួនឯង។
- គ្រូឱ្យសិស្សបិទដ្យាក្រាមអត្តសញ្ញាណរបស់ពួកគេនៅលើក្ដារខៀនតាមការចាំបាច់ អំឡុងម៉ោងរៀន។

គ្រូពន្យល់ថា មានកត្តាពីរដែលបង្កើតបានជាអត្តសញ្ញាណរបស់យើង៖ ១)អ្វីដែលយើងគិតពីខ្លួនយើងផ្ទាល់ និង២) អ្វីដែលអ្នកដទៃគិតមកលើយើង ហើយទាំងពីរនេះមានឥទ្ធិពលលើគ្នាទៅវិញទៅមក។

**គ្រូចែកឯកសារទី២៖** អត្តសញ្ញាណដែលបានរងឥទ្ធិពល។ សិស្សបំពេញពាក្យដោយប្រើគុណនាមដើម្បីពណ៌នាអំពីអត្តសញ្ញាណរបស់ពួកគេក្នុងបញ្ជីទី១។ បន្ទាប់មក ពួកគេផ្លាស់ប្ដូរក្រដាសរបស់ពួកគេជាមួយដៃគូ ហើយដៃគូនឹងសរសេរពាក្យដោយប្រើគុណនាមដើម្បីពណ៌នាអំពីដៃគូរបស់ខ្លួននៅក្នុងបញ្ជីទី២។ ជាចុងក្រោយ សិស្សទាំងពីរនាក់ឆ្លុះបញ្ចាំងពីពាក្យដែលបានសរសេរ ហើយដាក់សញ្ញាធីក (✓) លើពាក្យដែលពួកគេចូលចិត្ត អំពីអត្តសញ្ញាណរបស់ពួកគេ និងសញ្ញាខ្វែង (×) លើពាក្យដែលពួកគេមិនចូលចិត្ត ឬចង់ផ្លាស់ប្ដូរអំពីពួកគេផ្ទាល់។

គ្រូសម្របសម្រួលការពិភាក្សា ដោយប្រើសំណួរបើកដូចខាងក្រោម៖

- តើប្អូនចូលចិត្តអ្វីខ្លះនៅក្នុងសកម្មភាពនេះ?

- តើប្អូនមានអារម្មណ៍យ៉ាងណាបន្ទាប់ពីធ្វើសកម្មភាពនេះ?
- តើអត្តសញ្ញាណរបស់ប្អូនជះឥទ្ធិពលអ្វីខ្លះចំពោះអ្នកដទៃ ដែលកំពុងគិតមកលើប្អូន?
- តើប្អូនធ្លាប់គិតឬពិនិត្យមើលខ្លួនប្អូនឡើងវិញដែរឬទេ នៅពេលដឹងថាអ្នកដទៃគិតយ៉ាងណាចំពោះប្អូន?

## សកម្មភាពសំខាន់ទី២៖ រៀបចំបទប្បញ្ញត្តិក្នុងថ្នាក់រៀន - បទប្បញ្ញត្តិម្រាមដៃទាំងប្រាំ (១៥នាទី)

គ្រូណែនាំបទប្បញ្ញត្តិក្នុងថ្នាក់រៀនដោយលើកឡើងថា «ប្អូនៗទាំងអស់គ្នា! យើងនឹងបង្កើតបរិយាកាសសិក្សា ដែលមានសុវត្ថិភាពក្នុងមេរៀនអក្ខរកម្មហិរញ្ញវត្ថុរបស់យើងដើម្បីទទួលបានការសប្បាយ ការគោរព និងការចូលរួមដោយបង្កើតបទប្បញ្ញត្តិក្នុងថ្នាក់។ តាមគំនិតរបស់ប្អូន តើយើងគួរធ្វើអ្វី ឬមិនគួរធ្វើអ្វីក្នុងថ្នាក់នេះ?»

**ការងារជាក្រុម** (១០នាទី)

- គ្រូបែងចែកសិស្សជាប្រាំក្រុម។
- គ្រូចែករូបភាពម្រាមដៃឱ្យក្រុមនីមួយៗ ដូចខាងក្រោម៖ (សូមមើលសន្លឹកកិច្ចការ ៣)
  - ✓ រូបភាពម្រាមដៃកូន៖ សុវត្ថិភាព
  - ✓ រូបភាពម្រាមដៃនាង៖ ការប្តេជ្ញាចិត្ត
  - ✓ រូបភាពម្រាមដៃកណ្តាល៖ គោរព
  - ✓ រូបភាពម្រាមដៃចង្អុល៖ ទិសដៅ
  - ✓ រូបភាពលើកមេដៃឡើង
- ក្រុមនីមួយៗសរសេរពាក្យ ឬឃ្លាដែលមានអត្ថន័យទាក់ទងនឹងម្រាមដៃនីមួយៗ។ គ្រូចែកក្រដាសទំហំ A4 ចែកជា៤ ចំនួន២សន្លឹកដល់សិស្សម្នាក់ៗ ដោយ១សន្លឹកត្រូវសរសេរតែមួយពាក្យឬមួយប្រយោគ ។
- អ្នកដឹកនាំក្រុមទាំងអស់ធ្វើបទបង្ហាញកិច្ចការរបស់ពួកគេដល់ថ្នាក់ទាំងមូល។
- គ្រូសម្របសម្រួលគំនិត។ (សូមមើលឯកសារចែកទី៤៖ ព័ត៌មានជំនួយពីបទប្បញ្ញត្តិម្រាមទាំងប្រាំ)

សិស្សដាក់បញ្ចូលនូវក្បួនបទប្បញ្ញត្តិម្រាមដៃទៅក្នុងការរចនាផ្ទាំងរូបភាពដ៏ស្រស់ស្អាតសម្រាប់បង្ហាញលើជញ្ជាំងថ្នាក់រៀន។ សិស្សត្រូវបានលើកទឹកចិត្តឱ្យបង្កើតផ្ទាំងរូបភាពដោយប្រើសម្ភារៈផ្សេងៗដូចជា ក្រដាសពណ៌ និងខ្មៅដៃពណ៌។

គ្រូសរសើរសិស្សថា «ល្អណាស់! គំនិតរបស់ប្អូនពិតជាមានប្រយោជន៍ ហើយបទប្បញ្ញត្តិម្រាមដៃទាំងប្រាំត្រូវបានបង្កើតឡើងរួចហើយ។ យើងទាំងអស់គ្នាត្រូវគោរព និងអនុវត្តបទប្បញ្ញត្តិនេះក្នុងថ្នាក់របស់យើងជាប្រចាំ។ ប្អូននឹងក្លាយជាកូនល្អ សិស្សល្អ និងជាពលរដ្ឋល្អក្នុងសង្គមយើង។»

**ការឆ្លុះបញ្ចាំង៖ ៣-៥នាទី**

តើប្អូនបានរៀនអ្វីខ្លះនៅថ្ងៃនេះ? តើប្អូនចូលចិត្តអ្វីខ្លះអំពីមេរៀនថ្ងៃនេះ? តើប្អូនទទួលបានចំណេះដឹងអ្វីខ្លះពីមេរៀននេះ ពេលប្អូនត្រឡប់ទៅផ្ទះវិញ?

## សន្លឹកកិច្ចការ ១.១៖ អត្តសញ្ញាណរបស់ខ្ញុំ

ចូរបំពេញព័ត៌មានរបស់ប្អូននៅក្នុងចន្លោះដ្យាក្រាមអត្តសញ្ញាណខាងក្រោម។




## សន្លឹកកិច្ចការ ១.២៖ អត្តសញ្ញាណដែលបានរងឥទ្ធិពល

ចូរបំពេញពាក្យដោយប្រើគុណនាមដើម្បីពណ៌នាអំពីអត្តសញ្ញាណរបស់ប្អូនក្នុងបញ្ជីទី១។ បន្ទាប់មកផ្លាស់ប្តូរក្រដាសជាមួយដៃគូ ហើយដៃគូរបស់ប្អូននឹងសរសេរពាក្យដោយប្រើគុណនាមដើម្បីពណ៌នាអំពីប្អូននៅក្នុងបញ្ជីទី២។ ជាចុងក្រោយ ប្អូនទាំងពីរឆ្លុះបញ្ចាំងអំពីពាក្យដែលបានសរសេរ ហើយដាក់សញ្ញាធីក (✓) លើពាក្យដែលប្អូនទាំងពីរចូលចិត្ត អំពីអត្តសញ្ញាណរបស់ខ្លួន និងសញ្ញាខ្វែង (×) ទៅលើពាក្យដែលប្អូនទាំងពីរមិនចូលចិត្ត ឬចង់ផ្លាស់ប្តូរអំពីខ្លួនឯង។

**បញ្ជីទី១៖**

គុណនាមដែលប្អូនប្រើដើម្បីពណ៌នាពីអត្តសញ្ញាណរបស់ប្អូន ឬខ្លួនប្អូន។

ឧ. ក្មេងស្រីល្អម្នាក់ ....................................

....................................................................
....................................................................
....................................................................
....................................................................
....................................................................
....................................................................
....................................................................
....................................................................

**បញ្ជីទី២៖**

គុណនាមដែលមិត្តភក្តិរបស់ប្អូនបានប្រើដើម្បីពណ៌នាពីអត្តសញ្ញាណរបស់ប្អូន ឬខ្លួនប្អូន។

ឧ. ក្មេងស្រីខ្ជិលម្នាក់....................................

....................................................................
....................................................................
....................................................................
....................................................................
....................................................................
....................................................................
....................................................................
....................................................................

## សន្លឹកកិច្ចការ ១.៣៖ បទប្បញ្ញត្តិម្រាមដៃទាំងប្រាំ



ម្រាមដៃកូន

______________________________

______________________________

______________________________



ម្រាមដៃនាង

______________________________

______________________________

______________________________



ម្រាមដៃកណ្ដាល

______________________________

______________________________

______________________________



ម្រាមដៃចង្អុល

______________________________

______________________________

______________________________



លើកមេដៃឡើង

______________________________

______________________________

______________________________

# ឯកសារចែក ១.៤៖ បទប្បញ្ញត្តិម្រាមដៃទាំងប្រាំ

**ឯកសារចែកទី៤៖ ព័ត៌មានជំនួយអំពីបទប្បញ្ញត្តិម្រាមដៃទាំងប្រាំ[5] សម្រាប់គ្រូបង្រៀនប៉ុណ្ណោះ**

គ្រូប្រើព័ត៌មាននេះ ដើម្បីជួយសម្របសម្រួលដល់សិស្សក្នុងការបង្កើតជាបទប្បញ្ញត្តិម្រាមដៃទាំងប្រាំ។

១- **ម្រាមដៃកូន**តំណាងឱ្យ «សុវត្ថិភាពផ្លូវកាយ និងផ្លូវអារម្មណ៍»។ ជាទូទៅ ម្រាមដៃកូនជាម្រាមដៃតូចជាងគេ និងងាយទទួលរងការឈឺចាប់បំផុត។ នេះជាឧទាហរណ៍គំរូមួយចំនួន៖ ឧ. ចូរស្រឡាញ់ខ្លួនឯងនិងអ្នកដទៃ និយាយដោយគួរសម ជួយថែរក្សាមិត្តភក្តិដែលខ្សោយ និងរីករាយជាមួយគ្នា។

២- **ម្រាមដៃនាង៖** គូស្វាមីភរិយាជាច្រើនពាក់ចិញ្ចៀនលើម្រាមដៃនេះ។ វាតំណាងឱ្យ «ការចូលរួម និងការប្តេជ្ញាចិត្ត»។ យើងនឹងប្តេជ្ញាសាកល្បងធ្វើសកម្មភាពថ្មីៗ និងសិក្សាឱ្យបានច្រើន។ នេះជាឧទាហរណ៍គំរូមួយចំនួន៖ ឧ. ចូលរួមសកម្ម ចែករំលែក ឬផ្តួចផ្តើមគំនិត ចេះធ្វើការងារជាក្រុមបានល្អ ចូលរួមក្នុងសកម្មភាព។

៣- **ម្រាមដៃកណ្តាល**ជាធម្មតាមានន័យអវិជ្ជមាន និងអាក្រក់ ប៉ុន្តែសម្រាប់ថ្នាក់របស់យើង វាតំណាងឱ្យ «ការគោរព»។ នេះជាឧទាហរណ៍គំរូមួយចំនួន៖

- គោរពអត្តសញ្ញាណរបស់គ្នាទៅវិញទៅមក
- ស្តាប់មិត្តរបស់ប្អូនដោយយកចិត្តទុកដាក់
- លើកដៃរបស់ប្អូននៅពេលចង់និយាយ ហើយរង់ចាំដល់វេនរបស់ប្អូន
- រៀបចំសណ្តាប់ធ្នាប់ថ្នាក់រៀនរបស់ប្អូនឱ្យបានទៀងទាត់។

៤- **ម្រាមដៃចង្អុល**ជាធម្មតាត្រូវបានប្រើដើម្បីផ្តល់ «ទិសដៅ»។ នេះជាឧទាហរណ៍គំរូមួយចំនួន៖

- ចូរអាន និងធ្វើតាមការណែនាំដោយយកចិត្តទុកដាក់ មុនពេលចាប់ផ្តើមសកម្មភាព។
- ចូរផ្តោតលើការសិក្សារបស់ប្អូន ដើម្បីសម្រេចគោលដៅបាន។

៥- **លើកមេដៃឡើង** តើវាមានន័យយ៉ាងណាចំពោះប្អូន?

- ធ្វើបានល្អ / ប្អូនធ្វើបានល្អ
- ល្អណាស់ / ល្អឥតខ្ចោះ
- អបអរសាទរ
- អស្ចារ្យមែន។

[5] Inspired by the five fingers contract, Facilitator Overview Manual, P.A.C.E. Bronze Curriculum for Older Adolescent Girls.

# មេរៀនទី២ ចាប់ផ្តើមដំណើរមេរៀនស្តីពីអក្ខរកម្មហិរញ្ញវត្ថុ

| | |
|---|---|
| | រយៈពេល៖ ៤៥ នាទី |
| | **ការត្រៀមខ្លួនរបស់គ្រូ មុនចូលបង្រៀន**<br>- អានមេរៀនទាំងមូល<br>- ថតចម្លងឯកសារចែក។ |
| | **សម្ភារៈ ធនធានដែលចាំបាច់**<br>- ឯកសារចែកទី១.២.១៖ តេស្តមុនវគ្គ<br>- ឯកសារចែកទី១.២.២៖ គំនិត និងអារម្មណ៍របស់ខ្ញុំ<br>- ក្រដាសផ្ទាំងធំ ក្រដាស A4 ពណ៌ស និងពណ៌ផ្សេងៗ ហ្វឺត កន្រ្តៃ។ល។ |
| | **លទ្ធផលសិក្សា៖**<br>បន្ទាប់ពីបញ្ចប់មេរៀននេះ សិស្សនឹងអាច៖<br>- សរសេរពីគំនិត និងអារម្មណ៍ នៅពេលចាប់ផ្តើមឆ្នាំសិក្សាថ្មី<br>- បង្ហាញគំនិត និងអារម្មណ៍ទាំងនោះទៅកាន់មិត្តភក្តិ<br>- បង្កើតនិយមន័យនៃអក្ខរកម្មហិរញ្ញវត្ថុ។ |

## សេចក្តីផ្តើម (៥នាទី)

គ្រូស្វាគមន៍សិស្ស និងគ្រប់គ្រងថ្នាក់រៀនឱ្យបានល្អ។ បន្ទាប់មកគ្រូរំលឹកមេរៀនចាស់អំពីបទប្បញ្ញត្តិក្នុងថ្នាក់រៀនដោយប្រើម្រាមដៃប្រាំ។

## សកម្មភាពសំខាន់ទី១៖ តេស្តមុនវគ្គទាក់ទងនឹងអក្ខរកម្មហិរញ្ញវត្ថុ (១០នាទី)

គ្រូពន្យល់ថា សិស្សនឹងត្រូវបំពេញ **ឯកសារចែកទី១.២.១៖ តេស្តមុនវគ្គ**។ ការវាយតម្លៃនេះមានគោលបំណងយល់ដឹងកាន់តែប្រសើរអំពីចំណេះដឹងរបស់សិស្សទាក់ទងនឹងអក្ខរកម្មហិរញ្ញវត្ថុ។ មុនពេលចាប់ផ្តើម សិស្សត្រូវយករបស់របរផ្ទាល់ខ្លួនទាំងអស់ចេញពីតុ ហើយដាក់វានៅក្រោមតុ ឬនៅផ្នែកខាងក្រោយថ្នាក់រៀន។ នៅពេលតេស្តចាប់ផ្តើម សិស្សនឹងមិនត្រូវបានអនុញ្ញាតឱ្យជជែកជាមួយគ្នាឡើយ។ ប្រសិនបើមានសំណួរទាក់ទងនឹងតេស្តត្រូវលើកដៃដើម្បីសួរគ្រូ។ សិស្សមានពេល១០នាទីក្នុងការធ្វើតេស្ត។ ឥឡូវនេះសិស្សអាចចាប់ផ្តើម។

**អត្រាកំណែតេស្តមុនវគ្គ**

| | | | | |
|---|---|---|---|---|
| ១- គ្មានចម្លើយត្រូវ | ២- គ្មានចម្លើយត្រូវ | ៣- ង | ៤- ក | ៥- ក |
| ៦- គ្មានចម្លើយត្រូវ | ៧- គ | ៨- ខ | ៩- ទេ | ១០- សៀវភៅសន្សំ |
| ១១- គ្មានចម្លើយត្រូវ | ១២- ឃ | ១៣- គ | ១៤- គ | ១៥- គ |
| ១៦- ក និង គ | ១៧- ពលកម្មកុមារ | ១៨- | ១៩- ឃ | |

## សកម្មភាពសំខាន់ទី២៖ និយមន័យអក្ខរកម្មហិរញ្ញវត្ថុ (១០នាទី)

គ្រូស្វាគមន៍សិស្សមកកាន់ដំណើរការសិក្សាអំពីអក្ខរកម្មហិរញ្ញវត្ថុ ហើយសួរថា នៅពេលប្អូនឮពាក្យថា អក្ខរកម្មហិរញ្ញវត្ថុ តើប្អូនគិតដល់អ្វីមុនគេ? (១០នាទី)




គ្រូគូរផែនទីគំនិត (mind map) ដែលទទេមួយ បន្ទាប់មកសរសេរចម្លើយរបស់សិស្សស្ដីពីអក្ខរកម្មហិរញ្ញវត្ថុ នៅលើក្ដារខៀនជាទម្រង់ផែនទីគំនិត។ នៅខាងស្ដាំនេះ គឺជាឧទាហរណ៍នៃផែនទីគំនិត។

ចម្លើយមួយចំនួនដែលអាចមាននៅក្នុងផែនទីគំនិតរួមមានដូចខាងក្រោម៖ ប្រាក់ របស់របរកែច្នៃឡើងវិញ ការលក់ ធ្វើការងារ រកប្រាក់ សន្សំ ធនាគារ កម្ចី និងបំណុលជាដើម។

### គន្លឹះចំណេះដឹងសម្រាប់គ្រូ

ផែនទីគំនិត គឺជាដ្យាក្រាមរូបភាពដែលត្រូវបានប្រើដើម្បីរៀបចំទិន្នន័យឬព័ត៌មានផ្សេងៗទាក់ទងនឹងគំនិតឬប្រធានបទមួយ។ ប្រធានបទនោះត្រូវសរសេរនៅចំកណ្ដាលរង្វង់ ហើយគ្រប់គ្នាអាចចែករំលែកពាក្យដែលផ្សារភ្ជាប់ទៅនឹងប្រធានបទនោះ។ ក្បួនបទប្បញ្ញត្តិសម្រាប់ផែនទីគំនិត៖

- គំនិតកាន់តែច្រើន កាន់តែល្អ!
- គ្មានការរិះគន់។
- គ្មានគំនិតណាជាគំនិតមិនល្អនោះទេ។
- បង្កើតគំនិតថ្មីផ្សេងទៀត។
- បញ្ចេញគំនិតទាំងអស់។

បន្ទាប់មក គ្រូសួរសំណួរដល់សិស្សទាំងអស់ដូចខាងក្រោម៖

| | បាទ/ចាស | ទេ | គ្មានយោបល់ |
|---|---|---|---|
| - តើប្អូនគិតថាក្មេងដែលមានអាយុស្របាលប្អូនអាចសិក្សាអំពីអក្ខរកម្មហិរញ្ញវត្ថុបានដែរឬទេ? | --- | --- | --- |
| - ពេលប្អូនមានប្រាក់ តើប្អូនធ្លាប់ជួយអ្នកដែលត្រូវការជំនួយដែរឬទេ? | --- | --- | --- |
| - តើប្អូនគិតថា ប្អូននឹងទទួលបានអត្ថប្រយោជន៍ពីការសិក្សាអំពីអក្ខរកម្មហិរញ្ញវត្ថុដែរឬទេ? | --- | --- | --- |
| - តើប្អូនមានការរំពឹងទុកអ្វីពីកម្មវិធីសិក្សានេះដែរឬទេ? | --- | --- | --- |

ប្រសិនបើសិស្សយល់ព្រម សូមឱ្យពួកគេលើកដៃ ឬក្រោកឈរ។ បន្ទាប់មក សូមឱ្យសិស្សផ្ដល់មូលហេតុសម្រាប់សំណួរនីមួយៗ។ គ្រូកត់ត្រាចំនួនសិស្សដែលនិយាយថា «បាទ/ចាស»«ទេ»ឬ«គ្មានយោបល់»។ (១០នាទី)

**ចំណាំ៖** គ្រូត្រូវសរសេរចម្លើយរបស់សិស្ស (ពាក្យ ឬឃ្លាគន្លឹះ) នៅលើក្ដារខៀន ដើម្បីបង្កើតទៅជានិយមន័យនៃអក្ខរកម្មហិរញ្ញវត្ថុ មុនពេលបញ្ចប់មេរៀនថ្ងៃនេះ។

គ្រូអរគុណសិស្សដែលបានចូលរួមយ៉ាងសកម្ម និងពន្យល់ថា ដោយប្រើប្រាស់ចម្លើយរបស់ប្អូនទាំងអស់ស្ដីពីអក្ខរកម្មហិរញ្ញវត្ថុដែលបានសរសេរនៅលើក្ដារខៀន យើងចង់បង្កើតនិយមន័យអក្ខរកម្មផ្នែកហិរញ្ញវត្ថុជាមួយគ្នា។ គ្រូឱ្យសិស្សធ្វើកិច្ចការជាដៃគូ ដើម្បីសរសេរនិយមន័យ ហើយពួកគេមានពេល៥នាទី ដើម្បីបង្កើតនិយមន័យ។ (៥នាទី)

ជាមួយដៃគូ សិស្សចាប់ផ្ដើមសរសេរនិយមន័យមួយនៃអក្ខរកម្មហិរញ្ញវត្ថុ។ សិស្សនឹងចែករំលែកនិយមន័យរបស់ពួកគេជាមួយមិត្តរួមថ្នាក់ទាំងអស់។

គ្រូប្រៀបធៀបនិយមន័យរបស់សិស្សជាមួយនិយមន័យផ្លូវការនៃអក្ខរកម្មហិរញ្ញវត្ថុ រួចសួរសិស្សថា តើនិយមន័យទាំងនេះដូចគ្នាដែរឬទេ។ តើខុសគ្នាដូចម្ដេច? តើមានអ្វីខ្លះខាតនៅក្នុងនិយមន័យរបស់សិស្ស?

**និយមន័យ**

**កម្មវិធីសិក្សាអក្ខរកម្មហិរញ្ញវត្ថុ៖** អក្ខរកម្មហិរញ្ញវត្ថុ បង្កើតជំនាញរបស់សិស្សក្នុងការគ្រប់គ្រងប្រាក់ ការសម្រេចចិត្ត ការគ្រប់គ្រងខ្លួនឯង និងទំនួលខុសត្រូវក្នុងសង្គម។ សិស្សសិក្សាពីរបៀបរៀបចំថវិកា សន្សំ ចំណាយ និងបរិច្ចាគ ដែលអាចធ្វើឱ្យពួកគេមានភាពរីជ្ជមានលើទម្លាប់ហិរញ្ញវត្ថុ និងបង្កើនសុខុមាលភាពរបស់ពួកគេ។

**ឬនិយមន័យរបស់ក្រសួងអប់រំ យុវជន និងកីឡា៖** អក្ខរកម្មហិរញ្ញវត្ថុ ជាការអនុវត្តចំណេះដឹង ការយល់ដឹង ជំនាញ គុណតម្លៃ និងអាកប្បកិរិយាទៅក្នុងបរិបទហិរញ្ញវត្ថុ ដែលអនុញ្ញាតឱ្យបុគ្គលម្នាក់ៗធ្វើការសម្រេចចិត្តប្រកបដោយការយល់ដឹងពេញលេញ និងមានប្រសិទ្ធភាពក្នុងការគ្រប់គ្រងប្រាក់របស់ខ្លួន ដែលជះឥទ្ធិពលលើខ្លួនឯង អ្នកដទៃ សហគមន៍ និងបរិស្ថាន។

បន្ទាប់ពីការពិភាក្សាខ្លីមួយ គ្រូបញ្ចប់ការពិភាក្សា ហើយសម្រេចចុងក្រោយលើនិយមន័យនៃអក្ខរកម្មហិរញ្ញវត្ថុ។ ខាងក្រោមនេះ គ្រូនឹងឃើញនិយមន័យគោលដៅរបស់អក្ខរកម្មហិរញ្ញវត្ថុ។

**ចំណាំ៖** គ្រូក៏អាចប្រើនិយមន័យនៃអក្ខរកម្មហិរញ្ញវត្ថុរបស់ក្រសួងអប់រំ យុវជន និងកីឡា ផងដែរសម្រាប់ជាជម្រើសមួយបន្ថែមលើនិយមន័យខាងលើ។

### សកម្មភាពសំខាន់ទី៣៖ គំនិត និងអារម្មណ៍របស់ខ្ញុំ (១៥នាទី)

គ្រូចែកឯកសារ ១.២.២ ដល់សិស្សគ្រប់គ្នាដើម្បីសរសេរអំពីគំនិត និងអារម្មណ៍ក្នុងការចូលរៀនក្នុងឆ្នាំសិក្សាថ្មីនៅក្នុងថ្នាក់រៀនថ្មីរបស់ពួកគេ។ សិស្សមានពេល១០នាទីធ្វើកិច្ចការនេះ។ បន្ទាប់មក គ្រូឱ្យសិស្សចែករំលែកគំនិតជាមួយដៃគូ និងជ្រើសរើសសិស្សស្ម័គ្រចិត្តចែករំលែកព័ត៌មានរបស់ខ្លួនដែលបានសរសេរ។

### ការឆ្លុះបញ្ចាំង (៣នាទី)

តើប្អូនបានរៀនអ្វីខ្លះនៅថ្ងៃនេះ? តើប្អូនចូលចិត្តអ្វីខ្លះអំពីមេរៀនថ្ងៃនេះ? តើប្អូនទទួលបានចំណេះដឹងអ្វីខ្លះពីមេរៀននេះ ពេលត្រឡប់ទៅផ្ទះវិញ?

## ឯកសារចែកទី១.២.១៖ តេស្តមុនវគ្គ ឬក្រោយវគ្គ

សូមយកចិត្តទុកដាក់អានការណែនាំសម្រាប់សំណួរខាងក្រោមទាក់ទងនឹងអក្ខរកម្មហិរញ្ញវត្ថុ បន្ទាប់មកជ្រើសរើសចម្លើយដែលប្អូនគិតថា ត្រឹមត្រូវ។

១- តើប្អូនធ្លាប់បានចូលរៀនវគ្គសិក្សាស្តីពីអក្ខរកម្មហិរញ្ញវត្ថុពីមុនមកដែរឬទេ? □ បាទ/ចាស □ ទេ

២- តើប្អូនវាយតម្លៃបានថា ចំណេះដឹងអក្ខរកម្មហិរញ្ញវត្ថុរបស់ប្អូនមានត្រឹមកម្រិតណា? (នៅលើមាត្រដ្ឋាន១ដល់៥ ដែល ១គឺទាបបំផុត និង ៥គឺខ្ពស់បំផុត)

□ ១ □ ២ □ ៣ □ ៤ □ ៥។

៣- អក្ខរកម្មហិរញ្ញវត្ថុសំដៅលើ៖ (ចម្លើយត្រឹមត្រូវមានច្រើនជាងមួយ)

ក- ការសន្សំ ខ- ការចំណាយ គ- ការរកប្រាក់ចំណូល ឃ- ការបរិច្ចាគ ង- ចម្លើយទាំងអស់ខាងលើ។

៤- តើជម្រើសមួយណា**មិនមែន**ជាប្រភេទនៃការសន្សំ?

ក- បន្ទាន់ ខ- រយៈពេលខ្លី គ- អត្រាការប្រាក់សាមញ្ញ ឃ- រយៈពេលវែង។

៥- តើប្អូននឹងចំណាយប្រាក់សន្សំរបស់ប្អូនជាបន្ទាន់ទៅលើជម្រើសមួយណា?

ក- ការព្យាបាល ខ- ម្ហូបអាហារ គ- ទូរសព្ទឆ្លាតវៃ ឃ- ថ្ងៃឈប់សម្រាក។

៦- តើប្អូនសន្សំប្រាក់ញឹកញាប់ប៉ុណ្ណា?

ក- ជានិច្ចកាល ខ- ញឹកញាប់ គ- ម្តងម្កាល ឃ- កម្រណាស់ ង- មិនដែលទេ។

៧- តើមួយណាជាគោលដៅសន្សំរយៈពេលវែង? (សូមជ្រើសរើសចម្លើយត្រឹមត្រូវ)

ក- វចនានុក្រម ខ- សៀវភៅរឿង គ- កង់ ឃ- សម្លៀកបំពាក់។

៨- សម្រាប់គោលដៅរយៈពេលខ្លី តើប្អូនគិតថាសន្សំរយៈពេលប៉ុន្មាន? (សូមជ្រើសរើសចម្លើយត្រឹមត្រូវ)

ក- ១ ឆ្នាំ ខ- ៦ ខែ គ- ៨ ខែ ឃ- ៩ ខែ។

៩- ប្អូនគួរតែអនុវត្តការសន្សំតែមួយប្រភេទប៉ុណ្ណោះ។

□ បាទ/ចាស □ ទេ។

១០- តើប្អូនតាមដានកំណត់ត្រានៃការចំណាយ និងការសន្សំរបស់ប្អូនដោយរបៀបណា?

១១- តើប្អូនមានទំនុកចិត្តកម្រិតណាក្នុងការចូលប្រើប្រាស់ប្រព័ន្ធធនាគារ?

ក- មានទំនុកចិត្តខ្លាំងណាស់ ខ- មានទំនុកចិត្ត គ- មានទំនុកចិត្តខ្លះៗ ឃ- មិនសូវមានទំនុកចិត្ត ង- គ្មានទំនុកចិត្ត។

១២- តើប្អូនអាចបង្កើតគណនីធនាគារបានដោយរបៀបណា? (សូមគូសចម្លើយទាំងឡាយណាដែលត្រឹមត្រូវ)

ក- ទាញយកកម្មវិធីរបស់ធនាគារនៅលើទូរសព្ទឆ្លាតវៃ ខ- ទៅកាន់ធនាគារ

គ- ផ្តល់អត្តសញ្ញាណប័ណ្ណនិងទូរសព្ទដៃរបស់ប្អូនទៅអ្នកប្រឹក្សាធនាគារ ឃ- ចម្លើយទាំងអស់ខាងលើ។

១៣- តើល្បះមួយណាត្រឹមត្រូវ?

ក- ចំណាយតិច និងរកបានច្រើន = ខាតបង់ ខ- ចំណាយច្រើន និងរកបានតិច = ចំណេញ

គ- ចំណាយតិច និងរកបានច្រើន = ចំណេញ ឃ- ចម្លើយទាំងអស់ខាងលើ។

១៤- ប្អូនមានប្រាក់ ហើយចង់ដាក់ប្រាក់ជាមួយធនាគារដែលផ្ដល់អត្រាការប្រាក់ល្អ។ ក្នុងចំណោមធនាគារខាងក្រោម តើធនាគារមួយណាដែលប្អូននឹងដាក់ប្រាក់បញ្ញើ?

ក- ធនាគារ កៈ អត្រាការប្រាក់ ០.៥% ក្នុងមួយឆ្នាំ

ខ- ធនាគារ ខៈ អត្រាការប្រាក់ ០.១% ក្នុងមួយឆ្នាំ

គ- ធនាគារ គៈ អត្រាការប្រាក់ ១% ក្នុងមួយឆ្នាំ

ឃ- ធនាគារ ឃៈ អត្រាការប្រាក់ ០.៩៩% ក្នុងមួយឆ្នាំ។

១៥- តើមួយណាខាងក្រោមជាការចង់បាន? (សូមជ្រើសរើសចម្លើយត្រឹមត្រូវ)

ក- ម្ហូបអាហារ ខ- ទឹក គ- ទូរសព្ទឆ្លាតវៃ ឃ- សម្លៀកបំពាក់។

១៦- តើមួយណាខាងក្រោមជាតម្រូវការ? (ចម្លើយអាចលើសពីមួយ)

ក- ទីជម្រក ខ- នាឡិកាថ្លៃៗ គ- សម្លៀកបំពាក់ ឃ- សម្លៀកបំពាក់ហ៊ីហា។

១៧- សូមអានល្បះខាងក្រោម៖ «បុប្ផាជាសិស្សថ្នាក់ទី៨។ ពេលខ្លះ នាងអវត្តមាន ដើម្បីទៅធ្វើការងារនៅចម្ការថ្នាំជក់ពីម៉ោង៦ព្រឹក ដល់ ៥ល្ងាច»។ តើប្អូនគិតថា វាជាការងាររបស់កុមារ ឬជាពលកម្មកុមារ?

□ ការងាររបស់កុមារ □ ពលកម្មកុមារ។

១៨- តើចម្លើយមួយណាខាងក្រោម ដែលប្អូនគិតថាជាវិធីដែលមានសុវត្ថិភាពបំផុតក្នុងការវិនិយោគប្រាក់ចំណូលរបស់ប្អូន។

ក- សន្សំទុកនៅក្នុងធនាគារ

ខ- ផ្ដល់ប្រាក់កម្ចីដល់សហគមន៍មូលដ្ឋានជាមួយនឹងអត្រាការប្រាក់ខ្ពស់

គ- ដើរតាមមិត្តភក្តិដើម្បីធ្វើអាជីវកម្ម

ឃ- ផ្ដល់ការបង្រៀនឯកជន។

១៩- តើរបស់មួយណាខាងក្រោមដែលអាចបរិច្ចាគបាន?

ក- ពេលវេលា ខ- ជំនាញ គ- ទំនិញ ឃ- ចម្លើយទាំងអស់ខាងលើ។

## ឯកសារចែកទី១.២.២៖ គំនិត និងអារម្មណ៍របស់ខ្ញុំ

**ការណែនាំ៖** ចូរកត់ត្រាអារម្មណ៍ គំនិត និងការរំពឹងទុកលទ្ធផលសិក្សាក្នុងថ្នាក់រៀនរបស់ប្អូនក្នុងឆ្នាំនេះ។



# ជំពូកទី២

# ការសន្សំទុកសម្រាប់ថ្ងៃស្អែក

## មេរៀនទី១ ចូរយើងឈ្វេងយល់ពីប្រវត្តិប្រាក់នៅក្នុងពិភពលោក

| | |
|---|---|
|  | រយៈពេល៖ ៤៥នាទី |
|  | ការត្រៀមខ្លួនរបស់គ្រូ មុនចូលបង្រៀន<br>- អានមេរៀនទាំងមូល<br>- ថតចម្លងសន្លឹកកិច្ចការ ផ្ទាំងរូបភាព និងរូបភាព។ |
|  | សម្ភារៈ ធនធានដែលចាំបាច់<br>- សន្លឹកកិច្ចការ ២.១.១៖ ប្រវត្តិរបស់ប្រាក់<br>- ផ្ទាំងរូបភាព ២.១.២៖ ប្រវត្តិរបស់ប្រាក់នៅលើពិភពលោក<br>- រូបភាព ២.១.៣៖ រូបិយប័ណ្ណអាស៊ាន<br>- សន្លឹកកិច្ចការ ២.១.៤៖ រូបិយប័ណ្ណនៅក្នុងប្រទេសនៃតំបន់អាស៊ាន<br>- ឯកសារចែក ២.១.៥៖ រូបិយប័ណ្ណនៅក្នុងប្រទេសនៃតំបន់អាស៊ាន – ចម្លើយ<br>- ក្រដាស ប៊ិកពណ៌ និងប៊ិក។ |
|  | លទ្ធផលសិក្សា៖<br>បន្ទាប់ពីបញ្ចប់មេរៀននេះ សិស្សនឹងអាច៖<br>- ពន្យល់ពីការវិវត្តរបស់ប្រាក់នៅក្នុងប្រវត្តិសាស្ត្រ។<br>- រាប់ឈ្មោះរូបិយប័ណ្ណរបស់ប្រទេសនៅតំបន់អាស៊ាន។<br>- ប្រៀបធៀបអត្រាប្តូរប្រាក់រៀលទៅនឹងរូបិយប័ណ្ណផ្សេងទៀត។ |

### សេចក្តីផ្តើម ( ៥នាទី )

គ្រូស្វាគមន៍សិស្ស៖ សួស្តីប្អូនៗទាំងអស់គ្នា មុននឹងយើងចាប់ផ្តើមមេរៀនថ្មី គ្រូចង់ឱ្យប្អូនរំឭកប្រាប់អំពីមេរៀនមុន។ តើអ្នកណាអាចប្រាប់អំពីអ្វីដែលបានរៀន? ត្រូវចាំថា យើងត្រូវអនុវត្តបទប្បញ្ញត្តិម្រាមដៃទាំងប្រាំក្នុងថ្នាក់។

### សកម្មភាពសំខាន់ទី១៖ ប្រវត្តិរបស់ប្រាក់នៅលើពិភពលោក ( ២០នាទី )

គ្រូណែនាំមេរៀនថ្មីដែលមានចំណងជើងថា ប្រវត្តិរបស់ប្រាក់នៅលើពិភពលោក។ គាត់សួរសិស្ស៖ តើប្អូនៗធ្លាប់ឆ្ងល់ដែរទេថា តើមនុស្សចាប់ផ្តើមប្រើប្រាស់ប្រាក់ ឬលុយនៅពេលណា និងដោយរបៀបណា? ហើយតើមនុស្សធ្វើជំនួញដោយរបៀបណា? តើគេយកវត្ថុអ្វីមកដោះដូរកាលពីរាប់ពាន់ឆ្នាំមុន? គ្រូពន្យល់ថា ពួកគេនឹងឈ្វេងយល់ពីគំនិតនេះជាមួយគ្នា។

គ្រូសុំសិស្សធ្វើការជាដៃគូ បន្ទាប់មកចែកសន្លឹកកិច្ចការ ២.១.១៖ ប្រវត្តិរបស់ប្រាក់ (មួយសន្លឹកសម្រាប់ដៃគូនីមួយៗ)។ ដៃគូនីមួយៗត្រូវអានការណែនាំដោយយកចិត្តទុកដាក់ ហើយប្រសិនបើពួកគេត្រូវការការពន្យល់ គ្រូនឹងផ្តល់ការណែនាំបន្ថែម។ ពេលសិស្សបានបញ្ចប់កិច្ចការគ្រប់គ្នាហើយ ពួកគេមានពេល៣នាទី ដើម្បីពិភាក្សាជាមួយដៃគូផ្សេងទៀត ហើយពន្យល់ពីមូលហេតុ។

គ្រូបង្ហាញផ្ទាំងរូបភាព និងឯកសារចែក ២.១.២៖ ប្រវត្តិរបស់ប្រាក់នៅលើពិភពលោក និងសួរសំណួរ។ ដំបូងសិស្សម្នាក់ៗគិតអំពីចម្លើយដែលពួកគេអាចឆ្លើយតបបាន ហើយចែករំលែកគំនិតជាមួយដៃគូ។ ជាចុងក្រោយ គ្រូឱ្យសិស្សខ្លះប្រាប់ពីគំនិតរបស់ពួកគេទៅសិស្សទាំងអស់។

- តាមគំនិតរបស់ប្អូន តើមនុស្សសម័យមុន ប្រើអ្វីដើម្បីដោះដូរ?
- តើការរស់នៅរបស់មនុស្សក្នុងសម័យនោះមានលក្ខណៈបែបណា?
- ហេតុអ្វីបានជាគេបង្កើតក្រដាសប្រាក់?
- តើប្អូនសម្គាល់ឃើញពីភាពខុសគ្នាអ្វីខ្លះរវាងជីវិតសព្វថ្ងៃ និងការរស់នៅកាលពី៧០០០ឆ្នាំមុន?




គ្រូសម្របសម្រួលចម្លើយសិស្ស និងបញ្ជាក់បន្ថែមពីប្រវត្តិប្រាក់នៅលើពិភពលោកដោយប្រើគន្លឹះចំណេះដឹងសម្រាប់គ្រូនៅខាងក្រោម៖

**គន្លឹះចំណេះដឹងសម្រាប់គ្រូ៖** នៅ៥០០០ឆ្នាំ មុនគ.ស ពេលនោះមនុស្សជាអ្នកបរបាញ់ ឬកសិករ ការដោះដូរជាទំនិញដំណើរការបានល្អ។ កសិករអាចយកស្រូវដូរយកបន្លែ ឬអ្នកបរបាញ់អាចយកសាច់ដូរយកស្រូវ។ ឧទាហរណ៍ ប្រសិនបើអ្នកមានមាន់មួយក្បាល អ្នកអាចដូរបានអង្ករពីរបាវ។ នៅពេលដែលជីវិតកាន់តែស្មុគស្មាញ ការដោះដូរជាទំនិញក៏មានភាពស្មុគស្មាញផងដែរ។

ការដោះដូរជាទំនិញបាននាំឱ្យមានការភាន់ច្រឡំ ហើយមនុស្សត្រូវការវិធីល្អប្រសើរជាងមុនដើម្បីធ្វើអាជីវកម្ម។ ក្រោយមក នៅ៦០០ឆ្នាំមុនគ.ស ពួកគេបានបង្កើតប្រាក់ដោយប្រើលោហៈផ្សេងៗ។ នៅពេលដែលពួកគេមានអារម្មណ៍ថា លោហៈមានទម្ងន់ធ្ងន់ពេក ពួកគេបានសម្រេចចិត្តប្រើលុយក្រដាស ដែលនៅទីបំផុតបានវិវត្តទៅជាប្រាក់នាពេលបច្ចុប្បន្ន។ នៅ១០០ឆ្នាំ មុនគ.ស. ប្រទេសចិនបានបង្កើតលុយក្រដាសដំបូងគេ។

នៅឆ្នាំ១៧៩២ ប្រាក់ដុល្លារបានក្លាយជារូបិយប័ណ្ណផ្លូវការរបស់សហរដ្ឋអាមេរិក។

នៅឆ្នាំ១៩៤៩ គំនិតនៃកាតឥណទានត្រូវបានបង្កើតឡើង។ ធនាគារបានណែនាំប្រើកាតឥណទានដល់អតិថិជនរបស់ពួកគេនៅឆ្នាំ១៩៥៨។

នៅឆ្នាំ១៩៥៤ នៅពេលទទួលបានឯករាជ្យពេញលេញពីប្រទេសបារាំង ព្រះបាទសីហនុ បានបោះពុម្ពរូបិយប័ណ្ណជាតិដំបូង គឺប្រាក់រៀល នៅក្នុងធនាគារជាតិនៃកម្ពុជា។ ធនាគារកម្ពុជាពាណិជ្ជ គឺជាធនាគារដំបូងគេបង្អស់ដែលត្រូវបានបង្កើតឡើងក្នុងឆ្នាំ១៩៩១។ សព្វថ្ងៃនេះ មានធនាគារពាណិជ្ជចំនួន៥៩ ដែលកំពុងប្រតិបត្តិការនៅទូទាំងប្រទេសកម្ពុជា។

នៅក្នុងប្រព័ន្ធធនាគារ អ្នកអាចចូលប្រើសេវាកម្មផ្សេងៗដូចជា សន្សំ ឬដាក់ប្រាក់ កម្ចី និងផ្ទេរប្រាក់។ ចាប់តាំងពីឆ្នាំ១៩៩៣មក ធនាគារ និងស្ថាប័នហិរញ្ញវត្ថុបានចាប់ផ្តើមដំឡើងម៉ាស៊ីនស្វ័យប្រវត្តិ (អេធីអឹម) បន្ថែមលើសេវាទូទាត់តាមអេឡិចត្រូនិក។

ជាមួយនឹងការអភិវឌ្ឍអ៊ីនធឺណែត ប្រាក់អេឡិចត្រូនិចបានបង្ហាញខ្លួន។ ប្រាក់អេឡិចត្រូនិកអាចប្តូរជាក្រដាសប្រាក់ ហើយត្រូវបានគ្រប់គ្រងនៅក្នុងប្រព័ន្ធធនាគារ។ ប៉ុន្តែក៏មានរូបិយប័ណ្ណគ្រីបតូ ដែលត្រូវបានចេញជាឯកជន មិនស្ថិតក្រោមការគ្រប់គ្រងដោយរដ្ឋាភិបាល។ ឧទាហរណ៍ bitcoin គឺជារូបិយប័ណ្ណឌីជីថលដែលដំណើរការដោយមិនមានការគ្រប់គ្រងកណ្តាល ឬការត្រួតពិនិត្យរបស់ធនាគារ ឬរដ្ឋាភិបាល។ ការទូទាត់ប្រើរូបិយប័ណ្ណនិម្មិតជំនួសឱ្យរូបិយប័ណ្ណរូបវន្ត។

គ្រូអាចប្រាប់សិស្សអំពីប្រវត្តិរូបិយប័ណ្ណនៅកម្ពុជា។ ប្រាក់រៀលត្រូវបានបោះពុម្ពនៅឆ្នាំ១៩៥៤ នៅក្នុងធនាគារជាតិនៃកម្ពុជា។ ការដំឡើងម៉ាស៊ីនអេធីអឹមដំបូងគឺនៅឆ្នាំ១៩៩៣។

## សកម្មភាពសំខាន់ទី២៖ រូបិយប័ណ្ណនៅក្នុងប្រទេសនៃតំបន់អាស៊ាន (២០នាទី)

គ្រប់គ្នាបានដឹងរួចមកហើយថា កម្ពុជាជាប្រទេសសមាជិករបស់អាស៊ាន (សមាគមប្រជាជាតិអាស៊ីអាគ្នេយ៍)។ វាគួរឱ្យចាប់អារម្មណ៍ដើម្បីដឹងថា រូបិយប័ណ្ណនៃប្រទេសជិតខាងយើងមានអ្វីខ្លះ។ ប្រទេសអាស៊ានជាគោលដៅទេសចរណ៍ពេញនិយម និងទាក់ទាញភ្ញៀវទេសចររាប់លាននាក់ក្នុងមួយឆ្នាំៗ។ ការស្គាល់រូបិយប័ណ្ណនិងអត្រាប្តូរប្រាក់ក្នុងតំបន់អាស៊ានអាចឱ្យអ្នកធ្វើដំណើរសម្រេចចិត្តបានច្បាស់លាស់ ក្នុងការរៀបចំថវិកា និងការគ្រប់គ្រងការចំណាយនៅពេលធ្វើដំណើរ។

| ប្រទេស | សម្រាប់ ៤១០០រៀល អ្នកអាចទទួលបាន | |
|---|---|---|
| ថៃ | 35 | បាត |
| ឡាវ | 20,613 | គីប |
| ឥណ្ឌូនេស៊ី | 15,543 | រ៉ូពី |
| ម៉ាឡេស៊ី | 4.66 | រីងហ្គីត |
| ប្រ៊ុយណេ | 1.33 | ដុល្លារប្រ៊ុយណេ |
| សិង្ហបុរី | 1.34 | ដុល្លារសិង្ហបុរី |
| វៀតណាម | 24,260 | ដុង |
| មីយ៉ាន់ម៉ា | 2,102 | ក្យាត |
| ហ្វីលីពីន | 55.48 | ប៉េសូ |

គ្រូបែងចែកសិស្សជាក្រុម ដែលមានសមាជិក៥នាក់ បន្ទាប់មកចែកសន្លឹកកិច្ចការ ២.១.៤៖ ឈ្មោះរូបិយប័ណ្ណនៅក្នុងប្រទេសនៃតំបន់អាស៊ាន សន្លឹកទទេ។ ក្រុមនីមួយៗនឹងមានពេល៧នាទីដើម្បីសរសេរឈ្មោះប្រទេស និងរូបិយប័ណ្ណនៅជាប់នឹងទង់ជាតិតំណាង។ នៅពេលដែលក្រុមនីមួយៗបានបញ្ចប់ភារកិច្ចរបស់ខ្លួន គ្រូចែកឯកសារ ២.១.៥៖ ឈ្មោះរូបិយប័ណ្ណនៅក្នុងប្រទេសនៃតំបន់អាស៊ានដែលមានចម្លើយដល់សិស្សទាំងអស់ក្នុងក្រុម បន្ទាប់មកឆ្លុះបញ្ចាំងពីឈ្មោះរូបិយប័ណ្ណជាមួយសិស្សទាំងអស់។

គ្រូសួរសំណួរដល់សិស្សទាំងអស់៖ តើប្អូនអាចប្រាប់បានទេថា អត្រាប្តូរប្រាក់មានន័យដូចម្តេច?

គ្រូឱ្យសិស្សធ្វើការងារជាមួយដៃគូក្នុងរយៈពេល៥នាទី ហើយចែកបណ្ណVIPP (បណ្ណមានទំហំមួយភាគបួននៃក្រដាស A4) ដល់គូនីមួយៗ។ គ្រូប្រើរូបភាព ២.១.៣ និមិត្តសញ្ញារូបិយបណ្ណអាស៊ាន និងសុំឱ្យដៃគូទាំងអស់គិតអំពីអត្រាប្តូរប្រាក់ដែលពួកគេអាចដឹង។ គ្រូផ្តល់ឧទាហរណ៍គំរូ ៤ ១០០រៀល = ៣៥បាត បន្ទាប់មកដៃគូនីមួយៗគិតអំពីអត្រាប្តូរប្រាក់ផ្សេងទៀតជាមួយប្រាក់រៀល (៤ ១០០រៀល)។ នៅពេលដែលដៃគូទាំងអស់បានបញ្ចប់។ គ្រូសុំឱ្យដៃគូនីមួយៗចែករំលែកចម្លើយរបស់ពួកគេស្តីពីអត្រាប្តូរប្រាក់។ គ្រូបង្ហាញតារាងអត្រាប្តូរប្រាក់នៅលើក្តារខៀនរបស់ប្រទេសជាសមាជិកអាស៊ានជាមួយនឹងអត្រាប្តូរប្រាក់រៀល (៤ ១០០៛) ដោយប្រើគេហទំព័រធនាគារអេស៊ីលីដា។

គ្រូសួរសំណួរដល់សិស្សទាំងអស់។

១- តើអត្រាប្តូរប្រាក់ប្រទេសណាដែលមានតម្លៃទាបជាងគេបំផុត បើប្រៀបធៀបជាមួយលុយរៀល?

២- សូមរៀបរាប់អត្រាប្តូរប្រាក់ថ្លៃជាងគេបំផុតឱ្យបានបី បើប្រៀបធៀបជាមួយលុយរៀល? ហេតុអ្វីបានជាវាមានតម្លៃថ្លៃជាងគេ?

៣- តើការសិក្សាពីអត្រាប្តូរប្រាក់របស់ប្រទេសជាសមាជិកអាស៊ានផ្តល់ប្រយោជន៍អ្វីខ្លះដល់ប្រទេសកម្ពុជា?

គ្រូអាចប្រើគន្លឹះចំណេះដឹងសម្រាប់គ្រូនៅខាងក្រោម ដើម្បីជួយសម្របសម្រួលចម្លើយសិស្ស។

## ការឆ្លុះបញ្ចាំង (៣នាទី)

ដើម្បីបញ្ចប់មេរៀននេះ គ្រូសួរថា តើប្អូនបានរៀនសូត្រអ្វីខ្លះនៅថ្ងៃនេះ? តើប្អូនចូលចិត្តអ្វីខ្លះអំពីមេរៀនថ្ងៃនេះ? តើប្អូនទទួលបានចំណេះដឹងអ្វីខ្លះពីមេរៀននេះ ពេលត្រឡប់ទៅផ្ទះវិញ?

### គន្លឹះចំណេះដឹងសម្រាប់គ្រូ

**និយមន័យ៖** អត្រាប្តូរប្រាក់គឺជាតម្លៃនៃរូបិយប័ណ្ណរបស់ប្រទេសមួយធៀបនឹងរូបិយប័ណ្ណរបស់ប្រទេសមួយទៀត។

**ការពណ៌នា៖** អត្រាប្តូរប្រាក់អាចថេរឬអណ្តែត។ អត្រាប្តូរប្រាក់ថេរត្រូវបានសម្រេចដោយធនាគារកណ្តាលនៃប្រទេសមួយ ចំណែកឯអត្រាប្តូរប្រាក់អណ្តែតត្រូវបានសម្រេចដោយយន្តការនៃតម្រូវការទីផ្សារ និងការផ្គត់ផ្គង់។

មូលហេតុដែលត្រូវសិក្សាអំពីអត្រាប្តូរប្រាក់របស់អាស៊ាន៖

១- **ការយល់ដឹងអំពីសេដ្ឋកិច្ច៖** អាស៊ានគឺជាតំបន់សេដ្ឋកិច្ចដ៏រស់រវើក ដែលមានផលិតផលសរុបក្នុងស្រុករួមគ្នាជាង៣ពាន់ ពាន់លានដុល្លារ។ ការសិក្សាអំពីរូបិយប័ណ្ណនៃប្រទេសអាស៊ានជួយឱ្យយើងយល់ដឹងអំពីសេដ្ឋកិច្ច សក្តានុពលពាណិជ្ជកម្ម និងឱកាសវិនិយោគ។

២- **ការធ្វើដំណើរ និងទេសចរណ៍៖** ប្រទេសអាស៊ានគឺជាគោលដៅទេសចរណ៍ដ៏ពេញនិយម ដែលទាក់ទាញអ្នកទស្សនារាប់លាននាក់ក្នុងមួយឆ្នាំៗ។ ការស្គាល់ពីរូបិយប័ណ្ណក្នុងស្រុកនឹងអនុញ្ញាតឱ្យអ្នកធ្វើដំណើរធ្វើការសម្រេចចិត្តប្រកបដោយការយល់ដឹងទាក់ទងនឹងអត្រាប្តូរប្រាក់ ការរៀបចំថវិកា និងការគ្រប់គ្រងការចំណាយនៅពេលធ្វើដំណើរក្នុងតំបន់។

៣- **ធុរកិច្ច និងពាណិជ្ជកម្ម៖** ប្រទេសអាស៊ានមានទំនាក់ទំនងពាណិជ្ជកម្មដ៏រឹងមាំជាមួយគ្នា និងជាមួយពិភពលោក។ ការយល់ដឹងអំពីរូបិយប័ណ្ណនៃប្រទេសសមាជិកអាស៊ានគឺចាំបាច់សម្រាប់អាជីវកម្មដែលចូលរួមក្នុងពាណិជ្ជកម្មឆ្លងដែន សកម្មភាពនាំចូល-នាំចេញ និងយុទ្ធសាស្ត្រការពាររូបិយប័ណ្ណ។

៤- **ឱកាសវិនិយោគ៖** អាស៊ានផ្តល់ឱកាសវិនិយោគចម្រុះលើវិស័យផ្សេងៗ។ ការមានចំណេះដឹងអំពីរូបិយប័ណ្ណនៃប្រទេសអាស៊ានអនុញ្ញាតឱ្យអ្នកវិនិយោគអាចវាយតម្លៃហានិភ័យ និងសក្តានុពលត្រឡប់មកវិញ ទាក់ទងនឹងការវិនិយោគនៅក្នុងទីផ្សារទាំងនេះ។

៥- **ការឱ្យតម្លៃវប្បធម៌៖** ការសិក្សាអំពីរូបិយប័ណ្ណនៃប្រទេសអាស៊ានក៏ផ្តល់នូវការយល់ដឹងអំពីបេតិកភណ្ឌវប្បធម៌ដ៏សម្បូរបែបរបស់ពួកគេផងដែរ។ ការរចនារូបិយប័ណ្ណជាញឹកញាប់មានតួអង្គប្រវត្តិសាស្ត្រ សញ្ញាសម្គាល់ និងនិមិត្តសញ្ញាដែលតំណាងឱ្យអត្តសញ្ញាណវប្បធម៌ដោយឡែកៗតែមួយគត់នៃជាតិនីមួយៗ។

៦- **សមាហរណកម្មក្នុងតំបន់៖** អាស៊ានប្ដេជ្ញាជំរុញការធ្វើសមាហរណកម្ម និងកិច្ចសហប្រតិបត្តិការក្នុងតំបន់។ ការយល់ដឹងអំពីរូបិយប័ណ្ណរបស់រដ្ឋសមាជិកអាស៊ាន ជំរុញឱ្យមានការឯកភាព និងសាមគ្គីភាពក្នុងចំណោមប្រជាជាតិចម្រុះ ជំរុញការជឿទុកចិត្តគ្នា និងការយោគយល់គ្នាទៅវិញទៅមក។

សរុបសេចក្ដីមក ការសិក្សាអំពីរូបិយប័ណ្ណនៃប្រទេសអាស៊ានមានសារៈសំខាន់សម្រាប់ហេតុផលសេដ្ឋកិច្ច ការធ្វើដំណើរ អាជីវកម្ម ការវិនិយោគ វប្បធម៌ និងហេតុផលសមាហរណកម្មក្នុងតំបន់។ វាអនុញ្ញាតឱ្យបុគ្គលម្នាក់ៗមានការយល់ដឹងទូលំទូលាយអំពីតំបន់ និងជួយសម្រួលដល់ការធ្វើសេចក្ដីសម្រេចចិត្តប្រកបដោយការយល់ដឹងនៅក្នុងទិដ្ឋភាពផ្សេងៗនៃជីវិត។

## សន្លឹកកិច្ចការ ២.១.១៖ ប្រវត្តិរបស់ប្រាក់

**ការណែនាំ៖** សូមក្រឡេកមើលបញ្ជីនៃការវិវត្តជាប្រវត្តិសាស្ត្ររបស់ប្រាក់នៅលើពិភពលោក និងឆ្នាំនានា។ សូមបំពេញលេខឆ្នាំដែលប្អូនគិតថា ត្រូវទៅនឹងការពន្យល់អំពីការវិវត្តនៃប្រវត្តិរបស់ប្រាក់។

**ចំណាំ៖** ប្អូនអាចបំពេញឆ្នាំណាមួយបានតែម្ដងប៉ុណ្ណោះ។

| | | | | | | |
|---|---|---|---|---|---|---|
| ៦០០ឆ្នាំមុន គ.ស. | ១០០ឆ្នាំមុន គ.ស. | ឆ្នាំ ១៧៩២ | ឆ្នាំ ១៩៤៩ | ឆ្នាំ ១៩៦៥ | ឆ្នាំ ២០០៩ | ៥០០០ឆ្នាំ មុនគ.ស. |

| ឆ្នាំ | ការវិវត្តនៃប្រវត្តិរបស់ប្រាក់នៅលើពិភពលោក |
|---|---|
| …………… | មនុស្សបានប្រើការដោះដូរជាទំនិញដើម្បីផ្លាស់ប្ដូរទំនិញគ្នា។ |
| ……………. | ប្រទេសចិនបានបង្កើតក្រដាសប្រាក់ដំបូង។ |
| ……………. | ទូអេធីអឹមដំបូងគេ |
| ……………. | កាតឥណទានដំបូងគេ |
| ……………. | ការលេចចេញនូវប្រាក់អេឡិចត្រូនិច ( bitcoin ដំបូងគេ ) |
| …………..…. | ការប្រើប្រាស់លោហធាតុ និងការលេចចេញនូវកាក់ដំបូង |
| …………..…. | ការបង្កើតប្រាក់ដុល្លារអាមេរិក |

ផ្ទាំងរូបភាព ២.១.២៖ ប្រវត្តិរបស់ប្រាក់នៅលើពិភពលោក



រូបភាព ២.១.៣៖ រូបិយប័ណ្ណអាស៊ាន



| | |
|---|---|
| ប្រ៊ុយណេ | កម្ពុជា |
| ឡាវ | ឥណ្ឌូនេស៊ី |
| មីយ៉ាន់ម៉ា | ថៃ |
| សិង្ហបុរី | វៀតណាម |
| ម៉ាឡេស៊ី | ហ្វីលីពីន |

| | |
|---|---|
| បាត | រៀល |
| គីប | រ៉ូពី |
| រីងហ្គីត | ដុល្លារ<br>ប្រ៊ុយណេ |
| ដុល្លារ<br>សិង្ហបុរី | ដុង |
| ក្យាត | ប៉េសូ |

| | |
|---|---|
| Rp | ₫ |
| RM | S$ |
| ₱ | ฿ |
| B$ | ៛ |
| ₭ | K |

## សន្លឹកកិច្ចការ ២.១.៤៖ រូបិយប័ណ្ណនៅក្នុងប្រទេសនៃតំបន់អាស៊ាន

# រូបិយប័ណ្ណនៅក្នុងប្រទេសនៃតំបន់អាស៊ាន

**ការណែនាំ៖** សិស្សនឹងសរសេរឈ្មោះប្រទេស រូបិយប័ណ្ណ និងនិមិត្តសញ្ញារូបិយប័ណ្ណនៅក្បែរទង់ជាតិ។ ខាងក្រោមនេះ ប្អូននឹងឃើញនិមិត្តសញ្ញារូបិយប័ណ្ណនៃប្រទេសនៅតំបន់អាស៊ាន។

₫ RM S$ ₱ ៛ Rp ฿ ₭ K B$



ឈ្មោះប្រទេស៖ ____________________
ឈ្មោះរូបិយប័ណ្ណ៖ ____________________
និមិត្តសញ្ញារូបិយប័ណ្ណ៖ ____________________



ឈ្មោះប្រទេស៖ ____________________
ឈ្មោះរូបិយប័ណ្ណ៖ ____________________
និមិត្តសញ្ញារូបិយប័ណ្ណ៖ ____________________



ឈ្មោះប្រទេស៖ ____________________
ឈ្មោះរូបិយប័ណ្ណ៖ ____________________
និមិត្តសញ្ញារូបិយប័ណ្ណ៖ ____________________



ឈ្មោះប្រទេស៖ ____________________
ឈ្មោះរូបិយប័ណ្ណ៖ ____________________
និមិត្តសញ្ញារូបិយប័ណ្ណ៖ ____________________



ឈ្មោះប្រទេស៖ ____________________
ឈ្មោះរូបិយប័ណ្ណ៖ ____________________
និមិត្តសញ្ញារូបិយប័ណ្ណ៖ ____________________



ឈ្មោះប្រទេស៖ ____________________
ឈ្មោះរូបិយប័ណ្ណ៖ ____________________
និមិត្តសញ្ញារូបិយប័ណ្ណ៖ ____________________



ឈ្មោះប្រទេស៖ ____________________
ឈ្មោះរូបិយប័ណ្ណ៖ ____________________
និមិត្តសញ្ញារូបិយប័ណ្ណ៖ ____________________



ឈ្មោះប្រទេស៖ ____________________
ឈ្មោះរូបិយប័ណ្ណ៖ ____________________
និមិត្តសញ្ញារូបិយប័ណ្ណ៖ ____________________



ឈ្មោះប្រទេស៖ ____________________
ឈ្មោះរូបិយប័ណ្ណ៖ ____________________
និមិត្តសញ្ញារូបិយប័ណ្ណ៖ ____________________



ឈ្មោះប្រទេស៖ ____________________
ឈ្មោះរូបិយប័ណ្ណ៖ ____________________
និមិត្តសញ្ញារូបិយប័ណ្ណ៖ ____________________

# រូបិយប័ណ្ណនៅក្នុងប្រទេសនៃតំបន់អាស៊ាន

**ការណែនាំ៖** គ្រូអាចប្រើសន្លឹកនេះដើម្បីឆ្លើយ។



ឈ្មោះប្រទេស៖ ហ្វីលីពីន
ឈ្មោះរូបិយប័ណ្ណ៖ ប៉េសូ
និមិត្តសញ្ញារូបិយប័ណ្ណ៖ ₱



ឈ្មោះប្រទេស៖ ឡាវ
ឈ្មោះរូបិយប័ណ្ណ៖ គីប
និមិត្តសញ្ញារូបិយប័ណ្ណ៖ ₭



ឈ្មោះប្រទេស៖ កម្ពុជា
ឈ្មោះរូបិយប័ណ្ណ៖ ប្រាក់រៀល
និមិត្តសញ្ញារូបិយប័ណ្ណ៖ ៛



ឈ្មោះប្រទេស៖ ប្រ៊ុយណេ
ឈ្មោះរូបិយប័ណ្ណ៖ ដុល្លារប្រ៊ុយណេ
និមិត្តសញ្ញារូបិយប័ណ្ណ៖ B$



ឈ្មោះប្រទេស៖ ថៃ
ឈ្មោះរូបិយប័ណ្ណ៖ បាតថៃ
និមិត្តសញ្ញារូបិយប័ណ្ណ៖ ฿



ឈ្មោះប្រទេស៖ សិង្ហបុរី
ឈ្មោះរូបិយប័ណ្ណ៖ ដុល្លារសិង្ហបុរី
និមិត្តសញ្ញារូបិយប័ណ្ណ៖S$



ឈ្មោះប្រទេស៖ មីយ៉ាន់ម៉ា
ឈ្មោះរូបិយប័ណ្ណ៖ ក្យាត
និមិត្តសញ្ញារូបិយប័ណ្ណ៖ K



Cឈ្មោះប្រទេស៖ វៀតណាម
ឈ្មោះរូបិយប័ណ្ណ៖ ដុង
និមិត្តសញ្ញារូបិយប័ណ្ណ៖ ₫



ឈ្មោះប្រទេស៖ ឥណ្ឌូនេស៊ី
ឈ្មោះរូបិយប័ណ្ណ៖ រូពីឥណ្ឌូនេស៊ី
និមិត្តសញ្ញារូបិយប័ណ្ណ៖ Rp



ឈ្មោះប្រទេស៖ ម៉ាឡេស៊ី
ឈ្មោះរូបិយប័ណ្ណ៖ រីងហ្គីត
និមិត្តសញ្ញារូបិយប័ណ្ណ៖ RM

# មេរៀនទី២ ទម្លាប់សន្សំ

| | |
|---|---|
|  | រយៈពេល៖ ៤៥នាទី |
|  | **ការត្រៀមខ្លួនរបស់គ្រូ មុនចូលបង្រៀន**<br>- អានមេរៀនទាំងមូល<br>- ថតចម្លងឯកសារចែក ឬសន្លឹកកិច្ចការ។ |
|  | **សម្ភារៈ ធនធានដែលចាំបាច់**<br>- រូបភាព ២.២.១៖ រូបសញ្ញាកែច្នៃឡើងវិញ<br>- ឯកសារចែក ២.២.២៖ គោលការណ៍ ៣Rs (កាត់បន្ថយ ប្រើប្រាស់ឡើងវិញ កែច្នៃឡើងវិញ)<br>- សន្លឹកកិច្ចការ ២.២.៣៖ គោលការណ៍ ៣Rs<br>- សន្លឹកកិច្ចការ ២.២.៤៖ បញ្ជីទម្លាប់នៃការសន្សំរបស់ខ្ញុំ។ |
|  | **លទ្ធផលសិក្សា៖**<br>បន្ទាប់ពីបញ្ចប់មេរៀននេះ សិស្សនឹងអាច៖<br>- សង្ខេបពីសារៈសំខាន់នៃការសន្សំធនធាន និងអំពើល្អ សម្រាប់ការគ្រប់គ្រងបរិស្ថានផ្ទាល់ខ្លួន<br>- បំពេញតារាងសន្សំប្រចាំថ្ងៃក្នុងថ្នាក់រៀន និងនៅផ្ទះ។ |

## សេចក្តីផ្តើម

គ្រូស្វាគមន៍សិស្ស និងគ្រប់គ្រងថ្នាក់រៀនឱ្យបានល្អ ហើយសួរពួកគេអំពីមេរៀនមុន។ តើប្អូនបានរៀនអ្វីខ្លះ? សូមចាំថា យើងត្រូវអនុវត្តបទប្បញ្ញត្តិម្រាមដៃទាំងប្រាំនៅក្នុងថ្នាក់យើង! បន្ទាប់មក គ្រូណែនាំមេរៀនថ្មីដល់សិស្ស។

## សកម្មភាពសំខាន់ទី១៖ ការសន្សំធនធាន (៣០នាទី)



គ្រូបង្ហាញ **ឯកសារចែកទី២.២.១៖** រូបសញ្ញាកែច្នៃឡើងវិញ ដល់សិស្សទាំងអស់ ហើយសួរសិស្សនូវសំណួរខាងក្រោម៖

- តើមានអ្នកណាស្គាល់និមិត្តសញ្ញានេះដែរឬទេ?
- តើវាតំណាងឱ្យអ្វី? តើវាមានន័យដូចម្តេច?

គ្រូពន្យល់ថាវាជានិមិត្តសញ្ញាកែច្នៃឡើងវិញដែលពាក់ព័ន្ធនឹងការកែច្នៃនិងបំប្លែងកាកសំណល់ទៅជាផលិតផលថ្មី។ ការកែច្នៃឡើងវិញជួយអភិរក្សធនធាន កាត់បន្ថយការប្រើប្រាស់ថាមពល និងកាត់បន្ថយការបំពុល។ គ្រូបន្ថែមគំរូពីរទៀត (កាត់បន្ថយ និងប្រើប្រាស់ឡើងវិញ) ដែលជាគោលការណ៍គ្រឹះនៃការគ្រប់គ្រងសំណល់ប្រកបដោយនិរន្តរភាព។ តស់ យើងឈ្វេងយល់ទាំងអស់គ្នា!

គ្រូបែងចែកសិស្សជាបីក្រុម ហើយចែក **ឯកសារទី ២.២.២៖** គោលការណ៍៣Rs (កាត់បន្ថយ ប្រើប្រាស់ឡើងវិញ កែច្នៃឡើងវិញ) ដល់ក្រុមនីមួយៗ។ ក្រុមមានពេល៥នាទី ដើម្បីអានបន្ទាប់មកគ្រូផ្តល់ **ឯកសារចែកទី**

**២.២.៣៖** លំហាត់ទាក់ទងនឹងគោលការណ៍ ៣Rs ដល់ក្រុមនីមួយៗដើម្បីធ្វើ។ ក្រុមនីមួយៗនឹងធ្វើការងារលើគោលការណ៍មួយក្នុងចំណោមគោលការណ៍ទាំងបី។ គ្រូពន្យល់អំពីលំហាត់ដោយប្រើឧទាហរណ៍ដែលបានផ្តល់ជូនក្នុងតារាងកែច្នៃឡើងវិញខាងក្រោមឬឯកសារចែកទី២.២.៣៖នៅពេលដែលក្រុមនីមួយៗបញ្ចប់កិច្ចការ គ្រូហៅប្រធានក្រុម ឬសមាជិកក្រុមឱ្យចែករំលែកគំនិតរបស់ពួកគេអំពីសម្ភារៈ ឬផលិតផលដែលពួកគេបានជ្រើសរើសដើម្បីកាត់បន្ថយ ប្រើប្រាស់ឡើងវិញ និងកែច្នៃឡើងវិញ ហើយបន្ទាប់មកពន្យល់ពីមូលហេតុផល និងអត្ថប្រយោជន៍។ គ្រូជួយសរុបគំនិតរបស់សិស្ស។

គ្រូពន្យល់ថា សិស្សអាចសន្សំប្រាក់ និងធនធានដោយអនុវត្តគោលការណ៍ ៣Rs (កាត់បន្ថយ ប្រើប្រាស់ឡើងវិញ និងកែច្នៃឡើងវិញ) ក្នុងជីវិតប្រចាំថ្ងៃ។ ជាងនេះទៅទៀត ការសន្សំសំចៃធនធានគឺជាអំពើល្អមួយដែលងាយស្រួលធ្វើ។ ប៉ុន្តែដើម្បីក្លាយជាពលរដ្ឋល្អ និងមនុស្សល្អ ប្អូនក៏អាចប្រព្រឹត្ត និងធ្វើអំពើល្អតាមវិធីផ្សេងៗទៀតបានដែរ។

## សកម្មភាពសំខាន់ទី ២៖ បញ្ជីទម្លាប់នៃការសន្សំ (១៥នាទី)

គ្រូពន្យល់ថា ទម្លាប់សន្សំមានបីប្រភេទ រួមមាន ១) ការសន្សំអំពើល្អ ២) ការសន្សំធនធាន និង ៣) ការសន្សំប្រាក់។ ការសន្សំអំពើល្អ ជួយរក្សាអំពើសប្បុរស និងក្តីមេត្តា។ វាអនុញ្ញាតឱ្យយើងមានទុនបម្រុងជាវិជ្ជមាន និងសុច្ឆន្ទៈដែលអាចចែករំលែកនៅពេលដែលយើងត្រូវការវា។

តើប្អូនធ្លាប់ធ្វើអំពើល្អដែរឬទេ? ធ្វើសម្រាប់អ្នកណា? តើប្អូនអាចលើកឡើងពីសកម្មភាពអំពើល្អផ្សេងៗដែលប្អូនអាចធ្វើបានដែរឬទេ? គ្រូសរសេរចម្លើយរបស់សិស្សនៅលើក្តារខៀន។

គ្រូចែក**ឯកសារទី ២.២.៤៖** បញ្ជីទម្លាប់នៃការសន្សំដោយមានការណែនាំ។ គ្រូសុំឱ្យសិស្សអានឈ្មោះអំពីអំពើល្អ ហើយប្រៀបធៀបជាមួយចម្លើយរបស់ពួកគេនៅលើក្តារខៀន។ សិស្សអាចបន្ថែមឈ្មោះផ្សេងទៀតប្រសិនបើពួកគេចង់។ គ្រូពន្យល់ពីរបៀបធ្វើស្វ័យវាយតម្លៃ ដោយបិទរូបផ្កាយពណ៌ក្រហមត្រង់ឈ្មោះនីមួយៗប្រសិនបើបានធ្វើវាគ្រប់ពេល បិទរូបផ្កាយពណ៌ខៀវប្រសិនបើបានធ្វើខ្លះៗ និងបិទរូបផ្កាយពណ៌លឿងប្រសិនបើភ្លេចធ្វើ។ សូមធ្វើរបៀបនេះរយៈពេលមួយសប្តាហ៍។ ចូរចាំថា ត្រូវស្មោះត្រង់ជាមួយនឹងសមិទ្ធផលផ្ទាល់ខ្លួនរបស់ប្អូនៗ។




| ខ្ញុំចាំថា ខ្ញុំបាន... | ថ្ងៃទី១ | ថ្ងៃទី២ | ថ្ងៃទី៣ | ថ្ងៃទី៤ | ថ្ងៃទី៥ | ថ្ងៃទី៦ | ថ្ងៃទី៧ |
|---|---|---|---|---|---|---|---|
| ១. ការសន្សំអំពើល្អ | | | | | | | |
| ញ៉ាំអាហារក្នុងចានរបស់ខ្ញុំឱ្យអស់ | | | | | | | |
| បោះចោលសំរាមក្នុងធុង | | | | | | | |
| ប្រើពាក្យគួរសម | | | | | | | |
| គោរពច្បាប់ចរាចរណ៍ | | | | | | | |
| ប្រើប្រាស់ទ្រព្យសម្បត្តិសាធារណៈដោយប្រុងប្រយ័ត្ន | | | | | | | |
| ចែករំលែកជាមួយអ្នកដទៃ | | | | | | | |
| រៀបចំកាតាបខ្លួនឯង និងទៅសាលា [illegible] | | | | | | | |

នៅពេលសិស្សបំពេញបញ្ជីចប់ គ្រូនឹងលើកទឹកចិត្តសិស្សឱ្យកត់ត្រាទម្លាប់សន្សំរបស់ពួកគេក្នុងអំឡុងពេលពេញមួយសប្តាហ៍។ អំពើល្អមួយចំនួនដែលបានលើកឡើងក្នុងអំឡុងពេលសកម្មភាពមុនអាចត្រូវបានបន្ថែមទៅក្នុងបញ្ជីទម្លាប់នៃការសន្សំ។

ដើម្បីបញ្ចប់មេរៀននេះ គ្រូសួរថា តើពួកគេបានរៀនសូត្រអ្វីខ្លះពីសកម្មភាពនេះ ហើយតើពួកគេអាចអនុវត្តអ្វីដែលបានរៀននៅក្នុងគ្រួសារ និងក្នុងសហគមន៍របស់ពួកគេដោយរបៀបណា?

## កិច្ចការផ្ទះ

គ្រូឱ្យក្រុមនីមួយៗរចនាផ្ទាំងរូបភាពស្តីពីនិរន្តរភាពនៃការគ្រប់គ្រងសំណល់ ជាមួយនឹងគោលការណ៍ ៣R (កាត់បន្ថយ ការប្រើប្រាស់ឡើងវិញ និងកែច្នៃឡើងវិញ)។ សិស្សដាក់បញ្ចូលគំនិតរបស់ពួកគេដែលពួកគេបានចែករំលែក ដោយធ្វើការរចនាផ្ទាំងរូបភាពឱ្យទាក់ទាញ។ សិស្សអាចប្រើសម្ភារៈផ្សេងៗគ្នាដើម្បីបង្កើតផ្ទាំងរូបភាព។

### រូបភាព ២.២.១៖ កែច្នៃឡើងវិញ



### ឯកសារចែក ២.២.២៖ គោលការណ៍ ៣ R (កាត់បន្ថយ ប្រើប្រាស់ឡើងវិញ កែច្នៃឡើងវិញ)

**ការណែនាំ៖** សិស្សអានព័ត៌មានខាងក្រោមដើម្បីយល់ពីគោលការណ៍ ៣R ដែលពួកគេអាចអនុវត្តក្នុងជីវិតប្រចាំថ្ងៃរបស់ពួកគេ។

ការកាត់បន្ថយ ការប្រើប្រាស់ឡើងវិញ និងការកែច្នៃឡើងវិញ គឺជាគោលការណ៍គ្រឹះទាំងបីនៃការគ្រប់គ្រងសំណល់ប្រកបដោយនិរន្តរភាព។ ពួកវាត្រូវបានសំដៅជាទូទៅថាជា «៣Rs» ហើយមានគោលបំណងកាត់បន្ថយកាកសំណល់ អភិរក្សធនធាន និងកាត់បន្ថយផលប៉ះពាល់អវិជ្ជមានទៅលើបរិស្ថានដែលបង្កមកពីគំរូនៃការប្រើប្រាស់របស់យើង។

**១- ការកាត់បន្ថយ៖** ជំហានដំបូងគឺកាត់បន្ថយបរិមាណកាកសំណល់ដែលយើងបង្កើតឡើង ដោយគិតពីទម្លាប់ប្រើប្រាស់របស់យើង។ វាពាក់ព័ន្ធនឹងការជ្រើសរើសដោយមនសិការ ដើម្បីកាត់បន្ថយការប្រើប្រាស់ធនធាន ផលិតផល និងការវេចខ្ចប់។ ឧទាហរណ៍៖

- ការជ្រើសរើសដបទឹកដែលអាចដាក់ទឹកឡើងវិញបានជំនួសឱ្យដបប្លាស្ទិកដែលប្រើបានតែមួយដង។
- យកថង់ដាក់អីវ៉ាន់ដែលអាចប្រើឡើងវិញបានតាមខ្លួន ជំនួសឱ្យការពឹងផ្អែកលើថង់ប្លាស្ទិក។
- ថតចម្លងឯកសារតែនៅពេលចាំបាច់ និងប្រើទម្រង់ឌីជីថលនៅពេលណាដែលអាចធ្វើទៅបាន។
- ទិញជាដុំៗ ដើម្បីកាត់បន្ថយកាកសំណល់វេចខ្ចប់។ ឧ. ទិញអង្ករ២០គីឡូ ជំនួសឱ្យការទិញបរិមាណ២គីឡូក្រោមចំនួន១០ដង។ អ្នកនឹងសន្សំថង់ប្លាស្ទិចចំនួន ១០ថង់ និងកាត់បន្ថយការប្រើប្រាស់ប្លាស្ទិច។

តាមរយៈការកាត់បន្ថយការប្រើប្រាស់របស់យើង យើងអាចកាត់បន្ថយបរិមាណកាកសំណល់យ៉ាងច្រើនដែលត្រូវបានយកទៅចោលនៅកន្លែងចាក់សំរាម។

**២- ការប្រើប្រាស់ឡើងវិញ៖** ជំហានទីពីរគឺត្រូវរកវិធីប្រើប្រាស់ឡើងវិញ ជំនួសឱ្យការបោះចោល បន្ទាប់ពីប្រើបានម្តង។ វាជួយពន្យារអាយុជីវិតរបស់ផលិតផល អភិរក្សធនធាន និងកាត់បន្ថយតម្រូវការសម្រាប់ទិញថ្មី។ ឧទាហរណ៍មួយចំនួននៃការប្រើប្រាស់ឡើងវិញរួមមាន៖

- បរិច្ចាគសម្លៀកបំពាក់ សៀវភៅ ឬគ្រឿងសង្ហារិម ដល់អង្គការសប្បុរសធម៌ ឬហាងជជុះ ជំនួសឱ្យបោះចោល។
- កែច្នៃសម្ភារៈផលិតពីប្លាស្ទិកធ្វើជាសម្ភារៈប្រើប្រាស់ ឬជាធុងសម្រាប់ដាក់របស់របរផ្សេងនៅក្នុងផ្ទះ។
- ជួសជុល ឬកែច្នៃគ្រឿងអេឡិចត្រូនិច និងឧបករណ៍ប្រើប្រាស់ផ្សេងៗ ជាជាងទិញថ្មី។
- ទិញទំនិញជជុះ ឧទាហរណ៍ សម្លៀកបំពាក់ ឬចានជាដើម ជំនួសឱ្យការទិញទំនិញថ្មី។

តាមរយៈការប្រើប្រាស់របស់របរឡើងវិញ យើងកាត់បន្ថយតម្រូវការក្នុងការផលិតផលិតផលថ្មី និងកាត់បន្ថយកាកសំណល់ទាំងមូលដែលបានបង្កើត។

**៣- ការកែច្នៃឡើងវិញ៖** ជំហានទីបីគឺការកែច្នៃឡើងវិញ ដែលពាក់ព័ន្ធនឹងការកែច្នៃ និងការបំប្លែងកាកសំណល់ទៅជាផលិតផលថ្មី។ ការកែច្នៃឡើងវិញជួយអភិរក្សធនធាន កាត់បន្ថយការប្រើប្រាស់ថាមពល និងកាត់បន្ថយការបំពុលដែលទាក់ទងនឹងការទាញយកវត្ថុធាតុដើម។ ឧទាហរណ៍មួយចំនួននៃការកែច្នៃឡើងវិញរួមមាន៖

- ញែក និងដាក់វត្ថុដែលអាចកែច្នៃឡើងវិញបានដាច់ដោយឡែកពីគ្នាដូចជា ក្រដាស ប្លាស្ទិក កញ្ចក់ និងលោហៈ ហើយដាក់វាក្នុងធុងសំរាមដែលបានកំណត់។
- ទិញផលិតផលដែលផលិតពីវត្ថុធាតុកែច្នៃដូចជា ក្រដាសកែច្នៃ ឬផលិតផលប្លាស្ទិកកែច្នៃ។

តាមរយៈការកែច្នៃឡើងវិញ យើងអាចបង្វែរកាកសំណល់ចេញពីកន្លែងចាក់សំរាម និងលើកកម្ពស់សេដ្ឋកិច្ច ដែលវត្ថុធាតុដើមត្រូវបានប្រើប្រាស់ឡើងវិញ និងបំប្លែងទៅជាផលិតផលថ្មី។

វាជារឿងសំខាន់ក្នុងការកត់សម្គាល់ថា ការបញ្ចូលគោលការណ៍ ៣Rs (កាត់បន្ថយ ប្រើប្រាស់ឡើងវិញ និងកែច្នៃឡើងវិញ) ក្នុងជីវិតប្រចាំថ្ងៃរបស់យើង យើងអាចរួមចំណែកដល់អនាគតប្រកបដោយនិរន្តរភាព និងបរិស្ថានកាន់តែល្អប្រសើរ។

## សន្លឹកកិច្ចការ ២.២.៣៖ គោលការណ៍ ៣Rs

**ការណែនាំ៖** សិស្សធ្វើកិច្ចការជាក្រុម បំពេញតារាងខាងក្រោមដែលមានឧទាហរណ៍អំពីគោលការណ៍ ៣Rs (កាត់បន្ថយ ប្រើប្រាស់ឡើងវិញ កែច្នៃឡើងវិញ) ដែលត្រូវបំពេញផលិតផល ឬសម្ភារៈមួយ ហេតុផល និងអត្ថប្រយោជន៍ដើម្បីធ្វើវា។ ក្រុមនីមួយៗផ្តោតលើគោលការណ៍តែមួយប៉ុណ្ណោះ។ សូមមើលឧទាហរណ៍ដែលបានផ្តល់ឱ្យក្នុងតារាងខាងក្រោម។

| |   |   |   |
|---|---|---|---|
| **ផលិតផល ឬ សម្ភារៈ** | *ឧ. ទុយោប្លាស្ទិក* ........................................... | .................................<br>.................................<br>................................. | .................................<br>.................................<br>................................. |
| **មូលហេតុ** | *ឧ. ដើម្បីកាត់បន្ថយការបំពុល និងបង្កើតបរិស្ថានល្អ។* ............................................. | .................................<br>.................................<br>................................. | .................................<br>.................................<br>................................. |
| **អត្ថប្រយោជន៍** | *ឧ. ដើម្បីរួមចំណែកឱ្យមានសុខភាពល្អ និងធម្មជាតិស្អាត។* ........................................... | .................................<br>.................................<br>................................. | .................................<br>.................................<br>................................. |

## សន្លឹកកិច្ចការ ២.២.៤៖ បញ្ជីទម្លាប់នៃការសន្សំរបស់ខ្ញុំ

# បញ្ជីទម្លាប់សន្សំរបស់ខ្ញុំ

នៅចុងបញ្ចប់នៃថ្ងៃនីមួយៗ សូមពិនិត្យមើលបញ្ជី ថាតើប្អូនបានធ្វើអ្វីខ្លះ។

ផ្តល់ឱ្យខ្លួនឯង (សិស្សអាចគូរផ្កាយ ដោយប្រើប៊ិចរបស់ពួកគេ)

★ផ្កាយពណ៌បៃតងមួយ ប្រសិនបើប្អូនចាំថាបានធ្វើវាគ្រប់ពេល

★ផ្កាយពណ៌ខៀវ ប្រសិនបើប្អូនធ្វើវាពេលខ្លះ

★ផ្កាយពណ៌ក្រហម ប្រសិនបើប្អូនភ្លេចធ្វើវា។

ធ្វើបែបនេះសម្រាប់ពេញមួយសប្តាហ៍។ ចាំថាត្រូវស្មោះត្រង់!



ចាប់ពី_____________ រហូតដល់ __________________

ខែ ________________________________

| ខ្ញុំចាំថា ខ្ញុំបាន... | ថ្ងៃទី១ | ថ្ងៃទី២ | ថ្ងៃទី៣ | ថ្ងៃទី៤ | ថ្ងៃទី៥ | ថ្ងៃទី៦ | ថ្ងៃទី៧ |
|---|---|---|---|---|---|---|---|
| ១. ការសន្សំអំពើល្អ | | | | | | | |
| ញ៉ាំអាហារក្នុងចានរបស់ខ្ញុំឱ្យអស់ | | | | | | | |
| បោះចោលសំរាមក្នុងធុង | | | | | | | |
| ប្រើពាក្យគួរសម | | | | | | | |
| គោរពច្បាប់ចរាចរណ៍ | | | | | | | |
| ប្រើប្រាស់ទ្រព្យសម្បត្តិសាធារណៈដោយប្រុងប្រយ័ត្ន | | | | | | | |
| ចែករំលែកជាមួយអ្នកដទៃ | | | | | | | |
| រៀបចំកាតាបខ្លួនឯង និងទៅសាលាដោយមានរបៀបស្អាត | | | | | | | |
| បរិច្ចាគសម្លៀកបំពាក់ សៀវភៅ ឬគ្រឿងសង្ហារិម ដល់អង្គការសប្បុរសធម៌ | | | | | | | |
| ២. ការសន្សំសំចៃធនធានសម្រាប់ភពផែនដី | | | | | | | |
| បិទភ្លើង និងកង្ហារបន្ទាប់ពីប្រើរួច | | | | | | | |
| ប្រមូល និងកែច្នៃរបស់របរប្រើប្រាស់ឡើងវិញ | | | | | | | |
| បិទទឹកបន្ទាប់ពីប្រើរួច | | | | | | | |
| ប្រើក្រដាសឡើងវិញ | | | | | | | |
| ជ្រើសរើសផលិតផលដែលអាចប្រើឡើងវិញបាន។ | | | | | | | |
| ទិញផលិតផលជជុស | | | | | | | |
| ៣. ការសន្សំប្រាក់ | | | | | | | |
| ប្រមូលរបស់ដែលលែងប្រើដើម្បីយកលក់ យកប្រាក់ដាក់ក្នុងប្រអប់សន្សំ | | | | | | | |
| ដាក់ប្រាក់ក្នុងប្រអប់សន្សំរបស់ខ្ញុំ | | | | | | | |
| រក្សាកំណត់ត្រានៅក្នុងសៀវភៅសន្សំរបស់ខ្ញុំ។ | | | | | | | |
| ដាក់ប្រាក់ក្នុងធនាគារ។ | | | | | | | |

# មេរៀនទី៣ ប្រព័ន្ធធនាគារ

| | |
|---|---|
|  | រយៈពេល៖ ១៨០នាទី |
|  | **ការត្រៀមខ្លួនរបស់គ្រូ មុនចូលបង្រៀន**<br>- អានមេរៀនទាំងមូល<br>- ថតចម្លងឯកសារចែក<br>- ក្រដាសផ្ទាំងធំ។ |
|  | **សម្ភារៈ ធនធានដែលចាំបាច់**<br>- ឯកសារចែក ២.៣.១៖ ខិត្តប័ណ្ណរបស់ធនាគារ<br>- សន្លឹកកិច្ចការ ២.៣.២៖ ព័ត៌មានអំពីធនាគារនៅប្រទេសកម្ពុជា<br>- ឯកសារចែក ២.៣.៣៖ លិខិតអញ្ជើញ<br>- ឯកសារចែក ២.៣.៤៖ កម្រងសំណួរគំរូ<br>- សន្លឹកកិច្ចការ ២.៣.៥៖ ការដើរតួសម្តែង<br>- ឯកសារចែក ២.៣.៦៖ ទស្សនកិច្ចទៅកាន់ធនាគារ (ករណីមិនបានទៅដល់ធនាគារ)។ |
|  | **លទ្ធផលសិក្សា៖**<br>បន្ទាប់ពីបញ្ចប់មេរៀននេះ សិស្សនឹងអាច៖<br>- រាប់ឈ្មោះការងារទាំងអស់ក្នុងវិស័យធនាគារ តាមរយៈដំណើរការនៃការរុករក និងស្រាវជ្រាវ<br>- រាយការណ៍អំពីអត្ថប្រយោជន៍នៃការសន្សំប្រាក់ ដោយប្រើប្រាស់ប្រព័ន្ធធនាគារ តាមរយៈដំណើរការនៃការរុករក និងស្រាវជ្រាវ<br>- ប្រៀបធៀបអត្ថប្រយោជន៍នៃការសន្សំពីធនាគារក្នុងស្រុក។ |

## សេចក្តីផ្តើម

គ្រូចាប់ផ្តើមមេរៀនដោយរំឭកប្រាប់សិស្សថា ក្នុងមេរៀនមុនប្អូនៗបានឃើញថា ប្អូនៗអាចសន្សំសំចៃធនធានជាច្រើនប្រភេទរួមមាន ប្រាក់ជាដើម។ គ្រូសួរថា តើប្អូនៗបានបញ្ចប់កិច្ចការក្នុងឯកសារចែកស្តីពីទម្លាប់សន្សំរបស់ប្អូនហើយឬនៅ កាលពីសប្តាហ៍មុន? បន្ទាប់មកគ្រូសួរសិស្សថា តើប្អូនៗដឹងទេថាត្រូវរក្សាទុកប្រាក់ដែលបានសន្សំនៅឯណា? សំណួរនេះអាចឱ្យគ្រូពន្យល់ថា ជម្រើសមួយដែលមានសុវត្ថិភាពបំផុតគឺ ការដាក់ប្រាក់ក្នុងធនាគារ។

## សកម្មភាពសំខាន់ទី១៖ ការឈ្វេងយល់ពីព័ត៌មានទាក់ទងនឹងធនាគារ (៤០នាទី)

គ្រូសួរសិស្សនូវសំណួរខាងក្រោម។ សិស្សលើកដៃឡើង ប្រសិនបើពួកគេយល់ព្រមចំពោះសំណួរនោះ។ ក្នុងករណីសំណួរទី៤ គ្រូសរសេរចម្លើយទាំងអស់របស់សិស្សនៅលើក្តារខៀន។

១- តើប្អូនដឹងទេថា ប្អូនអាចសន្សំលុយនៅកន្លែងណា? បាទ/ចាស ឬ ទេ (កត់ត្រាថាតើមានសិស្សប៉ុន្មាននាក់ឆ្លើយ «បាទ/ចាស»)

២- តើប្អូនដឹងទេថា ធនាគារជាអ្វី? បាទ/ចាស ឬ ទេ (កត់ត្រាថាតើមានសិស្សប៉ុន្មាននាក់ឆ្លើយ «បាទ/ចាស»)

៣- តើប្អូនធ្លាប់ទៅធនាគារដែរឬទេ? បាទ/ចាស ឬ ទេ (កត់ត្រាថាតើមានសិស្សប៉ុន្មាននាក់ឆ្លើយ «បាទ/ចាស»)

៤- ចូរប្អូនរាប់ឈ្មោះធនាគារនៅក្នុងប្រទេសកម្ពុជាដែលប្អូនធ្លាប់ស្គាល់ ឬឮឱ្យបានមួយឬពីរ?

គ្រូពន្យល់ថា ជម្រើសសន្សំប្រាក់មួយក្នុងចំណោមជម្រើសដែលមានសុវត្ថិភាពបំផុតគឺ ការដាក់ប្រាក់នៅក្នុងធនាគារ។ គ្រូសរសេរចំណងជើងមេរៀនថ្មីនៅលើក្ដារខៀន៖ **ការឈ្វេងយល់អំពីព័ត៌មានសេវាកម្មរបស់ធនាគារ**។ សម្រាប់សកម្មភាពនេះ សូមចែកសិស្សជាបួនក្រុមដែលក្រុមនីមួយៗមានអ្នកដឹកនាំក្រុមម្នាក់។




គ្រូចែកខិត្តប័ណ្ណធនាគារ (**ឯកសារចែក ២.៣.១៖** ខិត្តប័ណ្ណរបស់ធនាគារ) ។ ក្រុមទី១ និងទី៣ អានខិត្តប័ណ្ណធនាគារវូរី ហើយក្រុមទី២ និងទី៤ អានខិត្តប័ណ្ណធនាគារហត្ថា ហើយពិភាក្សាជាក្រុម និងចែក**ឯកសារ ២.៣.២៖** ព័ត៌មានអំពីធនាគារនៅប្រទេសកម្ពុជា ហើយក្រុមនីមួយៗបង្កើតសំណួរមួយចំនួនទាក់ទងនឹងធនាគារ ដែលពួកគេចង់ដឹងបន្ថែម។ សិស្សអាចស្វែងរកព័ត៌មានបន្ថែមដោយចូលទៅកាន់គេហទំព័ https://www.wooribank.com.kh/ https://www.hatthabank.com/km/products/special-account-number។ វាកាន់តែប្រសើរប្រសិនបើសិស្សទៅធនាគារផ្ទាល់តែម្ដង ឬអញ្ជើញបុគ្គលិកធនាគារមកសាលាដើម្បីសម្ភាស។

គ្រូសួរសំណួរទៅសិស្សទាំងអស់។

- តើធនាគារក្នុងខិត្តប័ណ្ណឈ្មោះអ្វី? តើប្អូនដឹងទេថា ធនាគារនោះបង្កើតឡើងនៅឆ្នាំណាក្នុងប្រទេសកម្ពុជា?
- តើធនាគារនោះផ្ដល់សេវាកម្មអ្វីខ្លះ? តើប្អូនចាប់អារម្មណ៍សេវាកម្មធនាគារមួយណាខ្លាំងជាងបំផុត? ហេតុអ្វី?

នៅពេលសិស្សឆ្លើយសំណួរគ្រូសរសេរចម្លើយរបស់សិស្សនៅលើក្ដារខៀនទៅក្នុងតារាងដែលបានរៀបចំដូចខាងក្រោម៖

| | ធនាគារទី ១ | ធនាគារទី ២ | ធនាគារទី ៣ | ធនាគារទី ៤ |
|---|---|---|---|---|
| ឈ្មោះធនាគារ | | | | |
| ឆ្នាំបង្កើតធនាគារ | | | | |
| សេវាកម្មដែលផ្ដល់ជូន | | | | |
| ផ្សេងៗ | | | | |

### ការឆ្លុះបញ្ចាំង ( ៣នាទី )

គ្រូសួរសិស្សថា តើប្អូនអាចស្វែងរកព័ត៌មានទាំងអស់របស់ធនាគារតាមអ្វីដែលប្អូនចង់បានដែរឬទេ? តើប្អូនចង់ដឹងអ្វីបន្ថែមទៀតអំពីប្រព័ន្ធធនាគារ?

### សកម្មភាពសំខាន់ទី ២៖ ការត្រៀមខ្លួនមុនទៅធនាគារ ( ៤០នាទី )

គ្រូអបអរសាទរចំពោះគំនិតសិស្សដែលបានចូលរួមចំណែកទាក់ទងនឹងព័ត៌មានអំពីធនាគារ។ គ្រូប្រាប់សិស្សក្នុងថ្នាក់ទាំងអស់ថា ប្អូនៗត្រូវស្វែងរកព័ត៌មានអំពីធនាគារឱ្យបានស៊ីជម្រៅបន្ថែមទៀត ហើយប្អូនៗនឹងសម្រេចចិត្តជ្រើសរើសធនាគារដែលគួរជឿទុកចិត្តបំផុតសម្រាប់ការសន្សំនាពេលអនាគត ឬតម្រូវការផ្សេងៗ។

គ្រូសួរសិស្សក្នុងថ្នាក់ទាំងអស់។ ប្រសិនបើប្អូនចង់ទទួលបានព័ត៌មានបន្ថែមអំពីធនាគារណាមួយ តើប្អូនគួរធ្វើដូចម្តេច?

**ចម្លើយដែលអាចឆ្លើយបាន៖** រៀបចំកម្រងសំណួរ។ រៀបចំលិខិតអញ្ជើញផ្ញើទៅធនាគារឬទៅកាន់ធនាគារដោយផ្ទាល់ដើម្បីជួបជាមួយបុគ្គលិកធនាគារ។ ស្វែងរកព័ត៌មានបន្ថែមអំពីធនាគារតាមអ៊ីនធឺណិត។ល។

គ្រូបែងចែកសិស្សជាបីទៅប្រាំក្រុម អាស្រ័យលើទំហំថ្នាក់។ សិស្សពីរក្រុមនឹងធ្វើកិច្ចការដូចគ្នាដូចជា កិច្ចការទី១ ឬទី២ លើកលែងតែកិច្ចការទី៣ ដែលត្រូវជ្រើសរើសមួយក្រុមតែប៉ុណ្ណោះ។ បន្ទាប់មក គ្រូចែកកិច្ចការទាំងបីខាងក្រោម៖

- កិច្ចការទី១ (ឯកសារចែកទី ២.៣.៣)៖ ការរៀបចំលិខិតអញ្ជើញ
- កិច្ចការទី២ (ឯកសារចែកទី ២.៣.៤)៖ ការរៀបចំកម្រងសំណួរ
- កិច្ចការទី៣ (ឯកសារចែកទី ២.៣.៥)៖ ការដើរតួសម្ភាស។

ក្រុមនីមួយៗមានពេលវេលា១០នាទី ដើម្បីអានការណែនាំដោយយកចិត្តទុកដាក់នៅក្នុងកិច្ចការនីមួយៗ ហើយសិស្សធ្វើតាមការណែនាំដែលបានផ្តល់ជូនដើម្បីធ្វើកិច្ចការតាមក្រុមរៀងខ្លួន។ នៅពេលដែលក្រុមនីមួយៗបានបញ្ចប់កិច្ចការ ប្រធានក្រុម (អ្នកដឹកនាំក្រុមគួរតែត្រូវបានប្តូរវេនគ្នា) នឹងបង្ហាញចម្លើយ ឬសេចក្តីសន្និដ្ឋានដល់ថ្នាក់ទាំងមូល។ គ្រូជួយសម្របសម្រួលដល់ការឆ្លើយរបស់សិស្ស។ ដើម្បីចំណេញពេលវេលា ក្រុមដែលធ្វើកិច្ចការដូចគ្នាអាចប្រាប់ចម្លើយសំខាន់ៗបន្ថែមដែលក្រុមមួយទៀតមិនបានលើកឡើង។

សម្រាប់កិច្ចការទី២៖ ការរៀបចំកម្រងសំណួរ គ្រូនឹងបង្ហាញសំណួរដែលសរសេរនៅលើផ្ទាំងរូបភាព (សូមមើលឯកសារចែកទី ២.៣.៤) ដើម្បីជួយសិស្សឆ្លុះបញ្ចាំងពីការឆ្លើយតបរបស់ខ្លួន។ គ្រូសួរសិស្សទាំងអស់គ្នា ថាតើមានសំណួរដែលពួកគេចង់បន្ថែមដែរឬទេ?

គ្រូបង្ហាញតារាងកាលវិភាគខាងក្រោម ហើយពន្យល់ដល់សិស្សអំពីរយៈពេលធ្វើកិច្ចការ របៀបចាប់ផ្តើម និងបញ្ចប់កិច្ចការ និងការត្រៀមលក្ខណៈផ្សេងៗទៀត។

| ពេលវេលា | សកម្មភាព | ការពណ៌នា |
|---|---|---|
| ៥ នាទី | ស្វាគមន៍ | សិស្សណែនាំខ្លួន និងបង្ហាញពីគោលបំណងនៃការជួប។ (សូមមើលឯកសារចែក ២.៣.៥) |
| ២០ នាទី | ចាប់ផ្ដើមការសម្ភាស សំណួរ និងចម្លើយ | សិស្សប្រើកម្រងសំណួរដែលបានបង្កើតរួចសម្រាប់ការសម្ភាស។ ត្រូវមានអន្តរកម្មរវាងអ្នកសម្ភាស និងអ្នកទទួលការសម្ភាសក្នុងពេលសន្ទនា។ សិស្សមានទំនុកចិត្ត និងប្រើក្រសែភ្នែកដើម្បីទំនាក់ទំនង។ សិស្សនិយាយឮៗ និងអាចគ្រប់គ្រងសំឡេង។ |
| ៥ នាទី | បញ្ចប់ | សិស្សបង្ហាញពីអារម្មណ៍របស់ពួកគេ និងថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅដល់អ្នកទទួលការសម្ភាស។ (សូមមើលឯកសារចែកទី ២.៣.៥) |

**ការឆ្លុះបញ្ចាំង** (៣នាទី)

គ្រូសួរសិស្សទាំងអស់ក្នុងថ្នាក់។ តើប្អូនចូលចិត្តអ្វីខ្លះក្នុងសកម្មភាពនេះ? តើប្អូននឹងធ្វើអ្វីដើម្បីឱ្យខ្លួនឯងបានប្រសើរឡើង?

**ព័ត៌មានជំនួយ**

- សម្រាប់សកម្មភាពដែលបានគ្រោងទុកក្នុងឯកសារចែក សិស្សនឹងត្រៀមរួចរាល់ដើម្បីសម្ភាសបុគ្គលិកធនាគារ។ សិស្សអាចប្រើគំរូកម្រងសំណួរសម្ភាស (មានក្នុងឯកសារចែក ២.៣.៤) ដើម្បីសួរសំណួរ។ គ្រូគួរតែឱ្យសិស្សបង្កើតតារាងមួយដើម្បីសរសេរចម្លើយទាំងអស់ដែលបានមកពីអ្នកទទួលការសម្ភាស។
- លិខិតអញ្ជើញគួរតែត្រូវបានរៀបចំនិងផ្ញើទៅកាន់ធនាគារ ឬគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុចំនួនប្រាំផ្សេងគ្នានៅក្នុងខេត្តនានា។ ហេតុនេះ សិស្សទាំងអស់ក្នុងថ្នាក់អាចប្រើប្រាស់ចំណេះដឹង និងជំនាញរបស់ពួកគេ ដើម្បីប្រាស្រ័យទាក់ទងជាមួយមនុស្សផ្សេងៗគ្នា និងអាចសិក្សាបន្ថែមពីសេវាកម្មផ្សេងៗរបស់ធនាគារ ឬស្ថាប័នផ្សេងៗ។
- គ្រូគួររៀបចំទីកន្លែងប្អូនផ្សេងគ្នានៅក្នុងសាលារៀនក្នុងពេលតែមួយ ប្រសិនបើសិស្សត្រូវសម្ភាសបុគ្គលិកធនាគារក្នុងពេលតែមួយ។ ចាត់សមាជិកក្រុមឱ្យណែនាំបុគ្គលិកធនាគារទៅកាន់កន្លែងសម្ភាស។ សមាជិកនឹងត្រូវថតរូបក្នុងពេលសម្ភាស។
- គ្រូផ្ដល់ពេលវេលាគ្រប់គ្រាន់សម្រាប់សិស្សដើម្បីត្រៀមខ្លួនឱ្យបានល្អ (កម្រងសំណួរ កំណត់ត្រាសម្ភាស រយៈពេលនៃការសម្ភាស)ត្រូវប្រាកដថាសិស្សបានអនុវត្តម្ដងហើយម្ដងទៀតការសួរសំណួរឱ្យបានស្ទាត់។

## សកម្មភាពសំខាន់ទី ៣៖ ការត្រៀមខ្លួនក្នុងពេលសម្ភាសន៍ (៤០នាទី)

ដើម្បីជាការត្រៀមខ្លួនសម្រាប់សកម្មភាពខាងលើ គ្រូស្វាគមន៍ និងលើកទឹកចិត្តសិស្សឱ្យមានទំនុកចិត្ត និងជួយគាំទ្រគ្នាក្នុងក្រុម។ សួរសិស្សថា តើប្អូនត្រៀមខ្លួនហើយឬនៅក្នុងការជួបបុគ្គលិកធនាគារដើម្បីសម្ភាស? គ្រូប្រាប់សិស្សក្នុងថ្នាក់ថា ពួកគេនឹងស្វែងរកព័ត៌មានអំពីធនាគារឱ្យកាន់តែស៊ីជម្រៅ ហើយសិស្សនឹងសម្រេចចិត្តជ្រើសរើសធនាគារដែលល្អបំផុតសម្រាប់ការសន្សំនាពេលអនាគតរបស់ពួកគេ។

គ្រូអាចធ្វើតាមកាលវិភាគដែលបានផ្ដល់ឱ្យខាងក្រោមដើម្បីជួយណែនាំសកម្មភាពសិស្ស ឬបង្កើតដោយខ្លួនឯង។ គ្រូគួររំឭកប្រាប់សិស្សទាំងអស់ឱ្យត្រៀមខ្លួនសម្រាប់ការសម្ភាស ជាពិសេសសម្រាប់សកម្មភាពទី១និងទី២។

| កាលវិភាគសង្ខេបសម្រាប់ការសម្ភាស | |
|---|---|
| **សកម្មភាព** | **ការពណ៌នា** |
| ១- ការត្រៀមនរៀបចំ (៥ នាទី) | - ត្រូវប្រាកដថាសម្ភារៈទាំងអស់ រួមមានកម្រងសំណួរ ក្រដាសកត់ត្រា ប៊ិក ជាដើម ត្រូវបានត្រៀមទុករួចរាល់។<br>- ត្រូវប្រាកដថាអ្នកសម្ភាសទាំងអស់មានវត្តមានក្នុងពេលសម្ភាស។<br>- ត្រូវប្រាកដថាសម្លៀកបំពាក់របស់សិស្សស្អាតសមរម្យ។ |
| ២- ដំណើរការសម្ភាស សំណួរ និងចម្លើយ (៣០ នាទី) | - ស្វាគមន៍ភ្ញៀវ។<br>- ធ្វើអន្តរកម្មជាមួយភ្ញៀវដោយសួរ និងឆ្លើយសំណួរដែលបានរៀបចំទុក។<br>- ប្រមូលព័ត៌មានឱ្យបានគ្រប់គ្រាន់ក្នុងអំឡុងពេលសម្ភាស។<br>- អ្នកកត់ត្រាត្រូវប្រាកដអំពីពេលវេលាចាប់ផ្តើម និងបញ្ចប់ការសម្ភាស។<br>- មតិត្រឡប់។ |
| ៣- ការឆ្លុះបញ្ចាំងលើការសម្ភាស (១៥ នាទី) | - ប្រវែងនៃសំណួរ (ពេលវេលាដែលបានចំណាយ)<br>- ការកត់ត្រាចំណាំ (យឺតពេក ឬលឿនពេក)<br>- គុណភាពនៃសំណួរ<br>- ការប្រើប្រាស់ភាសា (ច្បាស់លាស់ឬទេ និយាយលឿនពេកឬទេ)<br>- ក្រសែភ្នែក<br>- ការងារជាក្រុម<br>- ចំណុចដើម្បីកែលម្អខ្លួនឯង។ |

### សកម្មភាពសំខាន់ទី៤៖ ការបង្កើតផ្ទាំងរូបភាពអំពីធនាគារ(៤០នាទី)

បន្ទាប់ពីបញ្ចប់ការសម្ភាស គ្រូគួរសរសើរសិស្សចំពោះការសម្ភាសកាលពីសប្តាហ៍មុន។ គ្រូគួរប្រាប់ឱ្យសិស្សអង្គុយជាមួយក្រុមសម្ភាសរបស់ពួកគេ ហើយទុកពេល៥នាទីដើម្បីឆ្លុះបញ្ចាំងលើបីចំណុចដែលពួកគេបានរៀន និងចែករំលែកដល់មិត្តក្នុងថ្នាក់។ គ្រូសរសេរចំណុចទាំងនេះនៅលើក្តារខៀន នៅពេលសិស្សធ្វើបទបង្ហាញ។

បន្ទាប់មក គ្រូប្រាប់ឱ្យសិស្សចូលរួមក្នុងក្រុមថ្មី ជាមួយនឹងសិស្សយ៉ាងហោចណាស់ម្នាក់មកពីក្រុមសម្ភាសផ្សេងទៀត។ សម្រាប់ក្រុមនីមួយៗ គ្រូផ្តល់ប្រធានបទមួយដូចជា ១) ព័ត៌មានទូទៅរបស់ធនាគារ ២) សេវាកម្មដែលផ្តល់ជូន (ប្រធានបទនេះគួរតែបែងចែកជាពីរផ្នែក៖ មួយផ្នែកផ្តោតលើអត្រាការប្រាក់ និងមួយទៀតលើប្រាក់កម្ចី និងការខ្ចី) ៣) ការងារដែលមាន។ សុំឱ្យក្រុមរចនាផ្ទាំងរូបភាពស្តីពីប្រធានបទរបស់ពួកគេ។

បន្ទាប់មក ក្រុមនីមួយៗនឹងបង្ហាញផ្ទាំងរូបភាពដល់មិត្តរួមថ្នាក់។ សិស្សទាំងអស់នឹងបង្កើតជាផ្ទាំងរូបភាពធំមួយដែលរួមបញ្ចូលនូវចំណុចសំខាន់ៗដែលមានក្នុងផ្ទាំងរូបភាពទាំងអស់។ ផ្ទាំងរូបភាពនេះអាចប្រើឡើងវិញសម្រាប់មេរៀនទី១០។

**ព័ត៌មានជំនួយ៖** គំនិតខាងក្រោមអាចជួយគ្រូក្នុងការជួយគាំទ្រសិស្សបង្កើតផ្ទាំងរូបភាពស្ដីពីប្រព័ន្ធធនាគារនៅកម្ពុជា។ គ្រូក៏ប្រើព័ត៌មានពីបទសម្ភាសរបស់សិស្ស និងព័ត៌មានផ្សេងទៀតដែលបានស្រាវជ្រាវ។

១- **សុវត្ថិភាព៖** ធនាគារផ្ដល់នូវកន្លែងសុវត្ថិភាព និងសន្តិសុខសម្រាប់រក្សាទុកប្រាក់របស់អ្នក។ ខុសពីការរក្សាទុកសាច់ប្រាក់នៅផ្ទះ ប្រាក់ដែលដាក់ក្នុងធនាគារត្រូវបានការពារពីការលួច ការបាត់បង់ ឬការខូចខាត។

២- **ការប្រាក់៖** ធនាគារផ្ដល់ការប្រាក់លើគណនីសន្សំ ដែលអនុញ្ញាតឱ្យប្រាក់របស់អ្នកកើនឡើងតាមពេលវេលា។ ខណៈពេលដែលអត្រាការប្រាក់អាចប្រែប្រួល សូម្បីតែចំនួនការប្រាក់តិចតួចក៏អាចជួយឱ្យការសន្សំរបស់អ្នកកើនឡើងលឿនជាងទុកប្រាក់ចោលផងដែរ។

៣- **ភាពងាយស្រួល៖** ធនាគារផ្ដល់ជូននូវសេវាកម្មដ៏ងាយស្រួលជាច្រើនដូចជា សេវាធនាគារតាមអនឡាញ និងទូរសព្ទ ការប្រើម៉ាស៊ីនអេធីអឹម និងការផ្ទេរតាមអេឡិចត្រូនិក។ មុខងារទាំងនេះធ្វើឱ្យងាយស្រួលក្នុងការគ្រប់គ្រង និងចូលទៅកាន់ប្រាក់សន្សំរបស់អ្នក នៅពេលណាដែលអ្នកត្រូវការ។

៤- **វិន័យផ្នែកហិរញ្ញវត្ថុ៖** តាមរយៈការរក្សាទុកប្រាក់សន្សំរបស់អ្នកនៅក្នុងធនាគារ អ្នកបង្កើតការបែងចែកយ៉ាងច្បាស់រវាងការចំណាយ និងការសន្សំ។ ការបែងចែកនេះអាចជួយអ្នករក្សាវិន័យហិរញ្ញវត្ថុ និងជៀសវាងចំណង់ក្នុងការចាយប្រាក់សន្សំរបស់អ្នកដោយមិនបានគិតគូរ។

៥- **ការចូលប្រើសេវាកម្មបន្ថែម៖** ធនាគារផ្ដល់ជូននូវផលិតផល និងសេវាកម្មហិរញ្ញវត្ថុជាច្រើនលើសពីគណនីសន្សំ។ នៅពេលមានទំនាក់ទំនងជាមួយធនាគារ អ្នកមានលទ្ធភាពទទួលបានប្រាក់កម្ចី បណ្ណឥណទាន ឱកាសវិនិយោគ និងឧបករណ៍ហិរញ្ញវត្ថុផ្សេងទៀតដែលអាចគាំទ្រដល់គោលដៅហិរញ្ញវត្ថុរបស់អ្នកបន្ថែមទៀត។

វាជារឿងសំខាន់ក្នុងការកត់សម្គាល់ថាអត្ថប្រយោជន៍មួយចំនួនអាចប្រែប្រួលរវាងធនាគារ និងប្រភេទគណនីផ្សេងៗគ្នា។ អ្នកគួរប្រៀបធៀបការផ្ដល់ជូនពីធនាគារផ្សេងៗគ្នា ហើយពិចារណាពីតម្រូវការហិរញ្ញវត្ថុផ្ទាល់ខ្លួនរបស់អ្នក មុននឹងជ្រើសរើសកន្លែងដែលត្រូវសន្សំប្រាក់។

# ឯកសារចែក ២.៣.១៖ ខិត្តប័ណ្ណរបស់ធនាគារ

## ទិន្នន័យហិរញ្ញវត្ថុសំខាន់ៗ | Key Financial Highlight

| | | |
|---|---|---|
| **$1,443M**<br>ទ្រព្យសកម្មសរុប<br>Total Asset | **$390M**<br>ប្រាក់បញ្ញើ-សន្សំ<br>Saving Deposit | **$1,180M**<br>ផលប័ត្រឥណទាន<br>Loan Portfolio |
| **460K**<br>ចំនួនអតិថិជន<br>Total Clients | **130K**<br>ដៃគូពាណិជ្ជករ<br>Merchant Partners | **290K**<br>អ្នកប្រើប្រាស់ MB<br>MB User |
| **4200**<br>ចំនួនបុគ្គលិក<br>Total Staff | **140**<br>បណ្តាញប្រតិបត្តិការ<br>Branch Network | **127**<br>បណ្តាញ ATM &<br>Self-Banking |

(គិតត្រឹម ខែកញ្ញា ឆ្នាំ២០២៣ | As of September 2023)

## អត្ថប្រយោជន៍សម្រាប់ដៃគូសហការ | Benefits of Partnership:

### 1. យុទ្ធសាស្ត្រទីផ្សារឈ្នះៗ | A win-win Marketing Strategy

- ជម្រុញការទទួលស្គាល់នៃម៉ាកយីហោតាមរយៈបណ្តាញផ្សព្វផ្សាយដ៏ទូលំទូលាយរបស់ ធនាគារ អ៊ូរី
  Promote brands & stores via wide advertisement channels of Woori Bank
- ជម្រុញការលក់តាមរយៈការគាំទ្រពីសំណាក់អតិថិជនរបស់ធនាគារ អ៊ូរី
  Increase sales via the support from Woori Bank's customers
- ផ្តល់ភាពងាយស្រួលដល់អតិថិជនជាមួយជម្រើសសម្បូរបែបនៃប្រព័ន្ធទូទាត់ប្រាក់
  Provide convenience to customers with the variety of payment method

### 2. ភាពឆ្លាតវៃនៃការដាក់ប្រាក់សន្សំ | The Smart Choice of Saving

- ទទួលបានអត្រាការប្រាក់ខ្ពស់ចាប់ពី **3%-3.5%** ពីគណនីសន្សំ ជាមួយធនាគារ អ៊ូរី
  Earn high interest rate from **3%-3.5%** with the Saving Account of Woori Bank
- ទទួលបានអត្រាការប្រាក់កាន់តែពិសេសរហូតដល់ **9%** ពីការដាក់សន្សំមានកាលកំណត់ជាមួយធនាគារ អ៊ូរី
  Earn very special interest rate up to **9%** for the Term Deposit of Woori Bank
- ទទួលបាន **Free** សម្រាប់ការប្រើប្រាស់ **Mobile Banking** និង បណ្ណ័ **ATM**
  Free usage of Mobile Banking, ATM Card

### 3. អត្ថប្រយោជន៍ផ្សេងៗ | Other Benefits

- អាចចរចាលក្ខខណ្ឌពិសេសសម្រាប់ការស្នើកម្ចីពីធនាគារ អ៊ូរី (អាស្រ័យតាមទំហំកម្ចី និងលក្ខខណ្ឌអតិថិជន ជាក់ស្តែង)
  Offer favorable condition for loan request (based on actual loan size and individual condition)
- អាចចរចាធ្វើកម្មវិធីប្រូម៉ូសិនពិសេសរួមគ្នាដើម្បីជម្រុញ ការលក់របស់ហាង (អាស្រ័យតាមគោលការឈ្នះៗ)
  Open opportunity to create co-promotion campaign (based on win-win condition)
- មានឱកាសទទួលបានប្រាក់រង្វាន់លើកទឹកចិត្តផ្សេងៗ (ធនាគារ អ៊ូរី នឹងជូនដំណឹងជាមុនអាស្រ័យតាមយុទ្ធនាការនីមួយៗ)
  Be eligible for any special reward (partners will be informed in advance based on each campaign)



## គណនីបឋមវ័យ

**គណនីបឋមវ័យ** គឺជាគណនីបញ្ញើសន្សំ មួយប្រភេទដែលត្រូវបានបង្កើតឡើងសម្រាប់ក្មេងដែលមានអាយុចាប់ពី ១០ ដល់ ១៧ឆ្នាំ បើកគណនីជាមួយ**ធនាគារ អ៊ូរី** និងអនុញ្ញាតឲ្យធ្វើប្រតិបត្តិការហិរញ្ញវត្ថុបានមួយចំនួនតាមរយៈ សេវាធនាគារចល័តរបស់ **ធនាគារ អ៊ូរី** ដែលរាល់ការធ្វើប្រតិបត្តិការហិរញ្ញវត្ថុទាំងអស់ស្ថិតនៅក្រោមការគ្រប់គ្រងពីសំណាក់ឪពុកម្តាយ ឬអាណាព្យាបាលរបស់ពួកគេ។

### អត្ថប្រយោជន៍

- ទទួលបានអត្រាការប្រាក់ខ្ពស់ ៣% - ៣.៥%
- លើកកម្ពស់ចំណេះដឹងផ្នែកហិរញ្ញវត្ថុដល់ក្មេងៗនិងរៀនសន្សំតាមបែបឌីជីថល
- ផ្តល់ឱកាសដល់ក្មេងៗនូវបទពិសោធន៍នៃការប្រើប្រាស់សេវាកម្មធនាគារតាមរយៈសេវាធនាគារចល័តរបស់ **ធនាគារ អ៊ូរី**
- ឪពុកម្តាយឬអាណាព្យាបាលអាចតាមដាននិងគ្រប់គ្រងទម្លាប់នៃការចាត់ចែងហិរញ្ញវត្ថុរបស់កូនៗបានយ៉ាងងាយស្រួលតាមរយៈ សេវាធនាគារចល័ត របស់ **ធនាគារ អ៊ូរី**

### លក្ខខណ្ឌ

| | |
|---|---|
| **រូបិយប័ណ្ណ** | ប្រាក់រៀល និង ប្រាក់ដុល្លារអាមេរិក |
| **ការដាក់ប្រាក់តម្កល់ដំបូង** | មិនតម្រូវ |
| **សមតុល្យគណនីអប្បបរមា** | មិនតម្រូវ |
| **ការប្រាក់** | បញ្ចូលជាប្រាក់ដើមរៀងរាល់ខែ |
| **លក្ខណៈសម្បត្តិ** | អតិថិជនឯកត្តបុគ្គល |

** លក្ខខណ្ឌផ្សេងៗត្រូវបានអនុវត្ត

### លក្ខខណ្ឌតម្រូវ សម្រាប់អតិថិជនឯកត្តបុគ្គល

| | |
|---|---|
| **កូន** | សំបុត្រកំណើត ឬ<br>អត្តសញ្ញាណប័ណ្ណ ឬ<br>លិខិតឆ្លងដែន |
| **ឪពុកម្តាយ ឬ អាណាព្យាបាល** | អត្តសញ្ញាណប័ណ្ណ ឬ<br>លិខិតឆ្លងដែន និង/ឬ ឯកសារពាក់ព័ន្ធផ្សេងទៀត |
| **ឯកសារបញ្ជាក់ ទំនាក់ទំនង** | សៀវភៅគ្រួសារ ឬ<br>ឯកសារបញ្ជាក់ពីភាពជា ឪពុកម្តាយ ឬ<br>អាណាព្យាបាលរបស់ក្មេង ដែលចេញដោយ<br>អាជ្ញាធរ ឬ តុលាការ។ |

### របៀបស្នើសុំបើកគណនី

- សូមអញ្ជើញទៅកាន់សាខា**ធនាគារ អ៊ូរី** ដែលនៅជិតលោកអ្នកដោយភ្ជាប់នូវឯកសារតម្រូវច្បាប់ដើម ឬទាក់ទងមកកាន់បុគ្គលិក**ធនាគារ អ៊ូរី** ដើម្បីបើកគណនីជូនដល់ទីកន្លែងរបស់លោកអ្នក។
- សម្រាប់សាខារាជធានីភ្នំពេញ អាចធ្វើការណាត់ជួបដោយផ្ទាល់ តាមរយៈលេខ៖ ០៩៣ ២១០ ២២២

## Best Junior Account

**Best Junior Account (BJA)** is new initiative savings account designed to allow child aged from 10 to 17 years old to experience the banking services by allowing them with some financial transactions under the control of their Parents/Guardian.

### Benefits

- To get high interest rate 3% - 3.5%
- To promote children's financial literacy and learn to save in digital
- To help children experience real banking services through Woori Bank Mobile App.
- To help parents/guardian fully monitor and control their children's habit of financial management through Woori Bank Mobile App.

### Conditions

| | |
|---|---|
| **Currency** | KHR and USD |
| **Initial Deposit** | Not Require |
| **Minimum Ongoing Balance** | Not Require |
| **Interest Payment** | Posted monthly |
| **Eligibilty** | Individual Customer |

** Terms and conditions apply

### Requirement for individual customers

| | |
|---|---|
| **Child** | Birth Certificate or<br>ID Card or<br>Passport |
| **Parents/ Guardian** | ID Card or<br>Passport and/or other documents |
| **Relationship Document** | Family book or<br>Any documents from competence authority/court to confirm the legal parent/guardian of the child. |

### How to Apply

- Visit nearest Woori Bank's branch office with any original copy of required original documents or contact Woori Bank's staff to visit your primise for account opening.
- Please contact Woori Bank's staff in Phnom Penh as: +855 93 210 222

# ផលិតផលប្រាក់បញ្ញើមានកាលកំណត់

ផលិតផលប្រាក់បញ្ញើមានកាលកំណត់ បង្កើតឡើងដើម្បីបំពេញសេចក្តីត្រូវការរបស់អតិថិជនដែលមានសាច់ប្រាក់នៅទំនេរអចិន្ត្រៃយ៍ ឬទំនេរក្នុងរយៈពេលជាក់លាក់ណាមួយ ឬមានសាច់ប្រាក់លើសពីសេចក្តីត្រូវការ ហើយមានបំណងចង់វិនិយោគសាច់ប្រាក់ទាំងនោះនៅកន្លែងដែលមានសុវត្ថិភាពខ្ពស់បំផុត និងទទួលបានចំណូលខ្ពស់។

ផលិតផលប្រាក់បញ្ញើមានកាលកំណត់មាន ២ ប្រភេទ៖ **គណនីបញ្ញើកើនចំណូល និង គណនីបញ្ញើកើនទ្រព្យ ។**

ផលិតផលប្រាក់បញ្ញើមានកាលកំណត់ផ្តល់ជូនចំពោះអតិថិជន ២ ប្រភេទដូចជា៖

- ផលិតផលប្រាក់បញ្ញើមានកាលកំណត់ - **រូបវន្តបុគ្គល**
- ផលិតផលប្រាក់បញ្ញើមានកាលកំណត់ - **នីតិបុគ្គល**

## ឯកសារ និងលក្ខខណ្ឌតម្រូវសម្រាប់រូបវន្តបុគ្គល

### អតិថិជនជាជនជាតិខ្មែរ

- អត្តសញ្ញាណប័ណ្ណដែលមានសុពលភាព
- លិខិតឆ្លងដែនដែលមានសុពលភាព
- ឯកសារបញ្ជាក់អំពីអត្តសញ្ញាណប្រហាក់ប្រហែលផ្សេងៗទៀត ដែលមានភ្ជាប់មកជាមួយនូវរូបថតរបស់អតិថិជនដែលចេញដោយអាជ្ញាធរមានសមត្ថកិច្ច

### អតិថិជនជាជនជាតិបរទេស

- លិខិតឆ្លងដែនដែលមានសុពលភាព ឬ
- លិខិតបញ្ជាក់អំពីអាជ្ញាធរមានសមត្ថកិច្ច/ កិច្ចសន្យាជួលសម្រាប់បញ្ជាក់អំពីអាសយដ្ឋានស្នាក់នៅក្នុងព្រះរាជាណាចក្រកម្ពុជា (ប្រសិនបើមាន)
- កិច្ចសន្យាការងារប្រសិនបើអតិថិជនធ្វើការនៅក្នុងប្រទេសកម្ពុជា (ប្រសិនបើមាន)

## ឥណទាននិស្សិតខ្មែរ

ផ្តល់ជូនដល់អាណាព្យាបាល ឬសិស្សនិស្សិត នូវជំនួយផ្នែកហិរញ្ញវត្ថុសម្រាប់ បន្តការសិក្សានៅកម្រិតឧត្តមសិក្សាដូចជា៖ បរិញ្ញាបត្រ និង បរិញ្ញាបត្រជាន់ខ្ពស់ ។

## លក្ខណៈពិសេសនៃឥណទាន

| | | |
|---|---|---|
| រូបិយប័ណ្ណ | : | ប្រាក់ដុល្លារអាមេរិក |
| រយៈពេល | : | រហូតដល់ ៨៤ខែ |
| ទំហំឥណទាន | : | រហូតដល់ ៨ ០០០ដុល្លារអាមេរិក |
| អត្រាការប្រាក់ | : | ត្រឹមតែ ១,៥០% ប៉ុណ្ណោះក្នុងមួយខែ |
| របៀបសង | : | តាមការចរចា |

## សន្លឹកកិច្ចការ ២.៣.២៖ កម្រងសំណួរអំពីធនាគារ

# កម្រងសំណួរអំពីធនាគារ



ការណែនាំ៖ សូមអានចំណុចណែនាំក្នុងជួរឈរផ្នែកពិពណ៌នាខាងក្រោម បន្ទាប់មកប្អូននឹងបង្កើតសំណួរទាក់ទងនឹងធនាគារដែលប្អូនចង់ដឹង។ សូមមើលឧទាហរណ៍នៃការបង្កើតសំណួរនៅក្នុងផ្នែកនីមួយៗដែលបានផ្តល់ជូនខាងក្រោម។

ឈ្មោះធនាគារ៖ ________________________ ស្រុក________________ ខេត្ត______________

ឈ្មោះអ្នកទទួលការសម្ភាស៖____________________ ភេទ ☐ស☐ ប តួនាទី_______________

ឈ្មោះអ្នកសម្ភាស៖ ____________________________________________________

កាលបរិច្ឆេទ៖ _______________________________________________________

| ការពិពណ៌នា | សំណួរ |
|---|---|
| ១. ព័ត៌មានទូទៅ<br>• ការបង្កើតធនាគារ<br>• ប្រទេសដើមកំណើត<br>• ចំនួនបុគ្គលិក | • តើធនាគារត្រូវបានបង្កើតឡើងនៅពេលណា?<br>____________________<br>____________________<br>____________________<br>____________________ |
| ២. សេវាដែលផ្តល់ជូន<br>• ប្រភេទសន្សំ<br>• អត្រាការប្រាក់<br>• ខ្ចីប្រាក់<br>• ប្រាក់កម្ចីសម្រាប់សាកលវិទ្យាល័យ<br>• អាយុដើម្បីបើកគណនីធនាគារ | • តើធនាគារមានតួនាទីអ្វី?<br>____________________<br>____________________<br>____________________<br>____________________<br>____________________<br>____________________ |
| ៣. ការងារដែលផ្តល់ជូននៅក្នុងធនាគារ | • តើមានការងារអ្វីខ្លះនៅក្នុងធនាគារ?<br>☐ មន្ត្រីប្រតិបត្តិការ ☐ មន្ត្រីឥណទាន ☐ ______________<br>☐ ជំនួយការផ្នែកសេវាកម្មអតិថិជន ☐ អ្នកគ្រប់គ្រងសាខា ☐ ______________<br>☐ អ្នកគ្រប់គ្រងមូលដ្ឋានទិន្នន័យ ☐ អ្នកសម្អាត ☐ ______________<br>____________________<br>____________________<br>____________________<br>____________________ |
| ៤. អនុសាសន៍<br>គំនិតណាមួយដែលធនាគារចង់ផ្តល់ជូន | • តើអ្នកនឹងផ្តល់ដំបូន្មានអ្វីខ្លះដល់អតិថិជនដែលចង់បើកគណនីនៅធនាគាររបស់អ្នក?<br>____________________<br>____________________<br>____________________<br>____________________<br>____________________ |



## ឯកសារចែក ២.៣.៣៖ លិខិតអញ្ជើញ

**ការណែនាំ៖** ចូរអានទម្រង់លិខិតអញ្ជើញខាងក្រោមដែលបានសរសេរឡើងដើម្បីអញ្ជើញតំណាងធនាគារមកសម្ភាសនៅសាលា។ នៅពេលប្អូនអានសំបុត្រចប់ ចូរឆ្លើយសំណួរនៅខាងក្រោម។

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

ការិយាល័យអប់រំក្រុងកំពង់ចាម
វិទ្យាល័យព្រះសីហនុ
លេខ៖.....................

**គោរពជូន**
**លោក លោកស្រី ប្រធានធនាគារអេស៊ីលីដា ប្រចាំក្រុងកំពង់ចាម**

**កម្មវត្ថុ:** សំណើសុំអញ្ជើញបុគ្គលិកផ្តល់ព័ត៌មានស្តីពីសេវាកម្មធនាគារ ។

សេចក្ដីដូចមានចែងក្នុងកម្មវត្ថុខាងលើ ខ្ញុំបាទ/នាងខ្ញុំមានកិត្តិយសសូមជំរាបជូនលោក លោកស្រីប្រធានមេត្តាជ្រាបថា៖ វិទ្យាល័យព្រះសីហនុយើងខ្ញុំកំពុងបណ្តុះបណ្តាលសិស្សស្តីពីអក្ខរកម្មហិរញ្ញវត្ថុដែលក្នុងនោះតម្រូវឱ្យសិស្សឈ្វេងយល់បន្ថែមពីការប្រើប្រាស់សេវាកម្មនៅធនាគារ។ ការជួបពិភាក្សា នឹងប្រព្រឹត្តទៅតាមកាលបរិច្ឆេទខាងក្រោម៖

**កាលបរិច្ឆេទ** : **ថ្ងៃអង្គារ ៥រោច ខែស្រាពណ៍-ភទ្របទ ឆ្នាំថោះ ព.ស ២៥៦៧ ត្រូវនឹងថ្ងៃទី ៥ ខែ កញ្ញា ឆ្នាំ២០២៣**
**ទីកន្លែង** : **វិទ្យាល័យព្រះសីហនុ**
**ពេលវេលា** : **៣:០០ ដល់ ៤:០០ល្ងាច**
**សមាសភាព** : **(មានបញ្ជីកម្រងសំណួរភ្ជាប់ជូន)**

អាស្រ័យដូចបានគោរពជម្រាបជូនខាងលើ សូមលោក លោកស្រីប្រធានមេត្តាជួយសម្របសម្រួលចាត់បញ្ជូនបុគ្គលិករបស់លោក-លោកស្រីចូលរួមតាមកាលបរិច្ឆេទកំណត់ដោយក្ដីអនុគ្រោះ។

សូមលោក លោកស្រីប្រធាន មេត្តាទទួលនូវការគោរពដ៏ជ្រាលជ្រៅអំពីខ្ញុំបាទ ។

ថ្ងៃព្រហ ១៥កើត ខែទុតិយាសាឍ-ស្រាពណ៍ ឆ្នាំថោះ ព.ស ២៥៦៧
កំពង់ចាម, ថ្ងៃទី៣១ ខែសីហា ឆ្នាំ២០២៣
វិទ្យាល័យព្រះសីហនុ
**នាយក/នាយិកា**

**សូមភ្ជាប់ជូន៖**

- បញ្ជីសំណួរស្តីពីសេវាកម្មធនាគារ
- កាលប្បវត្តិ-ឯកសារៈ វិទ្យាល័យព្រះសីហនុ

# ឯកសារចែក ២.៣.៤៖ គំរូនៃកម្រងសំណួរអំពីធនាគារ

ការណែនាំ៖ គ្រូនឹងស្វែងរកសំណួរគន្លឹះដើម្បីសួរទៅកាន់បុគ្គលិកធនាគារ។ គាត់/នាងគួរតែប្រើសំណួរទាំងនេះដើម្បីជួយបង្រួបបង្រួមសំណួររបស់សិស្ស។

ឈ្មោះធនាគារ៖ ____________________ ស្រុក____________ ខេត្ត____________

ឈ្មោះអ្នកទទួលការសម្ភាស៖________________ ភេទ □ស□ ប តួនាទី____________

ឈ្មោះអ្នកសម្ភាស៖ ________________________________________________

កាលបរិច្ឆេទ៖ ____________________________________________________

| ការពិពណ៌នា | សំណួរ |
|---|---|
| ១. ព័ត៌មានទូទៅ<br>• ការបង្កើតធនាគារ<br>• ប្រទេសដើមកំណើត<br>• ចំនួនបុគ្គលិក | • តើធនាគារត្រូវបានបង្កើតឡើងនៅពេលណា?<br>• តើប្រទេសដើមកំណើតអ្វីដែលបង្កើតធនាគារនៅក្នុងប្រទេសកម្ពុជា?<br>• តើមានបុគ្គលិកប៉ុន្មាននាក់? |
| ២. សេវាដែលផ្តល់ជូន<br>• ប្រភេទសន្សំ<br>• អត្រាការប្រាក់<br>• ខ្ចីប្រាក់<br>• ប្រាក់កម្ចីសម្រាប់សាកលវិទ្យាល័យ<br>• អាយុដើម្បីបើកគណនីធនាគារ | • តើធនាគារមានតួនាទីអ្វី?<br>• តើអ្នកណាអាចទៅធនាគារបាន?<br>• តើកុមារដែលមានអាយុប៉ុនខ្ញុំអាចបើកគណនីធនាគារបានដែរឬទេ?<br>• បើខ្ញុំចង់សន្សំប្រាក់ក្នុងធនាគារ តើខ្ញុំគួរធ្វើដូចម្តេច?<br>• តើខ្ញុំអាចរកប្រាក់ចំណូលបានដែរឬទេ ប្រសិនបើខ្ញុំរក្សាវាទុកនៅក្នុងធនាគារ? តើខ្ញុំអាចរកប្រាក់បានដោយរបៀបណា?<br>• តើអ្នកអាចពន្យល់បន្ថែមអំពីអត្រាការប្រាក់បានទេ ប្រសិនបើខ្ញុំសន្សំ ៦ ខែ ១ ឆ្នាំ ឬ ២ ឆ្នាំ?<br>• តើធនាគាររបស់អ្នកផ្តល់សេវាកម្មអ្វីខ្លះក្រៅពីការសន្សំ?<br>• បើខ្ញុំចង់ដកប្រាក់ពីម៉ាស៊ីន ATM តើខ្ញុំគួរធ្វើដូចម្តេច?<br>• តើមានប្រាក់កម្ចីសម្រាប់និស្សិតសាកលវិទ្យាល័យដែរឬទេ?<br>• តើយើងអាចស្នើសុំកម្ចីសម្រាប់សាកលវិទ្យាល័យដោយរបៀបណា?<br>• តើយើងអាចសងប្រាក់កម្ចីដោយរបៀបណា?<br>• ខ្ញុំតែងតែឃើញគេទៅផ្សារទំនើប ឬហាង ប្រើទូរសព្ទដៃរបស់ពួកគេដើម្បីបង់ប្រាក់។ តើអ្នកអាចពន្យល់ពីរបៀបដែលវាដំណើរការបានដែរឬទេ? |
| ៣. ការងារដែលផ្តល់ជូននៅក្នុងធនាគារ | • តើមានការងារអ្វីខ្លះនៅក្នុងធនាគារ?<br>• តើត្រូវសិក្សាអ្វីខ្លះដើម្បីអាចចូលធ្វើការនៅក្នុងធនាគារបាន? |
| ៤. អនុសាសន៍<br>គំនិតណាមួយដែលធនាគារចង់ផ្តល់ជូន | • តើអ្នកនឹងផ្តល់ដំបូន្មានអ្វីខ្លះដល់អតិថិជនដែលចង់បើកគណនីនៅធនាគាររបស់អ្នក?<br>• តើអ្នកនឹងផ្តល់ដំបូន្មានអ្វីខ្លះដល់យើងដើម្បីគ្រប់គ្រងប្រាក់ឱ្យបានល្អ?<br>• តើអ្នកអាចផ្តល់យោបល់បានទេ តើខ្ញុំអាចជ្រើសរើសធនាគារជាទីទុកចិត្តដែលខ្ញុំអាចដាក់ប្រាក់បានដោយរបៀបណា? |

## សន្លឹកកិច្ចការ ២.៣.៥៖ ការដើរតួសម្តែង

**ការណែនាំ៖** ចូរអានសាច់រឿងខាងក្រោមអំពីអាជីពរបស់វេជ្ជបណ្ឌិតម្នាក់ (២-៣ ដង) ហើយបង្កើតក្រុមមួយដើម្បីដើរតួសម្តែង ដោយផ្អែកលើការពិពណ៌នានៅក្នុងសាច់រឿង។ បន្ទាប់មក ពិភាក្សាជាមួយក្រុមរបស់ប្អូន ថាតើនរណានឹងក្លាយជាតួអង្គអ្វី។ នៅពេលប្អូនបានប្រមូលផ្តុំគំនិត និងត្រៀមខ្លួនរួចហើយ ប្អូនអាចចាប់ផ្តើមហាត់សមការសម្តែងជាមួយក្រុមដើម្បីឱ្យមានភាពជឿជាក់មុននឹងឡើងសម្តែងនៅមុខមិត្តរួមថ្នាក់ទាំងអស់។

**ប្រធានក្រុម៖** តើលោកសុខសប្បាយទេ?

**វេជ្ជបណ្ឌិត៖** បាទខ្ញុំសុខសប្បាយជាទេអរគុណ ចុះប្អូនវិញ?

**ប្រធានក្រុម៖** ចាសខ្ញុំសុខសប្បាយទេអរគុណ។ ខ្ញុំឈ្មោះ **នីតា** ជាប្រធានក្រុម សិស្សរៀនថ្នាក់ទី១១ នៅវិទ្យាល័យព្រះសីហនុ ខេត្តកំពង់ចាម។ ពួកយើងសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះការទទួលយកសំណើឱ្យយើងបានជួបលោកថ្ងៃនេះ។ ការចូលរួមចំណែករបស់លោកទាក់ទងនឹងអាជីពជាវេជ្ជបណ្ឌិតនឹងមានប្រយោជន៍សម្រាប់យើងក្នុងការរៀបចំខ្លួនយើងសម្រាប់ការងារនាពេលអនាគត។ ការសម្ភាសនឹងចំណាយពេលប្រហែល ៣០នាទី សូមអរគុណ។

**វេជ្ជបណ្ឌិត៖** ខ្ញុំពិតជារីករាយដែលបានជួបប្អូនទាំងអស់គ្នានៅគ្លីនិករបស់ខ្ញុំហើយសូមចាត់ទុកដូចជាផ្ទះរបស់ប្អូនចុះ។

**ប្រធានក្រុម៖** សូមអរគុណម្តងទៀត។ សំណួរដំបូងរបស់យើងគឺ តើលោកអាចណែនាំខ្លួន និងប្រាប់ពីបទពិសោធការងារបានដែរឬទេ?

**វេជ្ជបណ្ឌិត៖** ខ្ញុំឈ្មោះវេជ្ជបណ្ឌិតដារ៉ា។ ខ្ញុំជាវេជ្ជបណ្ឌិតឯកទេសវះកាត់។ ខ្ញុំបានបញ្ចប់ថ្នាក់បរិញ្ញាបត្រវេជ្ជសាស្ត្រ នៅឆ្នាំ២០០៥ ហើយបច្ចុប្បន្ន ខ្ញុំកំពុងធ្វើការនៅមន្ទីរពេទ្យរដ្ឋ ក្នុងខេត្តកំពង់ចាម។

**ប្រធានក្រុម៖** អរគុណសម្រាប់ព័ត៌មាននេះ។

**សមាជិកក្រុមទី១៖** តើលោកអាចប្រាប់យើងបន្ថែមអំពីតួនាទីរបស់វេជ្ជបណ្ឌិតបានដែរឬទេ?

**វេជ្ជបណ្ឌិត៖** វេជ្ជបណ្ឌិតមានតួនាទីយ៉ាងសំខាន់ក្នុងការផ្តល់ការថែទាំសុខភាព លើកកម្ពស់សុខភាព និងធ្វើឱ្យប្រសើរឡើងនូវសុខុមាលភាពរបស់បុគ្គល និងសហគមន៍។

**សមាជិកក្រុមទី២៖** តើលោកអាចពន្យល់ពីមូលហេតុដែលលោកជ្រើសរើសអាជីពជាវេជ្ជបណ្ឌិតបានដែរឬទេ?

**វេជ្ជបណ្ឌិត៖** ខ្ញុំចង់ជួយអ្នកដទៃ។ ខ្ញុំអាចផ្តល់ការថែទាំ ការគាំទ្រ និងព្យាបាលបុគ្គលដែលត្រូវការជំនួយ។ វាផ្តល់នូវការរីកចម្រើនផ្ទាល់ខ្លួន និងវិជ្ជាជីវៈរបស់ខ្ញុំ ដូចជាការអភិវឌ្ឍជំនាញ ចំណេះដឹងនៅក្នុងជំនាញឯកទេសដែលខ្ញុំបានជ្រើសរើស។ លើសពីនេះ អាជីពនេះអាចផ្តល់នូវសុវត្ថិភាព និងស្ថិរភាពការងារ។

**ប្រធានក្រុម៖** ប្រសិនបើពួកយើងចង់ជ្រើសរើសអាជីពជាវេជ្ជបណ្ឌិត តើលោកមានដំបូន្មានណែនាំអ្វីខ្លះ?

**វេជ្ជបណ្ឌិត៖** ការជ្រើសរើសអាជីពជាវេជ្ជបណ្ឌិតទាមទារការលះបង់ ការខិតខំប្រឹងប្រែង និងបំណងប្រាថ្នាពិតប្រាកដក្នុងការធ្វើឱ្យមានឥទ្ធិពលវិជ្ជមានលើជីវិតរបស់មនុស្សដទៃ។ ត្រូវឆ្លៀតពេលឈ្វេងយល់ពីជម្រើសរបស់អ្នក ទទួលបានបទពិសោធថ្មីៗ និងធ្វើការសម្រេចចិត្តប្រកបដោយការយល់ដឹង ដែលស្របតាមចំណង់ចំណូលចិត្ត និងគោលដៅរបស់អ្នក។ អាជីពនេះតម្រូវឱ្យមានចំណេះដឹងល្អខាងភាសាអង់គ្លេស/បារាំង គណិតវិទ្យា និងជីវវិទ្យា។

**ប្រធានក្រុម៖** សូមអរគុណសម្រាប់ចម្លើយដ៏ក្បោះក្បាយរបស់លោក។ យើងនឹងចែករំលែកព័ត៌មាននេះជាមួយមិត្តរួមថ្នាក់របស់យើងដែលចាប់អារម្មណ៍លើអាជីពនេះ។ ជាថ្មីម្ដងទៀត យើងសូមថ្លែងអំណរគុណយ៉ាងខ្លាំងចំពោះការចំណាយពេលវេលាដ៏មានតម្លៃរបស់លោកក្នុងការចែករំលែកដល់យើងអំពីអាជីពជាវេជ្ជបណ្ឌិត។ ពួកយើងទាំងអស់គ្នាសូមជូនពរឱ្យលោកជួបតែសំណាងល្អនាពេលអនាគត។

## ឯកសារចែក ២.៣.៦៖ ជាជម្រើស

(ករណីសិស្សមិនបានជួបបុគ្គលិកធនាគារ ឬទៅកាន់ធនាគារ គ្រូអាចអនុវត្តការសម្តែងក្នុងថ្នាក់ដោយប្រើឯកសារចែកនេះ)

# ទស្សនកិច្ចទៅកាន់ធនាគារ




ធនាគារនេះមានទីតាំងដែលយើងអាចជិះរថយន្តក្រុងទៅដល់ឆ្ងាយក្នុងអគារមួយនៅកណ្តាលទីក្រុងដែលជិតបំផុត។ ពួកគេបានឃើញអគារនេះជាច្រើនដងហើយ ប៉ុន្តែស្ទើរតែគ្មាននរណាម្នាក់ធ្លាប់បានចូលទៅក្នុងនោះទេ។

ក្នុងនោះ មានសកម្មភាពអ៊ូអរ។ មានមនុស្សអង្គុយនៅពីក្រោយតុដែលមានឯកសារ និងកុំព្យូទ័រជាច្រើន។ ពួកគេទាំងអស់មើលទៅរវល់ណាស់។ ក៏មានអ្នកផ្សេងទៀតជាច្រើននាក់ដែលកំពុងបំពេញទម្រង់ក្រដាសតូចៗ ហើយប្រគល់វាទៅអ្នកផ្សេងទៀតនៅតុនោះ។ មានមនុស្សផ្សេងទៀតកំពុងរង់ចាំជាជួរនៅតុមួយដែលមានកម្ពស់ខ្ពស់ ហើយមានផ្ទាំងផ្លាកសញ្ញាដែលសរសេរថា សាច់ប្រាក់។



អ្នកគ្រប់គ្រងបានស្វាគមន៍ពួកគេទាំងអស់គ្នា។ ពួកគេខ្លាចនាងបន្តិច។ នាងធ្វើឱ្យពួកគេនឹកឃើញដល់នាយកសាលាដ៏តឹងរ៉ឹងម្នាក់។ ពួកគេទាំងអស់បានចូលទៅក្នុងការិយាល័យអ្នកគ្រប់គ្រង។ ពួកគេបានសុំឱ្យក្មេងៗអង្គុយចុះ។ ពួកគេមានអារម្មណ៍ថាមានជាមនុស្សសំខាន់ និងមានទំនួលខុសត្រូវដែលបានអង្គុយនៅក្នុងការិយាល័យអ្នកគ្រប់គ្រងធនាគារ។ នាងបានប្រាប់ពួកគេថា គាត់បានធ្វើការក្នុងធនាគារនេះអស់រយៈពេលជិត ១៥ ឆ្នាំហើយ។ ធនាគារនេះមានឈ្មោះថា _________________។

នាងក៏បានប្រាប់ពួកគេថា វាមានការិយាល័យកណ្តាល ដែលមានទីតាំងនៅ __________ និងស្ទើរតែ _______ នៅទូទាំងប្រទេស។ នាងបាននិយាយថា នាងមានមោទនភាពយ៉ាងខ្លាំងដែលបានក្លាយជាផ្នែកមួយនៃភាពជោគជ័យបែបនេះ ដែលបានជួយប្រជាជនទូទាំងប្រទេសឱ្យសន្សំ។ បន្ទាប់មក ក្នុងលក្ខណៈដូចជាជំនួញ នាងបានចាប់ផ្តើមពន្យល់ពួកគេពីរបៀបដែលធនាគារដំណើរការ។

អ្នកគ្រប់គ្រងបានប្រាប់ពួកគេថាអ្នកគ្រប់គ្នាសន្សំប្រាក់នៅក្នុងគណនីមួយ។ នាងបានប្រាប់ពួកគេថា ធនាគារទាំងអស់មានគណនីប្រភេទផ្សេងៗគ្នា។ មនុស្សម្នាក់ៗនៅក្នុងធនាគារនេះមានគណនីមួយដែលមានលេខគណនីផ្ទាល់ខ្លួនរបស់ពួកគេ។ ព័ត៌មានលម្អិតនៃគណនីរបស់មនុស្សម្នាក់ៗត្រូវបានរក្សាទុកក្នុងសៀវភៅសន្សំ។

**គណនីចរន្ត៖** នេះជាធម្មតាសម្រាប់អ្នកជំនួញ ដែលត្រូវការប្រើប្រាស់ធនាគារជាប្រចាំ និងរក្សាទុកប្រាក់របស់ពួកគេនៅក្នុងធនាគារ ដើម្បីប្រាកដថាវាមានសុវត្ថិភាព។ ពួកគេដាក់ប្រាក់ និងដកប្រាក់ស្ទើរតែរាល់ថ្ងៃ។

**គណនីសន្សំ៖** នេះគឺជារឿងសំខាន់ដែលប្អូនត្រូវដឹង។ វាដូចជាគណនីរបស់ប្អូន។ នេះគឺជាប្រភេទនៃគណនីដែលមនុស្សភាគច្រើនចាប់ផ្តើមបើក។

ប្អូនអាចបន្ថែមប្រាក់ទៅក្នុងគណនីរបស់ប្អូននៅពេលណាដែលប្អូនចង់។ ប្រាក់ដែលប្អូនបញ្ចូលទៅក្នុងគណនីត្រូវបានគេហៅថា ប្រាក់បញ្ញើ។ បុគ្គលិកធនាគារបន្ថែមប្រាក់បញ្ញើថ្មីរបស់ប្អូនទៅក្នុងប្រាក់ដែលមានក្នុងគណនីរបស់ប្អូនរួចហើយ។ ទឹកប្រាក់សរុបរបស់ប្អូនត្រូវបានគេហៅថាសមតុល្យ។
ប្រាក់ដែលប្អូនដាក់គឺជារបស់ប្អូន ទោះបីជាអ្នកទុកវានៅធនាគារក៏ដោយ! ពេលខ្លះបន្ទាប់ពីសន្សំប្រាក់រួច ប្អូនចង់យកវាមកវិញ ប្រហែលជាយកទៅទិញរបស់លេងថ្មីៗ?






នៅពេលប្អូនចង់យកប្រាក់មកវិញ ប្អូនអាចធ្វើការដកប្រាក់។ ការដកប្រាក់គឺជាការស្នើសុំពីធនាគារដើម្បីយកប្រាក់មួយចំនួនរបស់ប្អូន។ នៅពេលដែលប្អូនដកចំនួនទឹកប្រាក់ដែលចង់បាន វាត្រូវបានដកចេញពីសមតុល្យមុនរបស់ប្អូន។ វាត្រូវបានបញ្ចូលទៅក្នុងសៀវភៅសន្សំរបស់ប្អូន។
សមតុល្យថ្មីរបស់ប្អូន គឺជាប្រាក់ដែលប្អូនបានសន្សំ ដកប្រាក់ដែលប្អូនបានដកចេញ។

**ប្រាក់បង្កើតប្រាក់ - នេះជាការប្រាក់!**

!អ្វីដែលគួរឱ្យចាប់អារម្មណ៍បំផុតដែលអ្នកគ្រប់គ្រងបានប្រាប់ពួកគេគឺអំពីការប្រាក់។ វាមានន័យថា ធនាគារឱ្យប្រាក់មកអ្នកសម្រាប់ការសន្សំប្រាក់នៅទីនោះ!!! សន្សំបានកាន់តែយូរ និងសន្សំកាន់តែច្រើន ធនាគារនឹងផ្តល់ប្រាក់ឱ្យអ្នកកាន់តែច្រើនដែរ!!!

វិធីដែលវាដំណើរការគឺ ថាធនាគារគុណចំនួនប្រាក់ដែលមាននៅក្នុងគណនីរបស់អ្នកជាមួយនឹងអ្វីដែលយើងហៅថាអត្រាការប្រាក់។ អត្រាការប្រាក់ដែលនាងបានប្រាប់ដល់ពួកគេទាំងអស់គឺត្រូវបានកំណត់ដោយធនាគារកណ្តាលនៃប្រទេស ដោយមានការពិគ្រោះយោបល់ជាមួយរដ្ឋាភិបាល។

វាត្រូវបានបន្ថែមទៅក្នុងសមតុល្យរបស់អ្នក ហើយអ្នកមានលុយប៉ុណ្ណោះ។ រំភើបណាស់មែនទេ!!! ចូរយើងគណនាការប្រាក់នៅក្នុងសៀវភៅសន្សំពីរបីសន្លឹកបន្ទាប់។

វណ្ណា បានដាក់ប្រាក់ ៥០,០០០ រៀលក្នុងធនាគារក្នុងរយៈពេល ១២ ខែ ក្នុងអត្រាការប្រាក់ ៦%។ គណនាថាតើគាត់នឹងទទួលបានប្រាក់ប៉ុន្មាននៅចុងបញ្ចប់ ១២ខែ ។

**ជំហានទី១៖** គណនាថាតើវណ្ណានឹងមានប្រាក់ប៉ុន្មាននៅចុងបញ្ចប់នៃ ១២ខែ (ដោយគ្មានការប្រាក់) ដោយយក ៥០,០០០ គុណនឹង ១២។

**៥០,០០០ X ១២ =** ______________________________

ជំហានទី ២៖ ដើម្បីទទួលបានចម្លើយចុងក្រោយ គុណចម្លើយក្នុងជំហានទី ១ ជាមួយអត្រាការប្រាក់ ៦% ឬ ៦/១០០ ឬ ០.០៦។

_______________ **X ០.០៦** = _______________



# មេរៀនទី៤ ការសម្រេចចិត្តក្នុងការសន្សំ

| | |
|---|---|
| | **រយៈពេល៖** ៤៥នាទី |
| | **ការត្រៀមខ្លួនរបស់គ្រូ មុនចូលបង្រៀន**<br>- អានមេរៀនទាំងមូល<br>- ថតចម្លងឯកសារចែកទាំងអស់។ |
| | **សម្ភារៈ ធនធានដែលចាំបាច់**<br>- សន្លឹកកិច្ចការ ២.៤.១៖ វិធីនៃការសន្សំ<br>- សន្លឹកកិច្ចការ ២.៤.២៖ សាច់រឿងរបស់ បុប្ផា<br>- សន្លឹកកិច្ចការ ២.៤.៣៖ សន្លឹករូបភាពកាតសន្សំ<br>- សន្លឹកកិច្ចការ ២.៤.៤៖ ផែនការសន្សំរបស់ខ្ញុំ<br>- ក្រដាស A4 ហ្វឺត ប៊ិក ក្រដាសផ្ទាំងធំ។ |
| | **លទ្ធផលសិក្សា៖**<br>បន្ទាប់ពីបញ្ចប់មេរៀននេះ សិស្សនឹងអាច៖<br>- ប្រៀបធៀបគុណសម្បត្តិ និងគុណវិបត្តិនៃវិធីសន្សំផ្សេងៗ<br>- បង្កើតគោលដៅសន្សំរយៈពេលខ្លី និងរយៈពេលវែង។ |

## សេចក្តីផ្តើម៖

គ្រូណែនាំមេរៀនថ្មីដល់សិស្ស ហើយប្រាប់ថាការសន្សំប្រាក់គឺជាទិដ្ឋភាពសំខាន់នៃសុខុមាលភាព និងសុវត្ថិភាពហិរញ្ញវត្ថុ។ វាអនុញ្ញាតឱ្យយើងបង្កើតសំណាញ់សុវត្ថិភាពសម្រាប់ការចំណាយដែលឥតគ្រោងទុក សម្រេចបាននូវគោលដៅរយៈពេលខ្លីនិងរយៈពេលវែង។ មានយុទ្ធសាស្ត្រនិងវិធីសាស្ត្រផ្សេងៗដែលអាចជួយបុគ្គលម្នាក់ៗសន្សំដោយប្រសិទ្ធភាព។ នៅក្នុងសេចក្តីផ្តើមនេះ ប្អូននឹងឈ្វេងយល់ពីវិធីសន្សំមួយចំនួននិងបង្កើតគោលដៅសន្សំ។

## សកម្មភាពសំខាន់ទី១៖ វិធីផ្សេងៗនៃការសន្សំប្រាក់ (១០នាទី)

គ្រូឱ្យសិស្សធ្វើការជាក្រុមដែលមានសមាជិក៥នាក់ ហើយចែកសន្លឹកកិច្ចការ២.៤.១៖ វិធីនៃការសន្សំដល់ក្រុមនីមួយៗ។ សិស្សនឹងមានពេល៣នាទីដើម្បីអានឯកសារចែកហើយមានសំណួរមួយចំនួនខាងក្រោម។ ក្រុមនីមួយៗនឹងឆ្លើយសំណួរនៅពេលពួកគេអានចប់។ គ្រូនឹងសរសេរចម្លើយរបស់សិស្សក្នុងតារាងខាងក្រោម៖

| ការសន្សំនៅផ្ទះ | | សន្សំក្នុងធនាគារ | |
|---|---|---|---|
| គុណសម្បត្តិ | គុណវិបត្តិ | គុណសម្បត្តិ | គុណវិបត្តិ |
| | | | |
| **ការសន្សំដែលមានហានិភ័យច្រើនជាង (គ្រូនឹងគូសយកប្រអប់ខាងក្រោម)**<br>☐ នៅផ្ទះ ☐ ក្នុងធនាគារ | | | |

## សកម្មភាពសំខាន់ទី២៖ ការសម្រេចចិត្តដ៏វៃឆ្លាត (១០នាទី)

គ្រូសង្កត់ធ្ងន់ថា វាជារឿងសំខាន់ក្នុងការជ្រើសរើសវិធីដែលសមស្របបំផុតដើម្បីសន្សំដោយផ្អែកលើស្ថានភាព និងគោលដៅរបស់យើង។ បន្ទាប់មក គ្រូប្រាប់សិស្សថា ការសន្សំប្រាក់ដោយឆ្លាតវៃ គឺត្រូវបង្កើតផែនការសន្សំ និងកំណត់គោលដៅ។

គ្រូចែកឯកសារទី ២.៤.២៖ សាច់រឿងរបស់បុប្ផា (សិស្សម្នាក់បានមួយសន្លឹក) ហើយសុំឱ្យសិស្សស្ម័គ្រចិត្តអានរឿងឱ្យឮៗ។ ទន្ទឹមនឹងនេះ សិស្សានុសិស្សទាំងអស់គិត និងគូសបន្ទាត់ពីក្រោមគោលដៅដែលបុប្ផាបានបង្កើតឡើង។ គ្រូអាចផ្តល់ពេលដល់សិស្ស (៣នាទី) ដើម្បីគូសបន្ទាត់ពីក្រោមគោលដៅ។ នៅពេលដែលសិស្សបានបញ្ចប់ភារកិច្ច គ្រូសួរសំណួរខាងក្រោម៖

១- តើបុប្ផាសន្សំដើម្បីអ្វី?

២- តើគោលដៅសន្សំណាមួយរបស់នាងអាចសម្រេចបានក្នុងរយៈពេលដ៏ខ្លី?

៣- តើគោលដៅសន្សំណាមួយនឹងចំណាយពេលយូរបំផុតដើម្បីសម្រេចបាន? ហេតុអ្វី?

៤- ប្រសិនបើប្អូនចង់សន្សំ តើប្អូនចង់ទិញអ្វីផ្សេងទៀត? (មិនទាមទារចម្លើយសម្រាប់ពេលនេះទេ)

**ចម្លើយដែលអាចឆ្លើយ៖**

១- អំណោយសម្រាប់ប្អូនស្រី សម្លៀកបំពាក់ថ្មី ទិញម៉ូតូ។

២- អំណោយសម្រាប់ប្អូនស្រីនិងសម្លៀកបំពាក់ថ្មី។

៣- ទិញម៉ូតូ។

## សកម្មភាពសំខាន់ទី ៣៖ ផែនការសន្សំរបស់ខ្ញុំ (២០នាទី)

គ្រូបែងចែកសិស្សជាក្រុម ដែលមានសមាជិក៥នាក់ ហើយក្រុមនីមួយៗនឹងទទួលបានសន្លឹករូបភាពកាតចំនួន៤ (សូមមើលឯកសារចែកទី២.៤.៣) អំពីវត្ថុដែលពួកគេអាចសន្សំទុកសម្រាប់គោលដៅនាពេលអនាគត។

**ចំណាំ៖** គ្រូបង្កើតសន្លឹកកាតរូបភាព បន្ថែមទៀតដើម្បីផ្តល់ឱ្យសិស្ស។ បន្ទាប់មកក្រុមនីមួយៗនឹងដាក់សន្លឹកកាតរូបភាពនៅក្នុងតារាងទី១ ដែលបានចែកឱ្យខាងក្រោម។ នៅក្នុងតារាងមានជួរឈរពីរ (ក្មេងប្រុស និងក្មេងស្រី) ក្រុមនីមួយៗនឹងសម្រេចចិត្តថាតើពួកគេដាក់ សន្លឹករូបភាពកាត របស់ពួកគេនៅក្នុងជួរឈរក្មេងប្រុស ឬក្មេងស្រីសម្រាប់គោលដៅសន្សំ។

| តារាងទី ១៖ ការសន្សំគោលដៅ | |
|---|---|
| **ក្មេងស្រី** | **ក្មេងប្រុស** |
| ឧ. សៀវភៅមនោសញ្ចេតនា | ឧ. សៀវភៅវិទ្យាសាស្ត្រ |

គ្រូសម្របសម្រួលចម្លើយរបស់សិស្ស បន្ទាប់មកសួរសំណួរខាងក្រោម៖

- តើប្អូនសម្គាល់ឃើញអ្វីដែលខុសគ្នាក្នុងការសន្សំរវាងក្មេងប្រុស និងក្មេងស្រីដែរឬទេ?
- តើប្អូនគិតថាស្រីៗអាចសន្សំប្រាក់ដើម្បីទិញ ដ្រូន (Drone) បានដែរឬទេ? ហេតុអ្វី?
- តើប្អូនគិតថាក្មេងប្រុសអាចសន្សំប្រាក់ដើម្បីទិញសម្ភារៈផ្ទះបាយបានដែរឬទេ? ហេតុអ្វី?

គ្រូពន្យល់សិស្សក្នុងថ្នាក់ ដោយប្រើព័ត៌មានជំនួយក្នុងប្រអប់ខាងក្រោម។ គ្រូយកគំនិតគួរឱ្យចាប់អារម្មណ៍មួយចំនួនដើម្បីចែករំលែកដល់សិស្ស។ **ចំណាំ៖** ត្រូវគិតអំពីពេលវេលាដែលមានសម្រាប់មេរៀននីមួយៗ។

### ផ្នត់គំនិតសន្មតផ្អែកយេនឌ័រទាក់ទងនឹងការសន្សំ

ផ្នត់គំនិតសន្មតផ្អែកយេនឌ័រទាក់ទងនឹងការសន្សំរបស់របរសម្រាប់ពេលអនាគតរវាងក្មេងប្រុស និងក្មេងស្រីត្រូវបានចាក់ឫសគល់នៅក្នុងការរំពឹងទុករបស់សង្គម ដែលគិតក្មេងប្រុសមានទំនួលខុសត្រូវផ្នែកហិរញ្ញវត្ថុច្រើនជាង និងផ្តោតលើផែនការរយៈពេលវែង ចំណែកឯក្មេងស្រីត្រូវបានគេមើលឃើញថាមានភាពរំជើបរំជួល ឬមិនសូវខ្វល់ខ្វាយអំពីបញ្ហាហិរញ្ញវត្ថុ។ ផ្នត់គំនិតសន្មតនេះអាចបន្តនាំឱ្យមានវិសមភាពយេនឌ័រ និងកំណត់ឯករាជ្យភាពហិរញ្ញវត្ថុរបស់បុគ្គលម្នាក់ៗ។

ឧទាហរណ៍៖ ផ្នត់គំនិតសន្មតទូទៅមួយគឺថា ក្មេងប្រុសត្រូវបានលើកទឹកចិត្តឱ្យសន្សំប្រាក់របស់ពួកគេដើម្បីវិនិយោគទៅលើអនាគតរបស់ពួកគេ ដូចជាសម្រាប់ការអប់រំ ការចាប់ផ្តើមអាជីវកម្ម ឬការទិញអចលនទ្រព្យ។ ម្យ៉ាងវិញទៀត ក្មេងស្រីអាចត្រូវបានលើកទឹកចិត្តឱ្យចំណាយប្រាក់របស់ពួកគេលើរបស់របរសម្រាប់បំពេញចិត្តភ្លាមៗ ឬរបស់របរដែលមិនសំខាន់។ ផ្នត់គំនិតសន្មតនេះអាចមានផលប៉ះពាល់ជាច្រើនដូចជា៖

១- **ឯករាជ្យភាពផ្នែកហិរញ្ញវត្ថុ៖** ក្មេងប្រុសអាចទំនងជាអភិវឌ្ឍជំនាញហិរញ្ញវត្ថុ និងទម្លាប់ដែលនាំទៅរកស្ថិរភាពហិរញ្ញវត្ថុរយៈពេលវែង ចំណែកឯក្មេងស្រីអាចងាយនឹងពឹងផ្អែកលើអ្នកដទៃសម្រាប់ការផ្គត់ផ្គង់ហិរញ្ញវត្ថុ។

២- **សេចក្តីប្រាថ្នាក្នុងអាជីព៖** ក្មេងប្រុសអាចត្រូវបានលើកទឹកចិត្តឱ្យបន្តអាជីពដែលផ្តល់សក្តានុពលរកប្រាក់ចំណូលបានខ្ពស់ និងមានស្ថិរភាពហិរញ្ញវត្ថុ ចំណែកឯក្មេងស្រីអាចត្រូវបានតម្រង់ទៅរកអាជីពដែលត្រូវបានគេមើលឃើញថាមិនសូវផ្តល់អត្ថប្រយោជន៍ផ្នែកហិរញ្ញវត្ថុច្រើន។

៣- **ហ៊ានប្រថុយ៖** ក្មេងប្រុសអាចនឹងត្រូវបានលើកទឹកចិត្តឱ្យហ៊ានប្រឈមមុខនឹងហានិភ័យក្នុងការវិនិយោគ ឬការបណ្តាក់ទុនអាជីវកម្ម ចំណែកឯក្មេងស្រីអាចនឹងមិនមានទឹកចិត្តក្នុងការហ៊ានប្រឈមមុខនឹងហានិភ័យដែលនាំឱ្យខកខានឱកាសរីកចម្រើនផ្នែកហិរញ្ញវត្ថុ។វាមានសារៈសំខាន់ណាស់ក្នុងការជំទាស់ទៅនឹងផ្នត់គំនិតសន្មតនេះ ដោយលើកកម្ពស់អក្ខរកម្មហិរញ្ញវត្ថុ និងឯករាជ្យភាពហិរញ្ញវត្ថុសម្រាប់បុគ្គលទាំងអស់ដោយមិនគិតពីភេទ។ ការលើកទឹកចិត្តក្មេងស្រីឱ្យចេះសន្សំប្រាក់ និងវិនិយោគសម្រាប់អនាគតរបស់ពួកគេ អាចជួយកាត់បន្ថយភាពលម្អៀងផ្នែកយេនឌ័រទាំងនេះ និងពង្រឹងភាពអង់អាចឱ្យពួកគេធ្វើការសម្រេចចិត្តផ្នែកហិរញ្ញវត្ថុប្រកបដោយការយល់ដឹងពេញលេញ។ លើសពីនេះទៀត ការបង្រៀនក្មេងប្រុសអំពីសារៈសំខាន់នៃទំនួលខុសត្រូវផ្នែកហិរញ្ញវត្ថុ និងការលើកទឹកចិត្តពួកគេឱ្យពិចារណាលើគោលដៅហិរញ្ញវត្ថុរយៈពេលខ្លី និងរយៈពេលវែងអាចជួយបង្កើតជាសង្គមមួយដែលមានសមធម៌ជាងមុន។

គ្រូឱ្យសិស្សអាននិយមន័យនៃគោលដៅរយៈពេលខ្លី និងរយៈពេលវែងនៅលើក្តារខៀន។

- **គោលដៅរយៈពេលខ្លី៖** គឺជាគោលដៅ ឬគោលបំណងដែលអ្នកកំណត់ឱ្យខ្លួនឯង ដើម្បីសម្រេចបានក្នុងរយៈពេលដ៏ខ្លីមួយ។ គោលដៅរយៈពេលខ្លីគឺជាចង់ការទិញទំនិញតូចៗដែលត្រូវចំណាយពេលប្រហែល ៦ខែដើម្បីសន្សំប្រាក់បានគ្រប់។
- **គោលដៅរយៈពេលវែង៖** គោលដៅរយៈពេលវែង គឺជាការចង់ទិញទំនិញដ៏ធំដែលត្រូវការពេលច្រើនចាប់ពី១ឆ្នាំ ឬច្រើនជាងនេះដើម្បីសន្សំប្រាក់បានគ្រប់។

សិស្សមកពីក្រុមដូចគ្នាដែលមានសមាជិក៥នាក់ ចាត់ថ្នាក់ សន្លឹកកាតរូបភាព ដាក់ក្នុងតារាងនៃគោលដៅរយៈពេលខ្លី និងវែង (នៅខាងស្តាំ)។ ក្រុមនីមួយៗអាចប្រើសន្លឹកកាតរូបភាព របស់ពួកគេ (សន្លឹកកិច្ចការ ២.៤.៣) នៅក្នុងសកម្មភាពពីមុន ហើយដាក់វានៅក្នុងគោលដៅរយៈពេលខ្លី និងរយៈពេលវែង។ គ្រូលើកឧទាហរណ៍មួយចំនួន ដើម្បីជួយសិស្សគិតបានលឿន។ គ្រូប្រាប់សិស្សថា គ្មានចម្លើយណាមួយត្រូវ ឬខុសទេ គោលដៅរយៈពេលខ្លី ឬរយៈពេលវែង អាចត្រូវបានកំណត់ទៅតាមសមត្ថភាព និងស្ថិរភាពហិរញ្ញវត្ថុរបស់ប្អូន។

| គោលដៅរយៈពេលខ្លី (សម្រាប់ ៦ ខែ) | គោលដៅរយៈពេលវែង (១ឆ្នាំឡើងទៅ) |
|---|---|
| ឧ. សៀវភៅមនោសញ្ចេតនា | |
| ឧ. សៀវភៅវិទ្យាសាស្ត្រ | |

គ្រូចែកសន្លឹកកិច្ចការ ២.៤.៤៖ គំរូគោលដៅសន្សំរបស់ខ្ញុំ ហើយពន្យល់ដូចខាងក្រោម៖ នេះគឺជាតារាងឧទាហរណ៍អំពីផែនការសន្សំ។

ឧទាហរណ៍៖ ខ្ញុំចង់ទិញស្បែកជើងកីឡាតម្លៃ ៤២ ០០០រៀល ហើយខ្ញុំត្រូវការវានៅរយៈពេល៣ខែទៀត។ វិធីសន្សំគឺ ខ្ញុំយកលុយ៥០០រៀលសម្រាប់រៀនទុកសន្សំរាល់ថ្ងៃ។ បន្ទាប់មកខ្ញុំអាចរកប្រាក់បានគ្រប់គ្រាន់ដើម្បីទិញស្បែកជើងកីឡាថ្មីមួយគូ។ ឪពុកម្តាយរបស់ខ្ញុំនឹងមានមោទនភាពចំពោះខ្ញុំ ហើយខ្ញុំឱ្យតម្លៃទៅលើលុយសន្សំ៥០០រៀល ដើម្បីសម្រេចគោលដៅរបស់ខ្ញុំ។ សិស្សនឹងបំពេញឯកសារ ២.៤.៤៖ គោលដៅសន្សំសម្រាប់ធ្វើជាកិច្ចការផ្ទះ។ គ្រូនឹងសួរសិស្សនៅក្នុងថ្នាក់បន្ទាប់។


MY SAVING GOALS

Name____________

Grade: ____________

| I would like to buy | in .... months | It costs | How much do I save per day/ week? | How much do I save per month? |
|---|---|---|---|---|
| E.g: Sport shoes | 3 | 42,000 riels | • 500 riels per day<br>• 3,500 riels per week | • 14,000 riels per month<br>• 42,000 riels per 3 months |
| | | | | |

## ការឆ្លុះបញ្ចាំង៖ ៣នាទី

គ្រូណែនាំសិស្សឱ្យឆ្លុះបញ្ចាំងអំពីខ្លួនឯងដោយប្រើសំណួរខាងក្រោម៖

- តើប្អូនបានសង្កេតឃើញអ្វីខ្លះពីសកម្មភាពនេះ?
- តើប្អូនបានរៀនសូត្រអ្វីខ្លះពីសកម្មភាពនេះ?
- តើប្អូនអាចអនុវត្តចំណេះដឹងរបស់ប្អូនទៅក្នុងជីវិតពិតប្រចាំថ្ងៃដោយរបៀបណា?
- តើអ្វីជាបញ្ហាប្រឈមក្នុងការកំណត់អត្តសញ្ញាណ និងចាត់ថ្នាក់គោលដៅរបស់ប្អូន?

## សន្លឹកកិច្ចការ ២.៤.១៖ វិធីនៃការសន្សំ

**ការណែនាំ៖** ប្អូននឹងអានព័ត៌មានអំពីវិធីសន្សំផ្សេងៗ បន្ទាប់មកប្អូននឹងឆ្លើយសំណួរខាងក្រោម៖

**ការសន្សំលក្ខណៈបុគ្គលនៅផ្ទះ៖** សិស្សអាចសន្សំប្រាក់លក្ខណៈបុគ្គលក្នុងប្រអប់សន្សំនៅផ្ទះបាន ឬពួកគេអាចទុកប្រាក់ជាមួយឪពុកម្ដាយ ឬសាច់ញាតិ។ ពួកគេកត់ត្រាការដាក់ប្រាក់ និងការដកប្រាក់របស់ពួកគេនៅក្នុងសៀវភៅកត់ត្រារបស់ខ្លួន។

**គណនីសន្សំលក្ខណៈបុគ្គលនៅក្នុងធនាគារ ឬសហគមន៍៖** សម្រាប់អ្នកដែលមានបំណងចង់បើកគណនីសន្សំលក្ខណៈបុគ្គលនៅក្នុងធនាគារ ឬគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ។ នៅក្នុងប្រទេសកម្ពុជា មនុស្សភាគច្រើនដែលមានអាយុ១៦ឆ្នាំអាចបើកគណនីសន្សំផ្ទាល់ខ្លួនបាន។ នៅក្នុងប្រទេសជាច្រើន គណនីសន្សំអាចបើកបានសម្រាប់តែមនុស្សពេញវ័យប៉ុណ្ណោះ។ វាផ្ដល់នូវកន្លែងមានសុវត្ថិភាព និងមានសន្តិសុខក្នុងការរក្សាទុកប្រាក់របស់អ្នក។

**សំណួរ៖**

- តើប្អូនអាចប្រាប់ពីគុណសម្បត្តិ និងគុណវិបត្តិនៃការសន្សំប្រាក់នៅផ្ទះបានដែរឬទេ?
- តើប្អូនអាចប្រាប់ពីគុណសម្បត្តិ និងគុណវិបត្តិនៃការសន្សំប្រាក់នៅធនាគារបានដែរឬទេ?
- រវាងការសន្សំក្នុងធនាគារ និងនៅផ្ទះ តើប្អូនគិតថាវិធីមួយណាមានហានិភ័យច្រើនជាង? ហេតុអ្វី?


## សន្លឹកកិច្ចការ ២.៤.១៖ វិធីនៃការសន្សំ

**ការណែនាំ៖** ប្អូននឹងអានព័ត៌មានអំពីវិធីសន្សំផ្សេងៗ បន្ទាប់មកប្អូននឹងឆ្លើយសំណួរខាងក្រោម៖

**ការសន្សំលក្ខណៈបុគ្គលនៅផ្ទះ៖** សិស្សអាចសន្សំប្រាក់លក្ខណៈបុគ្គលក្នុងប្រអប់សន្សំនៅផ្ទះបាន ឬពួកគេអាចទុកប្រាក់ជាមួយឪពុកម្ដាយ ឬសាច់ញាតិ។ ពួកគេកត់ត្រាការដាក់ប្រាក់ និងការដកប្រាក់របស់ពួកគេនៅក្នុងសៀវភៅកត់ត្រារបស់ខ្លួន។

**គណនីសន្សំលក្ខណៈបុគ្គលនៅក្នុងធនាគារ ឬសហគមន៍៖** សម្រាប់អ្នកដែលមានបំណងចង់បើកគណនីសន្សំលក្ខណៈបុគ្គលនៅក្នុងធនាគារ ឬគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ។ នៅក្នុងប្រទេសកម្ពុជា មនុស្សភាគច្រើនដែលមានអាយុ១៦ឆ្នាំអាចបើកគណនីសន្សំផ្ទាល់ខ្លួនបាន។ នៅក្នុងប្រទេសជាច្រើន គណនីសន្សំអាចបើកបានសម្រាប់តែមនុស្សពេញវ័យប៉ុណ្ណោះ។ វាផ្ដល់នូវកន្លែងមានសុវត្ថិភាព និងមានសន្តិសុខក្នុងការរក្សាទុកប្រាក់របស់អ្នក។

**សំណួរ៖**

- តើប្អូនអាចប្រាប់ពីគុណសម្បត្តិ និងគុណវិបត្តិនៃការសន្សំប្រាក់នៅផ្ទះបានដែរឬទេ?
- តើប្អូនអាចប្រាប់ពីគុណសម្បត្តិ និងគុណវិបត្តិនៃការសន្សំប្រាក់នៅធនាគារបានដែរឬទេ?
- រវាងការសន្សំក្នុងធនាគារ និងនៅផ្ទះ តើប្អូនគិតថាវិធីមួយណាមានហានិភ័យច្រើនជាង? ហេតុអ្វី?

# សន្លឹកិច្ចការ ២.៤.២៖ សាច់រឿងរបស់ បុប្ផា

**ការណែនាំ៖** ប្អូននឹងអានសាច់រឿងរបស់បុប្ផា បន្ទាប់មកគូសបន្ទាត់ពីក្រោមគោលដៅដែលបុប្ផាបានលើកឡើងក្នុងសាច់រឿងរបស់នាង។

បុប្ផា មានអាយុ១៨ឆ្នាំ រស់នៅក្នុងភូមិមួយនៅទីជនបទ។ នាងកំពុងទន្ទឹងរង់ចាំចូលរៀនសាកលវិទ្យាល័យ ហើយផ្លាស់ទៅទីក្រុងដើម្បីរស់នៅជាមួយមិត្តជិតស្និទ្ធរបស់នាង ក្នុងរយៈពេលពីរខែទៀត។ មុនពេលនាងចេញទៅ នាងចង់ឱ្យកាដូតូចមួយជូនប្អូនស្រីរបស់នាងឈ្មោះ ដារី។ នាងមានអារម្មណ៍សោកស្តាយដែលត្រូវទុកប្អូនស្រីរបស់នាងចោល ប៉ុន្តែមានដំណើរផ្សងព្រេងជាច្រើនកំពុងរង់ចាំនាងនៅឯទីក្រុង! នាងនឹងត្រូវការឯកសណ្ឋានថ្មី និងសម្ភារៈសិក្សាជាច្រើន។ ខណៈពេលដែលនាង មានគម្រោងបន្តការសិក្សានៅសាកលវិទ្យាល័យ នាងត្រូវធ្វើការងារ ប៉ុន្តែ នាង អាចទទួលបានប្រាក់តិចតួចប៉ុណ្ណោះ។ អ្វីដែលសំខាន់គឺថា នាងត្រូវការម៉ូតូជិះទៅសាសាហេតុនេះ នាងនឹងត្រូវសន្សំប្រាក់ទិញវាឱ្យបាន។

---

**ការណែនាំ៖** ប្អូននឹងអានសាច់រឿងរបស់បុប្ផា បន្ទាប់មកគូសបន្ទាត់ពីក្រោមគោលដៅដែលបុប្ផាបានលើកឡើងក្នុងសាច់រឿងរបស់នាង។

បុប្ផា មានអាយុ១៨ឆ្នាំ រស់នៅក្នុងភូមិមួយនៅទីជនបទ។ នាងកំពុងទន្ទឹងរង់ចាំចូលរៀនសាកលវិទ្យាល័យរបស់នាងក្នុងរយៈពេលពីរខែ ទៀត ហើយផ្លាស់ទៅទីក្រុងដើម្បីរស់នៅជាមួយមិត្តជិតស្និទ្ធរបស់នាង។ មុនពេលនាងចេញទៅ នាងចង់ឱ្យកាដូតូចមួយជូនប្អូនស្រីនាងឈ្មោះ ដារី។ នាងមានអារម្មណ៍សោកស្តាយដែលត្រូវទុកប្អូនស្រីរបស់នាងចោល ប៉ុន្តែមានដំណើរផ្សងព្រេងជាច្រើនកំពុងរង់ចាំនាងនៅឯទីក្រុង! នាងនឹងត្រូវការឯកសណ្ឋានថ្មី និងសម្ភារៈសិក្សាជាច្រើន។ ខណៈពេលដែលនាង មានគម្រោងបន្តការសិក្សានៅសាកលវិទ្យាល័យ នាងត្រូវធ្វើការងារ ប៉ុន្តែ នាង អាចទទួលបានប្រាក់តិចតួចប៉ុណ្ណោះ។ អ្វីដែលសំខាន់គឺថា នាងត្រូវការម៉ូតូជិះទៅសាសាហេតុនេះ នាងនឹងត្រូវសន្សំប្រាក់ទិញវាឱ្យបាន។

---

**ការណែនាំ៖** ប្អូននឹងអានសាច់រឿងរបស់បុប្ផា បន្ទាប់មកគូសបន្ទាត់ពីក្រោមគោលដៅដែលបុប្ផាបានលើកឡើងក្នុងសាច់រឿងរបស់នាង។

បុប្ផា មានអាយុ១៨ឆ្នាំ រស់នៅក្នុងភូមិមួយនៅទីជនបទ។ នាងកំពុងទន្ទឹងរង់ចាំចូលរៀនសាកលវិទ្យាល័យរបស់នាងក្នុងរយៈពេលពីរខែ ទៀត ហើយផ្លាស់ទៅទីក្រុងដើម្បីរស់នៅជាមួយមិត្តជិតស្និទ្ធរបស់នាង។ មុនពេលនាងចេញទៅ នាងចង់ឱ្យកាដូតូចមួយជូនប្អូនស្រីនាងឈ្មោះ ដារី។ នាងមានអារម្មណ៍សោកស្តាយដែលត្រូវទុកប្អូនស្រីរបស់នាងចោល ប៉ុន្តែមានដំណើរផ្សងព្រេងជាច្រើនកំពុងរង់ចាំនាងនៅឯទីក្រុង! នាងនឹងត្រូវការឯកសណ្ឋានថ្មី និងសម្ភារៈសិក្សាជាច្រើន។ ខណៈពេលដែលនាង មានគម្រោងបន្តការសិក្សានៅសាកលវិទ្យាល័យ នាងត្រូវធ្វើការងារ ប៉ុន្តែ នាង អាចទទួលបានប្រាក់តិចតួចប៉ុណ្ណោះ។ អ្វីដែលសំខាន់គឺថា នាងត្រូវការម៉ូតូជិះទៅសាសាហេតុនេះ នាងនឹងត្រូវសន្សំប្រាក់ទិញវាឱ្យបាន។

## សន្លឹកកិច្ចការ ២.៤.៣៖ របស់របរសម្រាប់ជម្រើសគោលដៅសន្សំ

**ការណែនាំ៖** គ្រូថតចម្លងឯកសារនេះ រួចកាត់វា ហើយចែកសាច់រឿងមួយសម្រាប់សិស្សម្នាក់។ **ចំណាំ៖** ឯកសារចែកនេះបង្ហាញពីសាច់រឿងតែមួយ។

















12:15
01 Jan, 19












17:15
Wed,11 January









## សន្លឹកកិច្ចការ ២.៤.៤៖ គោលដៅសន្សំរបស់ខ្ញុំ

**ការណែនាំ៖** ប្អូនត្រូវបំពេញគោលដៅសន្សំរបស់ប្អូននៅក្នុងតារាងខាងក្រោម។ ត្រូវប្រាកដថា ប្អូនអាចបង្កើតយ៉ាងហោចណាស់គោលដៅរយៈពេលខ្លីមួយ និងគោលដៅរយៈពេលវែងមួយ។ ចូឬចងចាំ! ហ៊ានសុបិនឱ្យធំ! អ្វីគ្រប់យ៉ាងគឺអាចធ្វើបាន!



# គោលដៅសន្សំរបស់ខ្ញុំ

ឈ្មោះ៖ ____________________

ថ្នាក់ទី៖ ____________________

| ខ្ញុំចង់ទិញ | ក្នុងពេលចំនួន ... ខែ | វាមានតម្លៃ | តើខ្ញុំសន្សំប៉ុន្មានក្នុងមួយថ្ងៃ/សប្តាហ៍? | តើខ្ញុំសន្សំបានប៉ុន្មានក្នុងមួយខែ? |
|---|---|---|---|---|
| ឧ. ស្បែកជើងកីឡា | ៣ | ៤២០០០ រៀល | • ៥០០ រៀលក្នុងមួយថ្ងៃ<br>• ៣៥០០ រៀលក្នុងមួយសប្តាហ៍ | • ១៤០០០ រៀលក្នុងមួយខែ<br>• ៤២០០០ រៀលក្នុង ៣ ខែ |
| | | | | |
| | | | | |
| | | | | |

"តក់ៗ ពេញបំពង់"

ទម្លាប់សន្សំ



# ជំពូកទី៣

# សិទ្ធិក្នុងការរកប្រាក់

## មេរៀនទី១ ពិភពការងាររបស់កុមារ

| | |
|---|---|
|  | រយៈពេល៖ ៤៥នាទី |
|  | **ការត្រៀមខ្លួនរបស់គ្រូ មុនចូលបង្រៀន**<br>- អានមេរៀនទាំងមូល<br>- សរសេរសំណួរពហុជ្រើសរើសចំនួន៣សំណួរ សម្រាប់រំឭកមេរៀនឡើងវិញនៅលើក្តារខៀន មុនម៉ោងចូលរៀន ហើយប្រើផ្ទាំងក្រដាសធំគ្របដើម្បីកុំឱ្យសិស្សឃើញសំណួរ រហូតដល់ចុងបញ្ចប់នៃមេរៀន<br>- ថតចម្លងឯកសារចែក។ |
|  | **សម្ភារៈ ធនធានដែលចាំបាច់**<br>- ក្រដាសផ្ទាំងតូច ឬធំ<br>- ប៊ិក / ហ្វឺត<br>- ឯកសារចែកទី ៣.១.១៖ ចំណេះដឹងសំខាន់ៗស្តីពីការងារកុមារ<br>- ឯកសារចែកទី ៣.១.២៖ ករណីសិក្សា។ |
|  | **លទ្ធផលសិក្សា៖**<br>បន្ទាប់ពីបញ្ចប់មេរៀននេះ សិស្សនឹងអាច៖<br>- ពណ៌នាអំពីនិយមន័យនៃការងារកុមារ និងពលកម្មកុមារ<br>- ពន្យល់ពីភាពខុសគ្នារវាងការងារកុមារ និងពលកម្មកុមារ<br>- ធ្វើចំណាត់ថ្នាក់ការងារកុមារ និងពលកម្មកុមារ<br>- មានទំនុកចិត្តក្នុងការបដិសេធរាល់ទម្រង់នៃពលកម្មកុមារ។ |

### សេចក្តីផ្តើម៖

គ្រូណែនាំមេរៀនស្តីពីពិភពនៃការងាររបស់កុមារ។ មានការជជែកវែកញែកជាច្រើនជុំវិញការឱ្យកុមារចូលរួមធ្វើការងារ ដោយសារជារឿយៗពាក់ព័ន្ធនឹងពលកម្មកុមារ ដែលប្រទេសនានាជុំវិញពិភពលោកប្តេជ្ញាលុបបំបាត់ឱ្យបាន។

## សកម្មភាពសំខាន់ទី១៖ ការឈ្វេងយល់ពីអត្ថន័យនៃពាក្យ ការងារ និងកុមារ - ការបំផុសគំនិត (២០នាទី)

គ្រូចែកឯកសារទី៣.១.១៖ ចំណេះដឹងសំខាន់ៗស្ដីពីការងារកុមារ។ គ្រូបែងចែកសិស្សជាប្រាំក្រុមដើម្បីអានខ្លឹមសារ។

- ក្រុមទី១ អានមាត្រា៣២ នៃគណៈកម្មាធិការសិទ្ធិកុមារ។
- ក្រុមទី២ អានអនុសញ្ញា១៨២ និងចំណុចសំខាន់ៗ។
- ក្រុមទី៣ អានភាពខុសគ្នារវាងពលកម្មកុមារ និងការងារកុមារ។
- ក្រុមទី៤ អាននិយមន័យពលកម្មកុមារ (ផ្នែកខាងលើ) ។
- ក្រុមទី៥ អាននិយមន័យពលកម្មកុមារ (ផ្នែកខាងក្រោម) ។

គ្រូប្រាប់ឱ្យក្រុមនីមួយៗចែករំលែកគំនិតអំពីការងារ និងពលកម្មកុមារដោយផ្អែកលើអ្វីដែលបានអាន។ គ្រូឱ្យសិស្សទាំងអស់បង្កើតនិយមន័យនៃពលកម្មកុមារ និងការងារកុមារ ដើម្បីងាយស្រួលយល់ ហើយបន្ទាប់មកគ្រូសរសេរនៅលើក្ដារខៀន។ ប្រអប់ខាងក្រោមផ្ដល់នូវចំណេះដឹងសំខាន់ៗដល់គ្រូអំពីការងារកុមារនិងពលកម្មកុមារ។

### ចំណេះដឹងសំខាន់ៗអំពីការងារកុមារ និងពលកម្មកុមារ

ពាក្យ «កុមារ» សំដៅដល់បុគ្គលទាំងឡាយណាដែលមានអាយុក្រោម ១៨ ឆ្នាំ។

**ការងារ** គឺជាសកម្មភាពផលិតភាពដែលផ្ដល់ជាការងារធ្វើ ឬប្រាក់ចំណូល។ វាជាមធ្យោបាយសម្រាប់បុគ្គល និងគ្រួសារក្នុងការរកប្រាក់ចំណូល ដើម្បីសម្រេចបាននូវតម្រូវការ និងចង់បាន និងលើកកម្ពស់សុខុមាលភាពរបស់ខ្លួន។ មនុស្សផ្សេងគ្នាអាចមានអារម្មណ៍ផ្សេងគ្នាអំពីការងារ អាស្រ័យលើថាតើវាជាសកម្មភាពដែលពួកគេចូលចិត្ត ឬថាតើវាជាអ្វីដែលពួកគេធ្វើដោយសារតែភាពចាំបាច់។ កុមារក៏ចូលរួមក្នុងទម្រង់ផ្សេងៗនៃការងារផងដែរ មិនថាជាការងារនៅផ្ទះ ឬការងារក្រៅម៉ោងដែលមានប្រាក់ឈ្នួល។ ក្នុងស្ថានភាពនីមួយៗ មានបញ្ហាប្រឈម និងឱកាសខុសៗគ្នា។

### មានភាពខុសគ្នារវាងការងារកុមារ និងពលកម្មកុមារ

មានការជជែកវែកញែកគ្នាជាបន្តបន្ទាប់អំពីពាក្យទាំងនេះ។ មានភាពខុសគ្នាគួរឱ្យកត់សម្គាល់រវាងការងារជាច្រើនដែលកុមារអាចធ្វើបាន។ ការងារខ្លះពិបាក ការងារខ្លះទៀតមានគ្រោះថ្នាក់ ហើយថែមទាំងប៉ះពាល់សីលធម៌ទៀតផង។ កុមារអនុវត្តកិច្ចការ និងសកម្មភាពយ៉ាងទូលំទូលាយ នៅពេលពួកគេធ្វើការងារ។ អង្គការពលកម្មអន្តរជាតិកំណត់និយមន័យ «ពលកម្មកុមារ» ថា ជាការងារដែលធ្វើឱ្យកុមារបាត់បង់កុមារភាព សក្ដានុពល និងសេចក្ដីថ្លៃថ្នូររបស់ពួកគេ ហើយវាបង្កគ្រោះថ្នាក់ដល់ការអភិវឌ្ឍរាងកាយ និងផ្លូវចិត្ត។

## សកម្មភាពសំខាន់ទី២៖ តើវាជាការងារ កុមារ ឬពលកម្មកុមារ? (១៥នាទី)

បន្ទាប់ពីបានកំណត់ឈ្មោះ និងភាពខុសគ្នារវាងពលកម្មកុមារ និងការងារកុមារ គ្រូចែកឯកសារ៣.១.២៖ ករណីសិក្សា។ សិស្សអានករណីសិក្សាមួយជាក្រុម រួចចាត់ថ្នាក់ករណីសិក្សានោះជាប្រភេទពលកម្មកុមារឬការងារកុមារ ហើយពន្យល់ពីមូលហេតុ។ សិស្សគូសតារាងដែលបានចែកឱ្យនៅផ្នែកខាងក្រោមនៃឯកសារចែកនោះ ហើយបំពេញតារាងតាមការណែនាំ។ សិស្សត្រៀមខ្លួនបង្ហាញការសន្និដ្ឋានដល់សិស្សទាំងអស់ នៅពេលពួកគេបានធ្វើរួច។

- ក្រុមទី១ និងទី២ អានករណីសិក្សារបស់កុសល
- ក្រុមទី៣ ទី៤ និងទី៥ អានករណីសិក្សារបស់ចំប៉ា។

នៅពេលសិស្សអានករណីសិក្សា គ្រូគូសតារាងខាងក្រោមនៅលើក្តារខៀន។ នៅពេលសិស្សបានបញ្ចប់តារាងរបស់ពួកគេ គ្រូពិនិត្យឡើងវិញនូវអ្វីដែលក្រុមនីមួយៗបានធ្វើ ហើយធ្វើការជាមួយសិស្សទាំងអស់ដើម្បីបង្កើតតារាងចុងក្រោយដែលឆ្លុះបញ្ចាំងពីការវិភាគរបស់ក្រុមទាំងអស់។

| ករណីសិក្សា | ការងារកុមារ | ពលកម្មកុមារ | មូលហេតុ |
|---|---|---|---|
| កុសល | | | |
| ចំប៉ា | | | |

បន្ទាប់មក គ្រូសួរសំណួរខាងក្រោមដល់សិស្សទាំងអស់។ (១០ នាទី)

| | បាទ/ចាស | ទេ |
|---|---|---|
| ១- តើនៅក្នុងភូមិ ឃុំ/សង្កាត់របស់ប្អូន មានកុមារធ្វើការងារដែរឬទេ? | ______ | ______ |
| ២- បើមាន តើប្អូនគិតថានោះជាពលកម្មកុមារ ឬការងារកុមារ? ហេតុអ្វី? | ______ | ______ |

៣- តើអ្នកណាជាកុមារដែលធ្វើការងារប្រភេទណា?

ក- កុមារដែលធ្វើការងារដើម្បីរកប្រាក់ចិញ្ចឹមជីវិត។

ខ- កុមារដែលធ្វើការងារប្រភេទណាមួយដោយប្រើកម្លាំង។

គ- កុមារដែលត្រូវបានបង្ខំឱ្យរៀនច្រើនម៉ោង។

៤- ហេតុអ្វីបានជាកម្មករដែលជាកុមារត្រូវធ្វើការងារ?

ក- ដើម្បីរកប្រាក់បន្ថែម។

ខ- ដោយសារតែភាពក្រីក្រ។

គ- ឪពុកម្តាយបង្ខំកូនឱ្យធ្វើការងារដើម្បីជៀសវាងរស់នៅខ្ជះខ្ជាយពេក។

៥- វាជាពលកម្មកុមារ ប្រសិនបើ៖

ក- អ្នកអាចបន្តទៅសាលារៀនបាន។

ខ- អ្នកធ្លាក់ខ្លួនឈឺដោយសារការងារនោះ។

គ- អ្នកអាចរកប្រាក់បន្ថែមសម្រាប់ខ្លួនឯង។

**ចម្លើយ៖ ៣.ក / ៤.ខ / ៥.ខ**

**កិច្ចការផ្ទះ៖** ដើម្បីត្រៀមសម្រាប់មេរៀនបន្ទាប់ គ្រូប្រាប់ឱ្យសិស្សរាយបញ្ជីជម្រើសការងារយ៉ាងហោច៤ ផ្សេងគ្នានៅក្នុងសហគមន៍ ដែលពួកគេមើលឃើញថា ជាជម្រើសដែលពួកគេអាចធ្វើបានដើម្បីរកប្រាក់រយៈពេលខ្លី ឬវែង។ សម្រាប់ប្រភេទការងារនីមួយៗ គ្រូឱ្យពួកគេកំណត់ថាតើអ្វីជាគុណសម្បត្តិ និងគុណវិបត្តិ។ គ្រូលើកទឹកចិត្តឱ្យសិស្សសម្ភាសអ្នកដែលមានបទពិសោធធ្វើការងារនោះ។ សិស្សធ្វើសកម្មភាពនេះជាកិច្ចការផ្ទះ ដើម្បីត្រៀមសម្រាប់មេរៀនបន្ទាប់។ សិស្សអាចប្រើតារាងខាងក្រោមជាជំនួយ។ ចូរគូសតារាងនេះនៅលើក្ដារខៀន មុនពេលសិស្សចាកចេញពីថ្នាក់រៀន។

| **ឱកាសការងារនៅក្នុងសហគមន៍ខ្ញុំ** | **គុណសម្បត្តិ** | **គុណវិបត្តិ** |
|---|---|---|
| ឧទាហរណ៍៖ ការចិញ្ចឹមមាន់ | - បង្កើនប្រាក់ចំណូលដើម្បីទិញរបស់ដែលត្រូវការ | - សកម្មភាពមានក្លិនមិនល្អ |
| ១-................................ | - ......................................... | - ............................................... |

**ចំណាំ៖** ការងារដែលអាចធ្វើបានក្នុងសហគមន៍គួរតែជាការងារដែលងាយរកបាន (ដាំបន្លែ ប្រមូលរបស់កែច្នៃឡើងវិញ ចិញ្ចឹមសត្វ ជួយឪពុកម្ដាយលក់ទំនិញនៅផ្សារ។ល។) ដើម្បីឱ្យសិស្សអាចរកប្រាក់បានក្នុងរយៈពេលខ្លី និងរយៈពេលវែង ហើយមិនប៉ះពាល់ដល់ការសិក្សារបស់ពួកគេ។

## ឯកសារចែកទី ៣.១.១៖ ចំណេះដឹងសំខាន់ៗស្ដីពីការងារកុមារ

### មាត្រា ៣២ នៃគណៈកម្មាធិការសិទ្ធិកុមារ៖

១- កុមារមានសិទ្ធិទទួលបានការការពារពីការកេងប្រវ័ញ្ចផ្នែកសេដ្ឋកិច្ច និងពីការធ្វើការងារទាំងឡាយណាដែលទំនងជាមានគ្រោះថ្នាក់ ឬរំខានដល់ការសិក្សារបស់កុមារ ឬបង្កគ្រោះថ្នាក់ដល់សុខភាពរបស់កុមារ ឬការអភិវឌ្ឍផ្លូវកាយ ផ្លូវចិត្ត ស្មារតី សីលធម៌ ឬសង្គម។

២- ប្រទេសនីមួយៗត្រូវតែចាត់វិធានការជាក់លាក់ដើម្បីធានាថាកុមារត្រូវបានការពារពីការកេងប្រវ័ញ្ចផ្នែកសេដ្ឋកិច្ចដោយធ្វើតាមចំណុចដូចខាងក្រោម៖

- ផ្ដល់អាយុអប្បបរមាដែលអាចចូលបម្រើការងារ។
- ផ្ដល់បទប្បញ្ញត្តិសមស្របស្ដីពីម៉ោង និងលក្ខខណ្ឌការងារ។
- ផ្ដល់ការពិន័យសមស្រប ឬទណ្ឌកម្មផ្សេងទៀត ដើម្បីធានាឱ្យមានការអនុវត្តមាត្រានេះប្រកបដោយប្រសិទ្ធភាព។

**អនុសញ្ញា ១៨២៖** អនុសញ្ញាស្ដីពីការហាមឃាត់ និងសកម្មភាពបន្ទាន់សម្រាប់ការលុបបំបាត់ទម្រង់អាក្រក់បំផុតនៃពលកម្មកុមារ។

### ចំណុចសំខាន់ៗ៖

សម្រាប់គោលបំណងនៃអនុសញ្ញានេះ៖

ពាក្យ «កុមារ» សំដៅដល់បុគ្គលទាំងឡាយណាដែលមានអាយុក្រោម១៨ឆ្នាំ។

ពាក្យ «ទម្រង់អាក្រក់បំផុតនៃពលកម្មកុមារ» រួមមាន៖

- រាល់ទម្រង់ទាសភាព ឬការអនុវត្តស្រដៀងទាសភាពដូចជា ការលក់ ឬជួញដូរកុមារ កញ្ចះបំណុល និងពលកម្មដោយបង្ខំ ឬពលកម្មចាំបាច់ខានមិនបាន ដោយរាប់បញ្ចូលទាំង ការជ្រើសដោយបង្ខំ ឬដោយចាំបាច់ខានមិនបានទៅលើកុមារសម្រាប់ប្រើនៅក្នុងជម្លោះប្រដាប់អាវុធ។
- ការប្រើប្រាស់ សញ្ជរកម្ម ឬការផ្ដល់កុមារសម្រាប់ពេស្យាចារ្យ សម្រាប់ការផលិតភាពយន្តអាសអាភាស ឬសម្រាប់ការសម្ដែងបែបអាសអាភាស។
- ការប្រើប្រាស់ សញ្ជរកម្ម ឬការផ្ដល់កុមារសម្រាប់សកម្មភាពខុសបទវិន័យ ពិសេសសម្រាប់ការផលិត និងជួញដូរគ្រឿងញៀន ដូចមានកំណត់នៅក្នុងសន្ធិសញ្ញាអន្តរជាតិដែលជាប់ទាក់ទង។
- ការងារដែលមានលក្ខណៈ ឬមានស្ថានភាពទំនងជាធ្វើឱ្យមានការខូចខាតដល់សុខភាព សុវត្ថិភាព ឬសីលធម៌របស់កុមារ នៅពេលដែលកុមារធ្វើការងារនោះ។

### ភាពខុសគ្នារវាងពលកម្មកុមារ និងការងារកុមារ៖

មានភាពខុសគ្នាគួរឱ្យកត់សម្គាល់រវាងការងារជាច្រើនដែលកុមារធ្វើ។ ការងារខ្លះពិបាក ខ្លះទៀតមានគ្រោះថ្នាក់ ហើយថែមទាំងប៉ះពាល់ដល់សីលធម៌ទៀតផង។ កុមារអនុវត្តកិច្ចការ និងសកម្មភាពយ៉ាងទូលំទូលាយនៅពេលពួកគេធ្វើការ។

### និយមន័យពលកម្មកុមារ

មិនមែនរាល់ការងារទាំងអស់ដែលកុមារធ្វើ គួរតែត្រូវបានចាត់ថ្នាក់ជាពលកម្មកុមារ ដែលត្រូវបានកំណត់គោលដៅសម្រាប់លុបបំបាត់នោះទេ។ ការចូលរួមរបស់កុមារ ឬមនុស្សវ័យជំទង់ក្នុងការងារដែលមិនប៉ះពាល់ដល់សុខភាពនិងការអភិវឌ្ឍផ្ទាល់ខ្លួន ឬរំខានដល់ការសិក្សារបស់ពួកគេ ជាទូទៅត្រូវបានចាត់ទុកថាជាអ្វីដែលវិជ្ជមាន។ នេះរួមបញ្ចូលទាំងសកម្មភាពដូចជាការជួយឪពុកម្ដាយជុំវិញផ្ទះ ជួយក្នុងអាជីវកម្មគ្រួសារ ឬរកប្រាក់ក្រៅម៉ោងសិក្សា និងអំឡុងពេលវិស្សមកាល។ ប្រភេទនៃសកម្មភាពទាំងនេះរួមចំណែកដល់ការអភិវឌ្ឍរបស់កុមារ និងសុខុមាលភាពនៃគ្រួសាររបស់ពួកគេ ការងារផ្ដល់ឱ្យពួកគេនូវជំនាញ និងបទពិសោធ និងជួយរៀបចំពួកគេឱ្យក្លាយជាសមាជិកដែលមានផលិតភាពក្នុងសង្គមក្នុងអំឡុងពេលពេញវ័យ។

ពាក្យ **ពលកម្មកុមារ** គឺជាការងារដែលធ្វើឱ្យមានផលប៉ះពាល់ដល់សុខុមាលភាពរបស់កុមារ សក្ដានុពល និងសេចក្ដីថ្លៃថ្នូររបស់ពួកគេ ហើយវាមានគ្រោះថ្នាក់ដល់ការអភិវឌ្ឍរាងកាយនិងផ្លូវចិត្ត។ វាសំដៅលើការងារដែល៖

- មានគ្រោះថ្នាក់ផ្លូវចិត្ត ផ្លូវកាយ សង្គម ឬខាងសីលធម៌ និងបង្កគ្រោះថ្នាក់ដល់កុមារ។
- រំខានដល់ការសិក្សារបស់ពួកគេដោយ៖
  - ✓ ដកហូតឱកាសរបស់ពួកគេក្នុងការចូលរៀន
  - ✓ បង្ខំឱ្យពួកគេឈប់រៀនមុនពេលកំណត់
  - ✓ តម្រូវឱ្យពួកគេព្យាយាមរួមបញ្ចូលការចូលរៀននៅសាលាជាមួយនឹងការងារយូរ និងធ្ងន់។

នៅក្នុងទម្រង់ធ្ងន់ធ្ងរបំផុត ពលកម្មកុមារពាក់ព័ន្ធនឹងយកកុមារធ្វើជាទាសករ បំបែកចេញពីគ្រួសាររបស់ពួកគេប្រឈមនឹងគ្រោះថ្នាក់ និងជំងឺធ្ងន់ធ្ងរ និង/ឬទុកចោលតែឯងនៅតាមដងផ្លូវនៃទីក្រុងធំៗ។ ជារឿយៗនៅវ័យក្មេង។ ទម្រង់ណាមួយនៃ «ការងារ» អាចត្រូវបានគេចាត់ទុកថាជា «ពលកម្មកុមារ» អាស្រ័យលើអាយុរបស់កុមារ ប្រភេទ និងម៉ោងនៃការងារដែលធ្វើ លក្ខខណ្ឌដែលត្រូវបានអនុវត្ត និងគោលបំណងដែលកំណត់ដោយប្រទេសនីមួយៗ។ ចម្លើយគឺប្រែប្រួលពីប្រទេសមួយទៅប្រទេសមួយ និងក្នុងចំណោមវិស័យក្នុងប្រទេស។

*ប្រភព៖* http://www.ilo.org/ipec/facts/lang--en/

## សន្លឹកកិច្ចការ ៣.១.២ - ករណីសិក្សាស្ដីពីការងាររបស់កុមារ

**ការណែនាំ៖** ចូរអានករណីសិក្សាខាងក្រោមជាក្រុមឬបុគ្គល។ នៅពេលអានករណីសិក្សាចប់ ចូរពិនិត្យមើលតារាងដែលបានចែកឱ្យខាងក្រោម ហើយធ្វើកិច្ចការជាមួយគ្រូដើម្បីចាត់ថ្នាក់ថាតើករណីសិក្សាដែលប្អូនបានអានគឺជាឧទាហរណ៍នៃការងារកុមារឬពលកម្មកុមារ។ ត្រូវផ្ដល់ហេតុផលសម្រាប់ចម្លើយរបស់ខ្លួន។

**ករណីសិក្សារបស់កុសល៖** កុសលរៀនថ្នាក់ទី៧ នៅខេត្តបាត់ដំបង។ គាត់រស់នៅជាមួយបងប្អូនបង្កើត៤នាក់ និងឪពុកម្ដាយរបស់គាត់។ គាត់ពិតជារីករាយក្នុងការរៀននៅសាលា ហើយក្ដីសុបិនរបស់គាត់គឺចង់ក្លាយជាមន្ត្រីហិរញ្ញវត្ថុ។ ថ្ងៃមួយ ឪពុករបស់កុសលដែលជាកម្មករក្នុងរោងចក្រវាយនភណ្ឌបានបាត់បង់ការងារ។ ដោយសារបរិបទសេដ្ឋកិច្ច ឪពុករបស់គាត់មិនអាចរកការងារផ្សេងបានទេ ហើយនៅតែគ្មានការងារធ្វើ។ គ្រួសារគ្មានប្រាក់សោះ ហើយចាប់ផ្ដើមជួបការលំបាកក្នុងការហូបចុក និងទិញរបស់របរសម្រាប់ជីវភាពប្រចាំថ្ងៃ។ កុសលទទួលខុសត្រូវរកប្រាក់ជួយផ្គត់ផ្គង់គ្រួសារ។ គាត់ចាប់ផ្ដើមធ្វើការងារក្នុងកន្លែងជួសជុលម៉ូតូក្រោយពីចេញពីរៀន ប៉ុន្តែគាត់រកប្រាក់បានតិចតួច។ ដូច្នេះ កុសលក៏សម្រេចចិត្តឈប់រៀន ដើម្បីទៅធ្វើការនៅពេលថ្ងៃផងដែរហើយរកប្រាក់ដោយធ្វើស្រែចម្ការ។ ការងារមានភាពលំបាក ហើយនៅពេលកុសលត្រឡប់មកផ្ទះវិញ ក៏នឿយហត់មិនអាចទៅលេងជាមួយមិត្តភក្ដិបានទេ។

**ករណីសិក្សារបស់ចំប៉ា៖** ចំប៉ារៀនថ្នាក់ទី៨ នៅខេត្តកំពង់ឆ្នាំង។ ឪពុករបស់នាងគឺជាជាងស្មូនម្នាក់ដែលធ្វើផើងពីដីឥដ្ឋដ៏ស្រស់ស្អាត ធ្វើផ្ថិល និងរបស់ជាច្រើននៅលើកង់បង្វិល ឬអន្ទងរបស់គាត់។ ចំប៉ា ជួយម្ដាយរបស់នាងលាយដីឥដ្ឋ មុនពេលដែលឪពុកនាងដាក់វាលើអន្ទង ហើយគាត់ចាប់ផ្ដើមធ្វើឆ្នាំង។



ពេលកំពុងធ្វើការជាមួយម្ដាយ នាងចាប់ផ្ដើមបង្កើតបានរបស់ក្មេងលេងតូចៗយ៉ាងយឺតៗ។ នាងបានធ្វើនាវាតូចៗ ចង្កៀងដីឥដ្ឋ កូនជ្រូកតូចមួយ ដំរី និងឆ្មា។ ឪពុករបស់នាងបានឃើញរបស់ក្មេងលេងទាំងនោះ ហើយសប្បាយចិត្តជាខ្លាំងដែលនាងបានចេះធ្វើដោយដៃរបស់នាង។ ពេលឪពុកម្ដាយយកឆ្នាំងទៅផ្សារ នាងក៏ទៅជាមួយដែរ។ នៅផ្សារ នាងចាប់អារម្មណ៍មើលហាងទាំងអស់ និងរបស់របរលក់ដូរជាច្រើនទៀត។ នាងបានកំណត់គោលដៅរបស់នាងចង់ទិញខ្សែបូថ្មីដើម្បីចងសក់។ នាងបានដឹងពីតម្លៃបូចងសក់នោះ។ នាងដឹងថា ប្រសិនបើនាងលក់របស់ក្មេងលេងដែលនាងបានបង្កើតបានចំនួន៦ នាងនឹងអាចទិញខ្សែបូនោះបាន។ នាងពិតជារំភើបណាស់។ នាងបានត្រឡប់ទៅតូបឪពុកម្ដាយនាងវិញ ហើយចាប់ផ្ដើមលក់ប្រដាប់ក្មេងលេងជាមួយពួកគាត់។ នាងបានលក់ប្រដាប់ក្មេងលេងបានចំនួន៦ ហើយក៏ទៅទិញខ្សែបូនោះ។ បន្ទាប់មក នាងបានផ្ដោតលើការលក់របស់ក្មេងលេងដែលនៅសល់ ហើយសម្រេចចិត្តថានាងនឹងទិញសៀវភៅខ្លះសម្រាប់ទៅរៀន។

ជារៀងរាល់ថ្ងៃ នាងបន្តធ្វើការងារជាមួយឪពុកម្ដាយនាង ដោយរៀនពីបច្ចេកទេសថ្មីនៃការលាយដីឥដ្ឋ ធ្វើប្រដាប់ប្រដាក្មេងលេងប្រភេទថ្មីៗ ដែលត្រូវដុតកម្ដៅដើម្បីវាឱ្យស្អាត មិនងាយខូច និងវេចខ្ចប់ឱ្យបានត្រឹម។ នាងបានបន្តទៅសាលារៀន។ នាងក៏ចាប់ផ្ដើមរៀនធ្វើផ្ថិល ថូ ពាង និងរបស់ផ្សេងៗទៀតដែលឪពុកម្ដាយបង្កើត។

# មេរៀនទី២ ជម្រើសក្នុងការរកប្រាក់

| | |
|---|---|
|  | **រយៈពេល៖** ៩០ នាទី |
|  | **ការត្រៀមខ្លួនរបស់គ្រូ មុនចូលបង្រៀន**<br>- អានមេរៀនទាំងមូល<br>- ថតចម្លងឯកសារ។ |
|  | **សម្ភារៈ ធនធានដែលចាំបាច់**<br>- សន្លឹកកិច្ចការ ៣.២.១៖ ការវិភាគអាជីវកម្មខ្នាតតូច<br>- សន្លឹកកិច្ចការ ៣.២.២៖ ផែនការអាជីវកម្ម<br>- ក្រដាសវ៉ាមធំ និងហ្វឺត។ |
|  | **លទ្ធផលសិក្សា៖**<br>បន្ទាប់ពីបញ្ចប់មេរៀននេះ សិស្សនឹងអាច៖<br>- បញ្ជាក់វិធីផ្សេងៗនៃការរកប្រាក់<br>- បង្កើតផែនការផ្ទាល់ខ្លួនដើម្បីរកប្រាក់ និងពង្រឹងសុខុមាលភាពរបស់ខ្លួន។ |

## សេចក្ដីផ្ដើម៖

គ្រូស្វាគមន៍សិស្សក្នុងថ្នាក់រៀន ហើយសួរថា តើការស្ទង់មតិអំពីការងារនៅក្នុងសហគមន៍របស់ប្អូន ដែលគ្រូបានឱ្យធ្វើជាកិច្ចការផ្ទះនោះ រួចហើយឬនៅ? តើប្អូនអាចប្រាប់ពីការងារនោះបានដែរឬទេ?

## សកម្មភាពសំខាន់ទី១៖ ការរាយបញ្ជីបញ្ហាប្រឈមដើម្បីទទួលបានការងារធ្វើ (១៥នាទី)

គ្រូប្រាប់ឱ្យសិស្សឱ្យប្រើជម្រើសការងារដែលពួកគេបានរាយក្នុងបញ្ជីឬស្ទង់មតិ ជាកិច្ចការផ្ទះសម្រាប់មេរៀនមុន។ គ្រូបែងចែកសិស្សជាក្រុមដែលមានសមាជិកពី៤ ទៅ ៦នាក់ ហើយចែកក្រដាសផ្ទាំងធំ និងហ្វឺត។ បន្ទាប់មក គ្រូឱ្យសិស្សគូរតារាងដូចគ្នានឹងតារាងដែលពួកគេបានប្រើសម្រាប់កិច្ចការផ្ទះ ប៉ុន្តែបន្ថែមជួរទីបួន៖ «បញ្ហាប្រឈមក្នុងការទទួលបានការងារប្រភេទនេះ។» គ្រូគូរតារាងនៅលើក្ដារខៀន។

**ជម្រើសការងារ គុណសម្បត្តិ និងគុណវិបត្តិ**

| ការងារ | គុណសម្បត្តិ | គុណវិបត្តិ | បញ្ហាប្រឈមក្នុងការទទួលបានការងារនេះ |
|---|---|---|---|
| | | | |
| | | | |
| | | | |

គ្រូរាយបញ្ជីការងារទាំងអស់ដែលសិស្សបានលើកឡើង ហើយផ្ដល់នូវឈ្មោះការងារបន្ថែម ដែលសិស្សប្រហែលជាមិនទាន់បានរកឃើញ។ គ្រូអាចប្រើបញ្ជីខាងក្រោម៖ ធ្វើការងារនៅកសិដ្ឋានសម្រាប់ពេលចុងសប្ដាហ៍

ការដឹកជញ្ជូនអាហារ បង្រៀនមិត្តភក្តិ ដាំបន្លែ ចិញ្ចឹមសត្វ គូរគំនូរ លក់ទំនិញនៅផ្សារ ឬតាមអនឡាញ ប្រមូលរបស់ដែលអាចកែច្នៃឡើងវិញបាន កម្មសិក្សានៅរោងពុម្ព អ្នកបង្កើតវីដេអូ...។

គ្រូឱ្យក្រុមទាំងអស់ឡើងបង្ហាញចំណុចសំខាន់ៗនៃការពិភាក្សាដល់មិត្តរួមថ្នាក់។

### សកម្មភាពសំខាន់ទី២៖ ការវិភាគអាជីវកម្មខ្នាតតូច (១៥នាទី)

គ្រូបំផុសនូវបញ្ហាប្រឈមមួយដល់ក្រុមនីមួយៗ តែគ្រូត្រូវប្រាកដថាបញ្ហាប្រឈមដែលបានដាក់ឱ្យសិស្សគឺអាចដោះស្រាយបានតាមជំហានជាក់ស្តែងតូចៗ។ ឧទាហរណ៍ ប្រសិនបើបញ្ហាប្រឈមគឺ «ត្រូវឆ្លងកាត់ការសម្ភាស» ក្រុមអាចកំណត់ជំហានឆ្ពោះទៅរកការត្រៀមខ្លួនសម្រាប់ការសម្ភាស។ គ្រូប្រាប់ឱ្យសិស្សបំផុសគំនិតអំពីសកម្មភាពដែលនឹងជួយពួកគេដោះស្រាយបញ្ហាប្រឈម ក្នុងរយៈពេល១០នាទី។

**គ្រូចែកសន្លឹកកិច្ចការ ៣.២.១៖** ការវិភាគអាជីវកម្មខ្នាតតូចដល់សិស្សម្នាក់ៗ។ បន្ទាប់មក គ្រូពន្យល់ពីរបៀបបំពេញតារាងឱ្យត្រឹមត្រូវ។

នៅពេលដែលសិស្សយល់ សិស្សម្នាក់ៗចាប់ផ្តើមធ្វើការវិភាគអាជីវកម្មផ្ទាល់ខ្លួន។

### សកម្មភាពសំខាន់ទី៣៖ ផែនការរកប្រាក់ (១៥នាទី)

គ្រូណែនាំសកម្មភាពដោយនិយាយថា វាមានសារៈសំខាន់ណាស់សម្រាប់សិស្សក្នុងការធ្វើឱ្យមានតុល្យភាពរវាងការងារ និងកិច្ចការផ្សេងទៀត។ ខណៈពេលដែលការងារអាចផ្តល់អត្ថប្រយោជន៍ជាច្រើន វាមិនគួរប៉ះពាល់លើទំនួលខុសត្រូវសិក្សារបស់សិស្ស ឬរារាំងការលូតលាស់ផ្ទាល់ខ្លួនរបស់ពួកគេឡើយ។ សិស្សអាចផ្តល់អាទិភាពលើការអប់រំរបស់ខ្លួន និងធានាថាការប្តេជ្ញាចិត្តលើការងាររបស់ពួកគេមិនប៉ះពាល់អវិជ្ជមានដល់សុខុមាលភាពទូទៅឡើយ។

គ្រូបង្ហាញផែនការរកប្រាក់ជាមួយឧទាហរណ៍ខាងក្រោម។ បន្ទាប់មក ពន្យល់ពីរបៀបបំពេញតារាងដោយប្រើសន្លឹកកិច្ចការ ៣.២.២៖ ផែនការអាជីវកម្ម។

| **ការងារដែលបានជ្រើសរើស** | **កាលបរិច្ឆេទ** | **ទីកន្លែង** | **ឈ្មោះអាជីវករ** | **សម្ភារៈចាំបាច់** | **តម្រូវការប្រាក់** | **ប្រាក់ចំណូល** |
|---|---|---|---|---|---|---|
| ឧទាហរណ៍៖ ការចិញ្ចឹមមាន់ | ខែកុម្ភៈ ឆ្នាំ ២០២៤ | ផ្ទះខ្ញុំ | ដារ៉ា | ទ្រុង<br>មេមាន់៨ក្បាល<br>មាន់គក១ក្បាល<br>អាហារ/ទឹក... | ២៤០ ០០០ រៀល | មិនទាន់ដឹង |
| ឧទាហរណ៍៖ ធ្វើការក្នុងកសិដ្ឋាននៅចុងសប្តាហ៍ | ខែកុម្ភៈ ឆ្នាំ ២០២៤ | ក្នុងភូមិខ្ញុំ | ធីតា | គ្មាន | គ្មាន | កន្លះថ្ងៃ<br>១៥ ០០០ រៀល |

ដើម្បីបញ្ចប់មេរៀនថ្ងៃនេះ គ្រូសួរសិស្សអំពីអ្វីដែលពួកគេបានរៀនពីសកម្មភាពនេះ ហើយសួរថាតើពួកគេនឹងនាំយកអ្វីពីមេរៀននេះទៅអនុវត្តនៅក្នុងគ្រួសារ និងក្នុងសហគមន៍?

## សន្លឹកកិច្ចការ ៣.២.១៖ ការវិភាគអាជីវកម្មខ្នាតតូច

**ការណែនាំ៖** សិស្សបំពេញតារាងខាងក្រោមដោយធ្វើការវិភាគ និងកំណត់ប្រភេទនៃអាជីវកម្មខ្នាតតូច ដែលពួកគេអាចបង្កើតឡើងដោយផ្អែកលើលក្ខណៈវិនិច្ឆ័យខាងក្រោម។

- ទីកន្លែង សំដៅលើកន្លែងដែលប្អូនអាចចូល ឬមានកន្លែងសម្រាប់ធ្វើការងារនេះ។
- សម្ភារៈ សំដៅលើវត្ថុដែលត្រូវការចាំបាច់ដើម្បីធ្វើអាជីវកម្មនេះ។
- តម្រូវការទីផ្សារ សំដៅលើលទ្ធភាពនៃការលក់។
- ថវិកា សំដៅលើប្រាក់ដែលត្រូវការដើម្បីចាប់ផ្តើមអាជីវកម្ម។
- ជំនាញ សំដៅលើអ្វីដែលប្អូនចេះធ្វើ។

**របៀបដាក់ពិន្ទុ៖**

១ = តម្រូវការទាប ២ = តម្រូវការមធ្យម ៣ = តម្រូវការខ្ពស់

**ចំណាំ៖** សម្រាប់ផ្នែកថវិកា ពិន្ទុត្រូវបានដាក់បញ្ច្រាសមកវិញ៖ ៣=មិនថ្លៃ ២= តម្លៃមធ្យម ១=ថ្លៃណាស់

| ល.រ. | ឈ្មោះការងារ | ទីកន្លែង | សម្ភារៈ | តម្រូវការទីផ្សារ | ថវិកា | ជំនាញ | ពិន្ទុសរុប | ការងារដែលត្រូវជ្រើសរើស | |
|---|---|---|---|---|---|---|---|---|---|
| | | | | | | | | បាទ/ចាស | ទេ |
| ឧ. | ដឹកជញ្ជូនអាហារ | ៣<br>ទីក្រុងជាកន្លែងល្អ។ | ១<br>ត្រូវការម៉ូតូ | ៣<br>មនុស្សចូលចិត្តញ៉ាំនៅផ្ទះ/ការិយាល័យ | ១<br>ម៉ូតូមានតម្លៃថ្លៃ | ៣<br>ប្អូនស្គាល់ទីតាំង និងចេះជិះម៉ូតូ។ | ១១ | | X |
| ឧ. | ចិញ្ចឹមមាន់ | ៣<br>មានកន្លែងទំនេរនៅផ្ទះ | ២<br>អាចស្វែងរកសម្ភារៈក្នុងមូលដ្ឋានដើម្បីសាងសង់ទ្រុង | ៣<br>មនុស្សចូលចិត្តញ៉ាំសាច់មាន់ ហើយវាតម្លៃថោក | ២<br>ត្រូវការប្រាក់តិច | ២<br>ត្រូវសិក្សាពីរបៀបចិញ្ចឹមសត្វ | ១២ | X | |
| ១. | | | | | | | | | |
| ២. | | | | | | | | | |
| ៣. | | | | | | | | | |
| ៤. | | | | | | | | | |
| | | | | | | | | | |

## សន្លឹកកិច្ចការ ៣.២.២៖ ផែនការអាជីវកម្មខ្នាតតូច

**ការណែនាំ៖** ចូរប្អូនធ្វើផែនការអាជីវកម្មខ្នាតតូចរបស់ប្អូន ដើម្បីបង្កើតប្រាក់ចំណូល និងឈានដល់ការសម្រេចផែនការសន្សំរបស់ប្អូននាពេលខាងមុខ។ ឧទាហរណ៍ចំនួនពីរបានផ្តល់ជាគំនិតមុននឹងប្អូនចាប់ផ្តើមបំពេញផែនការអាជីវកម្ម។

| ការងារដែលបានជ្រើសរើស | ពេលវេលា | ទីកន្លែង | អាជីវករ | សម្ភារៈចាំបាច់ | តម្រូវការប្រាក់ | ប្រាក់ចំណូល |
|---|---|---|---|---|---|---|
| ឧទាហរណ៍៖ ការចិញ្ចឹមមាន់ | ខែកុម្ភៈ ឆ្នាំ ២០២៤ | ផ្ទះខ្ញុំ | ដារ៉ា | ទ្រុង<br>មេមាន់៨ក្បាល<br>មាន់គក១ក្បាល<br>អាហារ/ទឹក... | ២៤០ ០០០ រៀល | មិនទាន់ដឹង |
| ឧទាហរណ៍៖ ធ្វើការក្នុងកសិដ្ឋាននៅចុងសប្តាហ៍ | ខែកុម្ភៈ ឆ្នាំ ២០២៤ | ក្នុងភូមិខ្ញុំ | ធីតា | គ្មាន | គ្មាន | កន្លះថ្ងៃ<br>១៥ ០០០ រៀល |
| | | | | | | |
| | | | | | | |
| | | | | | | |
| | | | | | | |

# ជំពូកទី៤

# តើខ្ញុំចំណាយប្រាក់ដោយឆ្លាតវៃដែរឬទេ?

## មេរៀនទី១ ជម្រើសក្នុងការចំណាយ

| | |
|---|---|
| | **រយៈពេល៖** ៤៥នាទី |
| | **ការត្រៀមខ្លួនរបស់គ្រូ មុនចូលបង្រៀន**<br>- អានមេរៀនទាំងមូល<br>- ថតចម្លងឯកសារចែក<br>- កាត់សន្លឹកកាតដែលមាននៅក្នុងឯកសារចែកទី៤.១.១ ដើម្បីឱ្យក្រុមនីមួយៗទទួលបានកាតមួយឈុត។<br>- ប្រមូលវត្ថុសម្រាប់រាប់ ចំនួន ២០ សម្រាប់ចែកសិស្សម្នាក់ៗ (សិស្សម្នាក់ បាន២០)។ |
| | **សម្ភារៈ ធនធានដែលចាំបាច់**<br>- រូបភាព ៤.១.១៖ ប័ណ្ណតម្រូវការ ឬការចង់បាន<br>- សន្លឹកកិច្ចការ ៤.១.២៖ ល្បែងសិក្សាចំណាយ<br>- សន្លឹកកិច្ចការ ៤.១.៣៖ កំណត់ត្រាចំណូល និងចំណាយប្រចាំឆ្នាំ<br>- ក្រដាសរ៉ាមផ្ទាំងធំ «ល្បែងសិក្សាចំណាយ»៖ ការដឹកជញ្ជូន<br>- វត្ថុសម្រាប់រាប់ចំនួន២០ សម្រាប់សិស្សម្នាក់ៗ (អាចជាសណ្តែក ឃ្លីបក្រដាស ថ្ម ឈើគូស)។ |
| | **លទ្ធផលសិក្សា៖**<br>បន្ទាប់ពីបញ្ចប់មេរៀននេះ សិស្សនឹងអាច៖<br>- ផ្តល់អាទិភាពលើកាតដែលតំណាងឱ្យការចង់បាន និងតម្រូវការ<br>- កំណត់ភាពខុសគ្នារវាងការចង់បាន និងតម្រូវការ<br>- ចាត់ថ្នាក់ភាពខុសគ្នារវាងការចង់បាន និងតម្រូវការ<br>- បំពេញកំណត់ត្រាចំណូល និងចំណាយប្រចាំឆ្នាំ។ |

**សេចក្តីផ្តើម៖**

គ្រូស្វាគមន៍សិស្ស ពិនិត្យវត្តមាន និងចាប់ផ្តើមមេរៀនដោយរំឭកប្រាប់សិស្សថាក្នុងមេរៀនមុន ប្អូនបានរៀនពីជម្រើសនៃការរកប្រាក់។ តើប្អូនរៀនបានអ្វីខ្លះពីមេរៀននោះ?

## សកម្មភាពសំខាន់ទី១៖ តម្រូវការ ឬការចង់បាន? (២០នាទី)

គ្រូប្រាប់ឱ្យសិស្សបង្កើតក្រុមមានគ្នា ៤-៦នាក់ ហើយចែករូបភាពប័ណ្ណ ៤.១.១៖ តម្រូវការ ឬការចង់បាន ដល់ក្រុមនីមួយៗ។ គ្រូគួរតែកាត់សន្លឹកកាតទាំងនេះ មុនម៉ោងរៀន ដើម្បីប្រាកដថាក្រុមនីមួយៗទទួលបានឈុតគ្រប់ចំនួន (២០សន្លឹក)។ បន្ទាប់មក គ្រូឱ្យសិស្សរៀបសន្លឹកកាតទៅតាមប្រភេទដូចខាងក្រោម៖

- សំខាន់ខ្លាំងបំផុត
- សំខាន់
- សំខាន់តិចតួចបំផុត។

បន្ទាប់មក គ្រូឱ្យក្រុមនីមួយៗចូលរួមជាមួយក្រុមមួយទៀត ហើយក្រុមថ្មីសម្រេចជ្រើសរើសយកសន្លឹកកាតចំនួន៦ដែលសំខាន់បំផុត។ បន្ទាប់មក ក្រុមទាំងអស់ចែករំលែកបញ្ជីកាតដែលសំខាន់បំផុតនោះជាមួយសិស្សទាំងអស់។

ក្នុងការធ្វើលំហាត់ចាត់ថ្នាក់នេះ គ្រូពន្យល់ថា មានតែសន្លឹកកាតបីសន្លឹកប៉ុណ្ណោះ អាចត្រូវបានចាត់ថា «សំខាន់បំផុត»ឬ«សំខាន់» ខណៈកាតនៅសល់ត្រូវចាត់ថា «សំខាន់តិចតួចបំផុត»។ ពេលសិស្សកំពុងចាត់អាទិភាពកាត ពួកគេក៏បង្ហាញថា តើពួកគេគិតថាកាតនោះតំណាងឱ្យ «តម្រូវការ» ឬ «ការចង់បាន» ដោយផ្អែកលើការយល់ដឹងអំពីពាក្យទាំងពីរនេះ។ ពួកគេសរសេរអក្សរ «N» នៅខាងក្រោយកាត ប្រសិនបើវាជាតម្រូវការ ឬ «W» ប្រសិនបើវាជាការចង់បាន។ គ្រូផ្តល់ពេលប្រហែល១០ ទៅ ១៥នាទីសម្រាប់សិស្សបញ្ចប់សកម្មភាពនេះ។

គ្រូពិភាក្សាសំណួរខាងក្រោមជាមួយសិស្ស៖

- ហេតុអ្វីបានជាប្អូនជ្រើសរើសកាតនេះជាតម្រូវការ ឬការចង់បាន? សូមផ្តល់ហេតុផលមួយ។
- គ្រូសរសេរចម្លើយរបស់សិស្សនៅលើក្តារខៀន បន្ទាប់មកជួយសម្រួលដល់សិស្សដើម្បីបង្កើតនិយមន័យនៃ «តម្រូវការ» និង «ការចង់បាន»។ គ្រូអាចប្រើចំណេះដឹងសំខាន់ៗខាងក្រោម ដើម្បីជួយដល់សិស្សបង្កើតនិយមន័យ។

### និយមន័យ៖

**តម្រូវការ៖** តម្រូវការសំដៅលើរបស់ដែលអ្នកត្រូវតែមានដើម្បីរស់បាន។ ម្ហូបអាហារ ទឹក សម្លៀកបំពាក់ និងទីជម្រក សុទ្ធតែជាតម្រូវការទាំងអស់។ ប្រសិនបើរាងកាយមនុស្សមិនមានរបស់ទាំងនេះទេ រាងកាយមិនអាចដំណើរការបានឡើយ ហើយយើងនឹងស្លាប់។

ស្រដៀងគ្នាដែរ បើចិត្តមនុស្ស មិនទទួលបានការអប់រំទេ វានឹងប្រែទៅជាខ្សត់ខ្សោយ។ ហេតុដូច្នេះហើយបានជាយើងនិយាយថា មនុស្សគ្រប់រូបមានសិទ្ធិទទួលបានការអប់រំព្រោះវាជា «តម្រូវការ»។

តម្រូវការត្រូវបានការពារជាសិទ្ធិនៅក្នុងអនុសញ្ញាស្តីពីសិទ្ធិកុមារ។ ការចង់បានមិនត្រូវបានការពារជាសិទ្ធិនោះទេ ព្រោះជាទូទៅវាមិនចាំបាច់ខ្លាំងសម្រាប់ការរស់រានមានជីវិត ការលូតលាស់ និងការអភិវឌ្ឍរបស់កុមារ។

**ការចង់បាន៖** ការចង់បានសំដៅលើរបស់ដែលអ្នកចង់មាន ប៉ុន្តែមិនចាំបាច់សម្រាប់ការរស់រានមានជីវិតនោះទេ។

តារាងខាងក្រោមបង្ហាញពីការបែងចែកប្រភេទសន្លឹកកាត យោងទៅតាម «ការចង់បាន» ឬ «តម្រូវការ»។

| តម្រូវការ | ការចង់បាន |
|---|---|
| - ទីជម្រកសមរម្យ<br>- អាហារដែលមានជីវជាតិ<br>- ការការពារពីការរំលោភបំពាន និងការមិនយកចិត្តទុកដាក់<br>- ការអប់រំ<br>- ការថែទាំសុខភាព<br>- ការប្រព្រឹត្តដាក់ដោយយុត្តិធម៌ និងមិនរើសអើង<br>- ខ្យល់អាកាសបរិសុទ្ធ<br>- ឱកាសចែករំលែកមតិយោបល់<br>- សួនកុមារ និងកន្លែងកម្សាន្ត<br>- ទឹកស្អាត<br>- ឱកាសដើម្បីប្រកាន់រកវប្បធម៌ ភាសា និងសាសនារបស់ខ្លួន។ | - សម្លៀកបំពាក់ទាន់សម័យបំផុត<br>- កង់មួយគ្រឿង<br>- ដំណើរកម្សាន្តថ្ងៃឈប់សម្រាក<br>- បន្ទប់គេងរបស់អ្នក<br>- កុំព្យូទ័រផ្ទាល់ខ្លួន<br>- ទូរទស្សន៍មួយ<br>- ស្តេរ៉េអូផ្ទាល់ខ្លួន<br>- ប្រាក់សម្រាប់ចាយតាមចិត្ត<br>- អាហាររហ័ស។ |

✦ ចំណុចមួយចំនួនដែលត្រូវបានចាត់ថ្នាក់ថា ជាការចង់បានអាចក្លាយជាតម្រូវការក្នុងកាលៈទេសៈជាក់លាក់ណាមួយ។ ឧទាហរណ៍៖ ទូរទស្សន៍ ឬកុំព្យូទ័រអាចជាប្រភពដ៏សំខាន់នៃការប្រមូល ឬចែករំលែកព័ត៌មានដែលអំណោយផលដល់ការការពារសិទ្ធិក្នុងការអភិវឌ្ឍសុខភាព និងការការពារពីអំពើហិង្សានិងការរំលោភបំពាន។

### សកម្មភាពសំខាន់ទី២៖ ជម្រើសក្នុងការចំណាយ (២៥នាទី)

សម្រាប់សកម្មភាពនេះ គ្រូគួរតែចាប់ផ្តើមដោយចែកសន្លឹកកិច្ចការ ៤.១.២៖ ល្បែងសិក្សាចំណាយ។ ដើម្បីប្រាកដថា សិស្សគ្រប់គ្នាយល់ពីរបៀបធ្វើលំហាត់នេះ គ្រូលើកឧទាហរណ៍ដល់សិស្ស ដោយប្រើក្រដាសវ៉ាមធំ ឬក្រដាសផ្ទាំងធំ៖ «ឧទាហរណ៍នៃល្បែងសិក្សាស្តីពីការចំណាយ» ដូចខាងក្រោម។

| **ចំណូលប្រចាំខែ** | **ចំនួនទឹកប្រាក់** |
|---|---|
| ប្រាក់សម្រាប់ចាយវាយ | |
| ប្រាក់ចំណូលផ្សេងទៀត៖ ប្រាក់ខែគ្រូបង្រៀន | **៣០០,០០០ រៀល** |
| **ចំណាយប្រចាំខែ** | |
| នៅផ្ទះៈល្វែងជាមួយមិត្តភក្តិ | ៦០,០០០ រៀល |
| ផ្សេងទៀត៖ អាវ | ៤០,០០០ រៀល |
| ឥណទានប្រចាំខែ | ២០,០០០ រៀល |
| ហ្វូមលាងមុខ | ១០,០០០ រៀល |
| គ្រឿងតុបតែងមុខ សំឡីអនាម័យ... | ១០,០០០ រៀល |
| ញ៉ាំនៅក្រៅផ្ទះ | ៨០,០០០ រៀល |
| សាំង | ២០,០០០ រៀល |
| **ចំណាយសរុប** | **២៤០,០០០ រៀល** |

បន្ទាប់មក គ្រូឱ្យសិស្សសួរសំណួរ ហើយគ្រូឆ្លើយដើម្បីប្រាកដថា សិស្សគ្រប់គ្នាយល់ពីរបៀបធ្វើលំហាត់នេះ។ នៅពេលសំណួរទាំងអស់ត្រូវបានឆ្លើយរួច គ្រូណែនាំសិស្សឱ្យបំពេញឯកសារចែកអំពីល្បែងសិក្សាចំណាយ។ សិស្សគួរតែមានពេលប្រហែល១០នាទី ដើម្បីបញ្ចប់លំហាត់នេះ។ **ចំណាំ៖** លំហាត់នេះត្រូវធ្វើជាលក្ខណៈបុគ្គល។

នៅពេលសិស្សកំពុងធ្វើលំហាត់នៅក្នុងសន្លឹកកិច្ចការ ៤.២.១ គ្រូដើរជុំវិញ ហើយត្រូវប្រាកដថាសិស្សយល់ពីអ្វីដែលពួកគេត្រូវធ្វើ។ នៅពេលដែលសិស្សបានបញ្ចប់ការចាត់ចែងប្រាក់ គ្រូប្រាប់ឱ្យសិស្សគណនាចំនួននៃការចំណាយសរុប និងសមតុល្យ។ ដូច្នេះ គ្រូសួរសំណួរខាងក្រោម៖

- តើលំហាត់នេះពិបាកត្រង់ណាខ្លះ?
- តើប្អូនត្រូវជ្រើសរើសអ្វីខ្លះ?
- តើប្អូនបានកំណត់អាទិភាពជម្រើសរបស់ប្អូន និងការចាត់ចែងប្រាក់ដោយរបៀបណា?
- តើប្រាក់ចំណូលរបស់ប្អូនគ្រប់គ្រាន់ដើម្បីបំពេញតម្រូវការសំខាន់បំផុតរបស់ប្អូនដែរឬទេ?

គ្រូគួរបញ្ចប់មេរៀនដោយពន្យល់ថា នៅពេលប្អូនចំណាយប្រាក់របស់ប្អូន ប្អូនគួរបែងចែកប្រាក់ទៅលើអ្វីដែលសំខាន់បំផុតឬរបស់ដែលជាអាទិភាពនៅក្នុងផែនការចំណាយ។ សូមចងចាំជានិច្ចថា ប្រសិនបើប្រាក់ចំណូលរបស់ប្អូនតិចជាងការចំណាយ ប្អូននឹងបាត់បង់ឬមានបំណុល ហើយវាអាចជំរុញឱ្យប្រឈមមុខនឹងភាពក្រីក្រ។ ប្រសិនបើប្រាក់ចំណូលរបស់ប្អូនលើសពីការចំណាយ វាអាចជំរុញឱ្យទទួលបានប្រាក់ចំណេញកាន់តែច្រើន ហើយប្អូនអាចសន្សំសម្រាប់តម្រូវការចាំបាច់ផ្សេងទៀត ដូចជាការថែទាំសុខភាពបន្ទាន់ ការទិញផ្ទះជាដើម។

ដើម្បីបញ្ចប់មេរៀនថ្ងៃនេះ គ្រូសួរសិស្សអំពីអ្វីដែលពួកគេបានរៀនសូត្រពីសកម្មភាពនេះ ហើយតើពួកគេអាចអនុវត្តអ្វីដែលបានរៀនសូត្រទៅក្នុងគ្រួសារ និងក្នុងសហគមន៍ដោយរបៀបណា? បន្ទាប់មក គ្រូចែកជូនសិស្សនូវសន្លឹកកិច្ចការ ៤.១.៣៖ កំណត់ត្រាចំណូល និងចំណាយប្រចាំឆ្នាំ។ គ្រូផ្តល់ឧទាហរណ៍ដល់សិស្សដូចដែលបានផ្តល់ជូនក្នុងតារាងខាងក្រោម។ គ្រូពន្យល់ថា សិស្សនឹងត្រូវបំពេញវាឱ្យបានទៀងទាត់ ដើម្បីអនុវត្តតាមថវិកាប្រចាំខែ និងប្រចាំឆ្នាំរបស់ពួកគេ។

## ឯកសារចែកទី ៤.១.៣៖ កំណត់ត្រាចំណូល និងចំណាយប្រចាំឆ្នាំ

**ការណែនាំ៖** តារាងខាងក្រោមគឺជាកំណត់ត្រាដើម្បីបំពេញប្រចាំខែជាមួយនឹងប្រាក់ចំណូល ចំណាយ ដើម្បីគណនាសមតុល្យ និងប្រាក់សមន្សំសរុប។

| ឆ្នាំ ................ | មករា | កុម្ភៈ | មីនា | មេសា | ឧសភា | មិថុនា | កក្កដា | សីហា | កញ្ញា | តុលា | វិច្ឆិកា | ធ្នូ |
|---|---|---|---|---|---|---|---|---|---|---|---|---|
| ចំណូល | | | | | | | | | | | | |
| ប្រាក់ចំណូល (ប្រាក់ខែ ប្រាក់ប្រចាំថ្ងៃ ។ល។) | ៨០,០០០ | ៨០,០០០ | | | | | | | | | | |
| ចំណូលផ្សេងទៀតរកបានពីការលក់វត្ថុកែច្នៃ | | ១០,០០០ | | | | | | | | | | |
| ចំណាយ | | | | | | | | | | | | |
| អាហារ | ១០,០០០ | ៥០,០០០ | | | | | | | | | | |
| ផ្ទះ និងឧបករណ៍ប្រើប្រាស់ | ៥,០០០ | ៥,០០០ | | | | | | | | | | |
| សម្លៀកបំពាក់ | ០ | ០ | | | | | | | | | | |
| ការចំណាយលើសុខភាព | ០ | ០ | | | | | | | | | | |
| ការវិនិយោគលើការអប់រំ | ១,០០០ | ១,០០០ | | | | | | | | | | |
| សកម្មភាពកម្សាន្ត | ១,០០០ | ១,០០០ | | | | | | | | | | |
| ចំណាយសរុប | ១៧,០០០ | ៥៧,០០០ | | | | | | | | | | |
| ***សមតុល្យនៅសល់*** *(ចំណូល - ចំណាយ)* | ២៣,០០០ | - ៧,០០០ | | | | | | | | | | |
| ***នៅក្នុងគណនីរបស់ខ្ញុំនៅចុងខែ*** *(សមតុល្យនៅសល់ពីខែមុន + សមតុល្យនៅសល់ខែបច្ចុប្បន្ន)* | ២៣,០០០ | ១៦,០០០ | | | | | | | | | | |

## រូបភាព ៤.១.១៖ កាតបង្ហាញពីតម្រូវការ និងការចង់បាន

**ការណែនាំសម្រាប់គ្រូ៖** គ្រូកាត់សន្លឹកកាតនីមួយៗចេញ ដើម្បីចែកដល់សិស្ស។ ត្រូវប្រាកដថា ក្រុមទាំងអស់នៅក្នុងថ្នាក់ទទួលបានកាតគ្រប់គ្រាន់។



ឱកាសចែករំលែកមតិយោបល់



ប្រាក់សម្រាប់ចាយតាមចិត្ត



ទឹកស្អាត



បន្ទប់គេងរបស់អ្នក



កុំព្យូទ័រផ្ទាល់ខ្លួន



ការប្រព្រឹត្តដាក់ដោយយុត្តិធម៌ និងមិនរើសអើង



ខ្យល់អាកាសបរិសុទ្ធ



ស្តេរ៉េអូផ្ទាល់ខ្លួន



អាហាររហ័ស



សួនកុមារ និងកន្លែងកម្សាន្ត



ទូរទស្សន៍មួយ



ឱកាសដើម្បីប្រកាន់រក្សវប្បធម៌ ភាសា និងសាសនារបស់ខ្លួន



ការថែទាំសុខភាព



កង់មួយគ្រឿង



ទីជម្រកសមរម្យ



សម្លៀកបំពាក់ទាន់សម័យបំផុត



ដំណើរកម្សាន្តថ្ងៃឈប់សម្រាក



អាហារដែលមានជីវជាតិ



ការការពារពីការរំលោភបំពាន និង
ការមិនយកចិត្តទុកដាក់



ការអប់រំ

## សន្លឹកកិច្ចការ ៤.១.២៖ ល្បែងសិក្សាស្តីពីការចំណាយ

**ការណែនាំ៖** តារាងខាងក្រោមបង្ហាញពីការចំណាយទូទៅដែលមនុស្សគ្រប់គ្នាត្រូវបំពេញឱ្យបានដើម្បីរស់នៅក្នុងសង្គមប្រកបដោយប្រសិទ្ធភាព។ នៅក្រោមប្រភេទនីមួយៗ មានជម្រើសជាក់លាក់ដែលអាចជួយបំពេញតម្រូវការទាំងនេះ។ ប្អូនត្រូវបំពេញលំហាត់ល្បែងសិក្សាស្តីពីការចំណាយប្រចាំខែជាមួយនឹងចំណូលនិងចំណាយ។

| **ចំណូលប្រចាំខែ** | **ចំនួនទឹកប្រាក់** |
|---|---|
| ប្រាក់សម្រាប់ចំណាយ | |
| ប្រាក់ចំណូលផ្សេងទៀត៖ ………………… | |
| **ចំណាយប្រចាំខែ** | |
| **លំនៅដ្ឋាន**<br>រស់នៅជាមួយឪពុកម្តាយ<br>នៅបន្ទប់ជាមួយមិត្តម្នាក់ | |
| **សម្លៀកបំពាក់**<br>មិនទិញអ្វីសោះ<br>អាវយឺត<br>ផ្សេងៗ……………………………………… | |
| **ទូរសព្ទ**<br>គ្មាន<br>ឥណទានប្រចាំខែ | |
| **ការថែទាំខ្លួនឯង**<br>គ្មាន<br>គ្រឿងតុបតែងមុខ<br>ហ្វមលាងមុខ<br>ផ្សេងៗ........................ | |
| **អាហារ**<br>តែងតែញ៉ាំនៅផ្ទះ<br>អាហារសម្រន់ | |
| **ការកម្សាន្ត**<br>គ្មាន<br>ភាពយន្ត<br>កន្លែងលេងវីដេអូហ្គេម | |
| **មធ្យោបាយធ្វើដំណើរ**<br>ដើរឬជិះកង់<br>សាំង | |
| **ការចំណាយសរុប** | |
| **សមតុល្យ** = (ការចំណាយសរុប – ប្រាក់ចំណូលសរុប) | |

## សន្លឹកកិច្ចការ ៤.១.៣៖ កំណត់ត្រាចំណូល និងចំណាយប្រចាំឆ្នាំ

**ការណែនាំ៖** នេះគឺជាកំណត់ត្រាប្រចាំខែ (ប្រាក់ចំណូល ចំណាយ និងសមតុល្យ )។ ឧទាហរណ៍គំរូបានផ្ដល់ជាគំនិតនៅខាងក្រោម។ ចូរប្អូនបំពេញកំណត់ត្រាចំណូល-ចំណាយរបស់ប្អូនពីខែមីនា ដើម្បីឱ្យយល់កាន់តែច្បាស់ពីរបៀបបំពេញ។

| ឆ្នាំ.................. | មករា | កុម្ភៈ | មីនា | មេសា | ឧសភា | មិថុនា | កក្កដា | សីហា | កញ្ញា | តុលា | វិច្ឆិកា | ធ្នូ |
|---|---|---|---|---|---|---|---|---|---|---|---|---|
| **ចំណូល** | | | | | | | | | | | | |
| ប្រាក់ចំណូល (ប្រាក់ខែ ប្រាក់ប្រចាំថ្ងៃ។ល។) | ៤០,០០០ | ៤០,០០០ | | | | | | | | | | |
| ចំណូលផ្សេងទៀតរកបានពី<br>ឧ. លក់វត្ថុកែច្នៃ........................................ | | ១០,០០០ | | | | | | | | | | |
| **ចំណាយ** | | | | | | | | | | | | |
| អាហារ | ១០,០០០ | ៥០,០០០ | | | | | | | | | | |
| ផ្ទះ និងឧបករណ៍ប្រើប្រាស់ | ៥,០០០ | ៥,០០០ | | | | | | | | | | |
| សម្លៀកបំពាក់ | ០ | ០ | | | | | | | | | | |
| ការចំណាយលើសុខភាព | ០ | ០ | | | | | | | | | | |
| ការវិនិយោគលើការអប់រំ | ១,០០០ | ១,០០០ | | | | | | | | | | |
| សកម្មភាពកម្សាន្ត | ១,០០០ | ១,០០០ | | | | | | | | | | |
| ផ្សេងៗ៖.......................... | -- | -- | | | | | | | | | | |
| **ចំណាយសរុប** | ១៧,០០០ | ៥៧,០០០ | | | | | | | | | | |
| *សមតុល្យនៅសល់ (ចំណូល - ចំណាយ)* | ២៣,០០០ | - ៧,០០០ | | | | | | | | | | |
| *នៅក្នុងគណនីរបស់ខ្ញុំនៅចុងខែ (សមតុល្យនៅសល់ពីខែមុន + សមតុល្យនៅសល់ខែបច្ចុប្បន្ន)* | ២៣,០០០ | ១៦,០០០ | | | | | | | | | | |

# ជំពូកទី៥

# ការផ្ដល់ត្រឡប់មកកាន់សហគមន៍វិញ

## មេរៀនទី១ តម្រូវការរបស់សហគមន៍អ្នក

| | |
|---|---|
| | **រយៈពេល៖** ៤៥នាទី |
| | **ការត្រៀមខ្លួនរបស់គ្រូ មុនចូលបង្រៀន**<br>- អានមេរៀនទាំងមូល។ |
| | **សម្ភារៈ ធនធានដែលចាំបាច់**<br>- ក្រដាសពណ៌ និងហ្វឺត។ |
| | **លទ្ធផលសិក្សា៖**<br>បន្ទាប់ពីបញ្ចប់មេរៀននេះ សិស្សនឹងអាច៖<br>- ផ្ដល់កំណត់បានលក្ខណៈសម្បត្តិនៃពលរដ្ឋសកម្ម<br>- ចែករំលែកបទពិសោធន៍សកម្មភាពផ្សេងៗដែលឆ្លើយតបនឹងពលរដ្ឋសកម្ម<br>- កំណត់តម្រូវការរបស់សហគមន៍ដើម្បីចូលរួមដោះស្រាយ។<br>- មានទំនុកចិត្តក្នុងការប្រាស្រ័យទាក់ទងជាមួយប្រជាជនក្នុងសហគមន៍។ |

### សេចក្ដីផ្ដើម៖

គ្រូចាប់ផ្ដើមវគ្គ ដោយពន្យល់ថា នៅក្នុងមេរៀននេះ សិស្សនឹងឆ្លុះបញ្ចាំងពីអ្វីដែលពួកគេអាចធ្វើបានដើម្បីជួយដល់សហគមន៍។ ការជួយអ្នកដទៃ គឺជាផ្នែកមួយដ៏សំខាន់ក្នុងជីវិតយើងជាមនុស្សម្នាក់ៗ ហើយរួមចំណែកដល់ការកសាងសហគមន៍ និងសង្គម។ យើងទាំងអស់គ្នារស់នៅក្នុងភូមិដែលមានមនុស្សជាច្រើននាក់រស់នៅ។ មនុស្សមួយចំនួនត្រូវការជំនួយច្រើនជាងអ្នកដទៃទៀត ហើយថ្ងៃនេះ យើងនឹងនិយាយអំពីរបៀបដែលយើងអាចជួយអ្នកដទៃ និងហេតុអ្វីបានជាវាសំខាន់ក្នុងការជួយអ្នកដទៃ។ នៅក្នុងវគ្គសិក្សាអក្ខរកម្មហិរញ្ញវត្ថុ រហូតមកដល់ពេលនេះ សិស្សបានសិក្សាពីទិដ្ឋភាពជាច្រើននៃការសន្សំ និងការចំណាយ ហើយឥឡូវនេះ ពួកគេនឹងចាប់ផ្ដើមសិក្សាពីរបៀបសងគុណត្រឡប់ទៅកាន់សហគមន៍វិញ និងក្លាយខ្លួនជាពលរដ្ឋសកម្ម។

### សកម្មភាពសំខាន់ទី១៖ ពលរដ្ឋសកម្ម (២០នាទី)

គ្រូសរសេរពាក្យ «ពលរដ្ឋសកម្ម» នៅលើក្ដារខៀន។ សួរសិស្សថា៖ តើពាក្យ «ពលរដ្ឋសកម្ម» មានន័យដូចម្ដេចសម្រាប់ប្អូន? តើ «ពលរដ្ឋសកម្ម» ត្រូវធ្វើអ្វីខ្លះ?

**គំនិតសម្រាប់គ្រូ៖** សិស្សអាចប្រហែលជារៀនអំពីពាក្យនេះរួចមកហើយនៅក្នុងមេរៀនសិក្សាសង្គម ឬធ្លាប់បានឮពាក្យនេះនៅក្នុងគ្រួសារនៃសហគមន៍។

គ្រូបង្ហាញលក្ខណៈសម្បត្តិពលរដ្ឋសកម្មនៅលើក្ដារខៀន រួចឱ្យសិស្សមួយចំនួនអានអំពីគុណសម្បត្តិឱ្យឮៗ (ត្រូវចាំថា កុំហៅតែសិស្សពូកែឱ្យអាន ត្រូវហៅទាំងសិស្សប្រុស និងសិស្សស្រី)។ សួរថា តើប្អូនមានសំណួរទាក់ទងនឹងអត្ថន័យនៃពាក្យណាមួយដែរទេ។

| លក្ខណៈសម្បត្តិពលរដ្ឋសកម្ម |
|---|
| ១- ពលរដ្ឋសកម្មជំរុញឱ្យមានការផ្លាស់ប្ដូរដោយខ្លួនឯង។ |
| ២- ពលរដ្ឋសកម្មព្យាយាមកសាងការជឿទុកចិត្តនៅក្នុង និងរវាងសហគមន៍។ |
| ៣- ពលរដ្ឋសកម្មត្រូវបានលើកទឹកចិត្ត និងពង្រឹងភាពអង់អាចដើម្បីធ្វើឱ្យមានការផ្លាស់ប្ដូរ។ |
| ៤- ពលរដ្ឋសកម្មយកចិត្តទុកដាក់ចំពោះសហគមន៍មូលដ្ឋាន ហើយចង់ធ្វើឱ្យសហគមន៍ក្លាយជាកន្លែងល្អប្រសើរជាងមុន។ |
| ៥- ពលរដ្ឋសកម្មជួយជនដែលងាយរងគ្រោះបំផុត។ |
| ៦- ពលរដ្ឋសកម្មតស៊ូប្រឆាំងនឹងភាពអយុត្តិធម៌។ |
| ៧- ជឿជាក់លើការគាំទ្រសមភាព និងភាពចម្រុះ។ |

គ្រូសួរថា «តើប្អូនបានបង្ហាញ ឬមានលក្ខណៈសម្បត្តិទាំងនេះតាំងពីពេលណា?» ឱ្យសិស្សពិភាក្សាមួយដៃគូ ហើយចែករំលែកបទពិសោធ នៅពេលពួកគេធ្លាប់បានបង្ហាញពីលក្ខណៈសម្បត្តិទាំងនេះ មួយឬច្រើន។

គ្រូលើកឡើងថា «ចូរគិតអំពីពេលវេលាណាមួយដែលប្អូនធ្លាប់បង្ហាញលក្ខណៈសម្បត្តិមួយ ឬច្រើននៃ "ពលរដ្ឋសកម្ម"» ហើយបន្ថែមថា «ចូរគិតថាខ្លួនឯងជាពលរដ្ឋសកម្ម... តើប្អូនកំពុងធ្វើអ្វី? ... តើប្អូនមានអារម្មណ៍បែបណា?" ទុកពេលឱ្យសិស្សគិតរយៈពេលពីរ ឬបីនាទីអំពីសំណួរនេះ។



ឱ្យសិស្សចែករំលែកគំនិតរបស់ពួកគេដោយប្រើបាល់ក្រដាស។ ការណែនាំ៖ «យើងនឹងបោះបាល់ជុំវិញរង្វង់។ នៅពេលប្អូនកាន់បាល់នោះ គ្រូចង់ឱ្យប្អូនចែករំលែកបទពិសោធន៍ក្នុងការក្លាយជា "ពលរដ្ឋសកម្ម"»។ សូមបោះបាល់ជុំវិញ ហើយលើកទឹកចិត្តសិស្សម្នាក់ៗឱ្យចែករំលែកគំនិតនៅពេលគាត់ ឬនាងធ្លាប់បានបង្ហាញលក្ខណៈសម្បត្តិយ៉ាងហោចណាស់មួយ។

គ្រូបន្ត ហើយពន្យល់ថា អ្នកណាក៏អាចក្លាយជា ពលរដ្ឋសកម្មបានដែរ។ ពលរដ្ឋសកម្ម ភ្ជាប់ទំនាក់ទំនងជាមួយមនុស្សដទៃ ធ្វើសកម្មភាព គាំទ្រអ្នកដទៃ ធ្វើឱ្យគំនិតរបស់ពួកគេក្លាយជាការពិត។

ភាពជាពលរដ្ឋសកម្ម គឺនិយាយអំពីការធ្វើឱ្យសិស្សក្លាយជាមនុស្សល្អប្រសើរជាងមុន និងធ្វើឱ្យមានការផ្លាស់ប្ដូរដល់សហគមន៍របស់ពួកគេ នៅថ្នាក់ស្រុក ថ្នាក់ជាតិ និងកម្រិតសកលលោក។

## សកម្មភាពសំខាន់ទី២៖ គំនិតទៅជាសកម្មភាព៖ តើខ្ញុំអាចធ្វើអ្វីបាន? (២០នាទី)

គ្រូចាប់ផ្ដើមដោយពន្យល់ថា ជំហានទីមួយ ក្នុងការជួយសហគមន៍ និងក្លាយជាពលរដ្ឋសកម្ម គឺត្រូវកំណត់ឱ្យឃើញបញ្ហា ឬតម្រូវការនៅក្នុងសហគមន៍ដែលប្អូនអាចជួយបាន។ សកម្មភាពជួយទាំងនោះអាចជា៖ ការផ្ដល់ពេលវេលា ផ្ដល់ថវិកា ចែករំលែកចំណេះដឹង ឬផ្ដល់ជារបស់របរផ្សេងៗដល់មនុស្សដែលត្រូវការ។

គ្រូគូសតារាងខាងក្រោមនៅលើក្ដារខៀន ហើយសុំឱ្យសិស្សគិត សម្រាប់សកម្មភាពនីមួយៗដែលអាចធ្វើបាន តើអ្នកណាអាចទទួលបានអត្ថប្រយោជន៍ពីវា។ ឧទាហរណ៍៖ តើអ្នកណាអាចទទួលបានអត្ថប្រយោជន៍ ប្រសិនបើខ្ញុំលះបង់ពេលវេលាខ្លះរបស់ខ្ញុំសម្រាប់គាត់ ឬនាង? តើអ្នកណានឹងទទួលបានផលប្រយោជន៍ច្រើនជាងគេ ប្រសិនបើខ្ញុំឱ្យប្រាក់(ថវិកា)។ល។

**ការណែនាំ៖** ១) ឱ្យសិស្សពិភាក្សាជាក្រុមតូចៗ។ ២) ផ្ដល់ឱ្យពួកគេនូវក្រដាសកត់ចំណាំ អាចសរសេរគំនិតរបស់ខ្លួន។ ៣) ឱ្យសិស្សយកក្រដាសទាំងនោះមកបិទលើក្ដារខៀន។ ៤) វិភាគ និងចាត់ថ្នាក់សកម្មភាពស្រដៀងគ្នាក្នុងក្រុមតែមួយ។

| **សកម្មភាពដែលអាចធ្វើបាន** | **ឱ្យទៅអ្នកណា?** |
|---|---|
| ផ្ដល់ពេលវេលា | |
| ផ្ដល់ប្រាក់ | |
| ចែករំលែកចំណេះដឹង | |
| ផ្ដល់ជារបស់របរ | |

តារាងខាងក្រោមជាចម្លើយដែលអាចឆ្លើយបានសម្រាប់គ្រូ។

| **សកម្មភាពដែលអាចធ្វើបាន** | **ទៅឱ្យអ្នកណា?** |
|---|---|
| **ផ្ដល់ពេលវេលា** | មនុស្សចាស់ មនុស្សមានជំងឺ មិត្តភក្ដិ កុមារតូចៗ (ឧ. ហ្វឹកហាត់ក្រុមបាល់ទាត់ រៀបចំក្លឹបអំណាន។ល។)។ |
| **ផ្ដល់ប្រាក់** | អង្គការដែលមានមូលដ្ឋាននៅសហគមន៍ ដែលជួយដល់មនុស្សខ្វះខាត មិត្តភក្ដិដែលទទួលបានអាហារូបករណ៍ គ្រួសារដែលត្រូវការជំនួយបំផុត។ |
| **ចែករំលែកចំណេះដឹង** | សហគមន៍ ដើម្បីឈ្វេងយល់អំពីប្រធានបទសំខាន់ៗដូចជា ការប្រែប្រួលអាកាសធាតុ ជំងឺគ្រុនចាញ់ ការទប់ស្កាត់គ្រោះថ្នាក់ចរាចរណ៍ មនុស្សចាស់របៀបប្រើប្រាស់អ៊ីនធឺណិត មិត្តភក្ដិដើម្បីជួយគាំទ្រពួកគេក្នុងការសិក្សា។ |
| **ផ្ដល់ជារបស់របរ** | នរណាម្នាក់នៅក្នុងសហគមន៍ដែលត្រូវការសម្លៀកបំពាក់ អាហារ ឬរបស់របរផ្សេងៗ។ ផ្ដល់របស់លេងដល់ក្មេងៗដែលអត់មាន។ បរិច្ចាគសៀវភៅទៅបណ្ណាល័យ ឬចែករំលែកជាមួយមិត្តភក្ដិ/បង្កើតកន្លែងមួយដើម្បីចែករំលែកសៀវភៅនៅក្នុងសហគមន៍។ |

**ការឆ្លុះបញ្ចាំង៖** គ្រូពន្យល់ថា អ្វីដែលយើងបានពិភាក្សា គឺជាឧទាហរណ៍ទាំងអស់នៃសកម្មភាពដែលយើងអាចធ្វើបានដើម្បីផ្ដល់ឱ្យសហគមន៍យើងវិញ។ សហគមន៍នីមួយៗមានលក្ខណៈពិសេសដោយឡែក និងមានតម្រូវការផ្ទាល់ខ្លួនខុសគ្នា។ មានវិធីផ្សេងៗ និងមនុស្សជាច្រើនដែលអាចទទួលបានអត្ថប្រយោជន៍ពីជំនួយរបស់យើងនៅក្នុងសហគមន៍។

គ្រូបន្ត ហើយពន្យល់ថា មានវិធីជាច្រើនក្នុងការជួយអ្នកដទៃ ហើយយើងអាចចាត់ថ្នាក់សកម្មភាពទាំងនោះក្នុង៣ ប្រភេទផ្សេងគ្នា ប៉ុន្តែវាមានលក្ខណៈបំពេញបន្ថែមឱ្យគ្នា៖ ការបរិច្ចាគ ការស្ម័គ្រចិត្ត និងការរៃអង្គាសប្រាក់៖

| |
|---|
| - **ការបរិច្ចាគ៖** ការបរិច្ចាគ គឺនៅពេលដែលប្អូនឱ្យរបស់របររបស់ប្អូនដើម្បីជួយអ្នកដទៃ។ |
| - **ការស្ម័គ្រចិត្ត៖** ការស្ម័គ្រចិត្តគឺនៅពេលដែលប្អូនផ្តល់ពេលវេលារបស់ប្អូនដើម្បីជួយអ្នកដទៃ។ |
| - **ការរៃអង្គាសប្រាក់៖** ការរៃអង្គាសថវិកា គឺជាពេលដែលប្អូនប្រមូលប្រាក់ដើម្បីជួយអ្នកដទៃ។ |

ជាចុងក្រោយ គ្រូពន្យល់ថា នៅក្នុងមេរៀនបន្ទាប់ យើងនឹងរៀនពីរបៀបវិភាគបញ្ហា និងស្វែងរកដំណោះស្រាយដែលអាចធ្វើបានសម្រាប់ឱ្យប្អូនចាត់វិធានការ។ យើងនឹងឈ្វេងយល់ពីឧទាហរណ៍ពីសាលារៀនផ្សេងទៀតដែលអាចបំផុសគំនិតប្អូន!

## កិច្ចការផ្ទះ៖

មុនពេលចូលមេរៀនបន្ទាប់ នេះជាកិច្ចការសម្រាប់ប្អូន៖ ធ្វើជាមួយដៃគូ។ ចូរគិតអំពីបញ្ហាចំនួន ២-៣ នៅក្នុងសហគមន៍របស់ប្អូនដែលប្អូនចង់ជួយដោះស្រាយ។ ចូរសរសេរគំនិតរបស់ប្អូននៅលើក្រដាស។ ប្អូននឹងចែករំលែកជាមួយគ្រូ។ យើងនឹងចែករំលែកគំនិតរបស់យើងក្នុងមេរៀនបន្ទាប់។ សូមកុំបារម្ភ គំនិតទាំងអស់ត្រូវបានស្វាគមន៍នៅក្នុងថ្នាក់យើង។

# មេរៀនទី២ ការបង្កើតគម្រោងតូចមួយសម្រាប់សហគមន៍យើង

| | |
|---|---|
|  | **រយៈពេល៖** ១៣៥នាទី |
|  | **ការត្រៀមខ្លួនរបស់គ្រូ មុនចូលបង្រៀន**<br>- អានមេរៀនទាំងមូល<br>- ថតចម្លងឯកសារចែក ៥.១.១៖ ការរៀបចំមុននឹងសម្ភាសន៍<br>- ថតចម្លងឯកសារចែក ៥.១.២ក៖ ការវិភាគព័ត៌មានដើម្បីកំណត់រកដំណោះស្រាយ<br>- ថតចម្លងឯកសារចែក ៥.១.២ខ៖ ការវិភាគព័ត៌មានតាមរយៈដើមឈើបញ្ហា និងដើមឈើវត្ថុបំណង។ |
|  | **សម្ភារៈ ធនធានដែលចាំបាច់**<br>- ឯកសារចែក ៥.១.១៖ ការរៀបចំមុននឹងសម្ភាសន៍<br>- ឯកសារចែក ៥.១.២ក៖ ការវិភាគព័ត៌មានដើម្បីកំណត់រកដំណោះស្រាយ<br>- ឯកសារចែក ៥.១.២ខ៖ ការវិភាគព័ត៌មានតាមរយៈដើមឈើបញ្ហា និងដើមឈើវត្ថុបំណង<br>- ឯកសារចែក ៥.១.៣៖ ការបង្កើតផែនការផ្សព្វផ្សាយដើម្បីបង្ហាញដំណោះស្រាយ<br>- ក្រដាសរ៉ាម A4។ |
|  | **លទ្ធផលសិក្សា៖**<br>បន្ទាប់ពីបញ្ចប់មេរៀននេះ សិស្សនឹងអាច៖<br>- បង្ហាញដល់មិត្តរួមថ្នាក់នូវដំណោះស្រាយដែលអាចធ្វើបានសម្រាប់ដោះស្រាយបញ្ហាដែលពួកគេបានកំណត់<br>- ប្រមូលធនធានដើម្បីជួយគាំទ្រសហគមន៍។ |

## សេចក្តីផ្តើម៖

គ្រូស្វាគមន៍សិស្ស និងពិនិត្យរដ្ឋបាលថ្នាក់ ។ តើប្អូនរៀនបានអ្វីខ្លះពីមេរៀនមុន? គ្រូសុំឱ្យសិស្សចែករំលែកលទ្ធផលនៃការងារជាគូនៅពេលបានធ្វើកិច្ចការផ្ទះដែលក្នុងនោះពួកគេត្រូវវាយបញ្ចីបញ្ហា ១-២ ដែលពួកគេអាចគិតបាននៅក្នុងសហគមន៍។ គ្រូសរសេរបញ្ហាទាំងនោះនៅលើក្តារខៀន។ គ្រូឆ្លុះបញ្ចាំងជាមួយសិស្សថាមានបញ្ហា និងតម្រូវការជាច្រើននៅក្នុងសហគមន៍ ។

## សកម្មភាពសំខាន់ទី១៖ ការយល់ដឹងពីវិធីសាស្ត្រ៦ដំណាក់កាលព័ត៌មាន (៣០នាទី)

គ្រូបង្ហាញវិធីសាស្ត្រ៦ដំណាក់កាលនៅលើក្តារខៀន និងឱ្យសិស្សស្ម័គ្រចិត្តអានជំហាននីមួយៗឱ្យឮៗ។



គ្រូចាប់ផ្តើមអនុវត្តសកម្មភាពបង្រៀនតាមបែបដំណើរវិចិត្រសាល (Gallery Walk) ។ គ្រូចែកសិស្សជា៦ក្រុមដែលមានសមាជិកស្មើគ្នា (ករណីមិនស្មើគ្នាអាចក្រុមណាមួយមានចំនួនសមាជិកលើស) បន្ទាប់មកឱ្យប្រធានបទដូចខាងក្រោម៖ បញ្ជាក់ក្រុមនីមួយៗត្រូវសរសេរនៅលើក្រដាសផ្ទាំងធំ រូបភាព ឬបង្ហាញព័ត៌មានបែបផែនទីគំនិត។




- ក្រុមទី១ និងទី៤៖ ពិភាក្សាពីការយល់ដឹងពីបញ្ហា និងការប្រមូលព័ត៌មានទាក់ទងនឹងបញ្ហា៖ សិស្សអាចគូរផែនទីគំនិតដោយសរសេរឃ្លានៅចំកណ្តាលរង្វង់ដូចជា បញ្ហាក្នុងសហគមន៍ និងលើកបញ្ហាជាច្រើនដែលកើតមានជាមួយក្រុម។ ចំពោះការប្រមូលព័ត៌មានទាក់ទងនឹងបញ្ហា គ្រូត្រូវជួយសម្របសម្រួលគំនិតសិស្ស ដោយកំណត់យកបញ្ហាមួយដូចជា "កុមារប្រឈមមុខបោះបង់ការសិក្សាកម្រិតអនុវិទ្យាល័យ" និងឱ្យក្រុមបង្កើតសំណួរទាក់ទងនឹងបញ្ហានេះ។
- ក្រុមទី២ និងទី៥៖ ពិភាក្សាពីការវិភាគព័ត៌មានដើម្បីរកដំណោះស្រាយ៖ គ្រូផ្តល់ឯកសារចែក ៥.១.២ ដល់ក្រុម និងធ្វើការវិភាគតាមដើមឈើបញ្ហា សូមមើលឯកសារចែក ៥.១.៣ ។
- ក្រុមទី៣ និងទី៦៖ បង្កើតផែនការផ្សព្វផ្សាយដើម្បីបង្ហាញដំណោះស្រាយ
- បន្ទាប់ពីក្រុមនីមួយៗពិភាក្សា និងសរសេរព័ត៌មាន ឬមានរូបភាព ឬសរសេរបែបផែនទីគំនិតនៅលើផ្ទាំងក្រដាសធំរួចរាល់។

## ការឆ្លុះបញ្ចាំង៖ ១០នាទី

តើប្អូនរៀនសូត្របានអ្វីខ្លះក្នុងថ្ងៃនេះ? តើប្អូននឹងយកចំណេះដឹងនេះចែករំលែកមិត្តភក្តិ ក៏ដូចជាក្រុមគ្រួសាររបស់ប្អូនដែរឬទេ? ហេតុអ្វី?

## សកម្មភាពសំខាន់ទី២៖ អនុវត្តសកម្មភាពដំណើរវិចិត្រសាលា (៣៥នាទី)

- គ្រូត្រូវរៀបចំ និងជ្រើសរើសអ្នកធ្វើបទបង្ហាញសម្រាប់ក្រុមនីមួយ និងរង់ចាំផ្តល់ព័ត៌មានដល់សមាជិកក្រុមផ្សេងដើម្បីឈ្វេងយល់ពីព័ត៌មានក្រុមដទៃ។ ចំណែកឯសមាជិកក្រុមដែលនៅសល់គ្រូត្រូវរៀបចំឱ្យពួកគេដើរទៅកាន់ក្រុមផ្សេង។ គ្រូត្រូវធានាថា សិស្សទាំងអស់គ្នាបានស្តាប់ការធ្វើបទបង្ហាញគ្រប់ប្រធានបទ។ ឧ. ក្រុមទី១មានសមាជិកសរុប៦នាក់ ក្រុមទី២៖៦នាក់ និងក្រុមទី៣៖៦នាក់ និងមានប្រធានបទ៣ខុសៗគ្នា។ ប្រធានក្រុមធ្វើបទបង្ហាញមកពីក្រុមទី១ អាចមានចំនួនពីរនាក់ឈរនៅកន្លែងរបស់ខ្លួន ចំណែកឯសមាជិកនៅសល់ចំនួន៤នាក់ទៀត គ្រូត្រូវជ្រើសរើស២នាក់ទៅកាន់ក្រុមទី២ និង២នាក់ទៀតទៅកាន់ក្រុមទី៣។ ចំពោះក្រុមទី២ និងទី៣ ត្រូវអនុវត្តតាមលំនាំការចាត់ចែងដូចក្រុមទី១។
- នៅពេលដែលការធ្វើបទបង្ហាញចាប់ផ្តើម គឺគ្រប់ក្រុមចាប់ផ្តើមចែករំលែកព័ត៌មាន គ្រូត្រូវគ្រប់គ្រងពេលវេលាឱ្យបានល្អ (ក្រុមនីមួយអាចមានពេល៥ ឬ១០នាទីអាស្រ័យលើពេលវេលាគ្រប់គ្រាន់) ហើយនៅដល់ម៉ោងបញ្ចប់ គ្រូត្រូវឱ្យសិស្សទាំងអស់ក្នុងក្រុមនីមួយៗផ្លាស់ទីដោយចាប់ផ្តើមពីក្រុមទី១ ត្រូវផ្លាស់ទី

ទៅក្រុមទី២ ហើយក្រុមទី២ត្រូវផ្លាស់ប្ដូរទៅក្រុមទី៣ និងក្រុមទី៣ត្រូវផ្លាស់ទីទៅក្រុមទី១វិញ។ **ចំណាំ៖** ក្រុមនីមួយៗផ្លាស់ទីទៅកាន់ក្រុមផ្សេងៗ ដោយគ្រូត្រូវធានាថា មានអ្នកធ្វើបទបង្ហាញតំណាងប្រធានបទរបស់ខ្លួន។

- ក្រុមនីមួយៗត្រូវអនុវត្តសកម្មភាពដំណើរវិចិត្រសាលដល់ចប់ ដោយក្រុមនីមួយៗបានស្ដាប់ និងសួរសំណួរបន្ថែម ឬចែករំលែកគំនិតប្រសិនបើមាន។

## សកម្មភាពសំខាន់ទី៣៖ ការឆ្លុះបញ្ចាំង និងការវាយតម្លៃ (១០នាទី)

ដើម្បីបង្កើតគម្រោងមួយតើប្អូនគួររៀបចំអ្វីខ្លះ? តាមរយៈសកម្មភាពដំណើរវិចិត្រសាលា តើប្អូនរៀនសូត្របានអ្វីខ្លះ? តើប្អូនចូលចិត្តសកម្មភាពនេះដែរឬទេ? ហេតុអ្វី?

## សេចក្ដីសន្និដ្ឋាន

- សិស្សទាំងអស់ក្លាយជាពលរដ្ឋសកម្ម។
- ប្អូនៗអាចជួយសហគមន៍ ដោយចាប់ផ្ដើមពីការកំណត់អត្តសញ្ញាណបញ្ហា/តម្រូវការរបស់សហគមន៍។
- នៅពេលដែលយើងយល់ពីបញ្ហានោះ យើងអាចស្វែងរកដំណោះស្រាយដែលអាចធ្វើបាន ដោយប្រើប្រាស់ដំណើរការ៦ជំហានដើម្បីបង្កើតគម្រោងរបស់យើង។ តាមរយៈការផ្សព្វផ្សាយសកម្មភាពរបស់យើងទៅកាន់សហគមន៍ យើងអាចស្វែងរកការគាំទ្រ ការរួមចំណែក និងការយល់ដឹងពីអ្វីដែលយើងចង់សម្រេចបាន។

## ឯកសារចែក ៥.១.១៖ ការរៀបចំទុកជាមុនដើម្បីសម្ភាសន៍

ជាការល្អក្នុងការធ្វើតាមក្បួនបទប្បញ្ញត្តិមួយចំនួននៅពេលសម្ភាសន៍៖

- អានសំណួរមុនពេលសម្ភាស ត្រូវត្រៀមខ្លួន។
- ចេះគួរសម និងអរគុណអ្នកទទួលការសម្ភាសសម្រាប់ពេលវេលាដែលគាត់ផ្ដល់ឱ្យប្អូន។
- សំណួររបស់ប្អូនត្រូវច្បាស់លាស់ (ប្រើពាក្យសាមញ្ញៗ បង្កើតសំណួរខ្លីៗ)។
- សួរសំណួរម្ដងទៀត ប្រសិនបើគេមិនយល់។
- ផ្ដល់ពេលវេលាឱ្យគេឆ្លើយ។
- ស្ដាប់ដោយយកចិត្តទុកដាក់។
- កុំណែនាំប្រាប់ចម្លើយ។

ជំនាញសំខាន់បំផុតមួយដែលប្អូនត្រូវអភិវឌ្ឍ ប្រសិនបើចង់ធ្វើបទសម្ភាសឱ្យល្អនោះ គឺត្រូវស្ដាប់ឱ្យបានល្អ!

| | |
|---|---|
| **នរណាជាអ្នកផ្ដល់ការសម្ភាស** | កុមារ ឬ អាណាព្យាបាល ឬអជ្ញាធរមូលដ្ឋាន។ |
| **កម្រងសំណួរ** | រៀបចំរួចរាល់ និងបានអនុវត្តសួរសំណួរជាមួយដៃគូ ឬក្រុម។ |
| **ការជូនដំណឹងពីការសម្ភាស** | ផ្ដល់ជូននូវលិខិតជូនដំណឹង ឬទំនាក់ទំនងតាមទូរសព្ទ។ល។ |
| **កាលបរិច្ឆេទកំណត់នៃការសម្ភាស** | កាលបរិច្ឆេទជាក់លាក់ ដើម្បីធ្វើការសម្ភាស។ |

## ឯកសារចែក ៥.១.២ក៖ ការវិភាគព័ត៌មានតាមរយៈករណីសិក្សាដើម្បីរកដំណោះស្រាយ

### ករណីសិក្សាទី១

**ស្រីនិត** មានអាយុ១៤ឆ្នាំកំពុងរៀនថ្នាក់ទី៩។ ផ្ទះរបស់នាងមានចម្ងាយ២.៥គីឡូម៉ែត្រពីសាលា។ នាងមានបងប្អូន៤នាក់ ហើយនាងរស់នៅជាមួយជីដូន។ ឪពុកម្តាយរបស់នាងជំពាក់ប្រាក់ធនាគារ។ ស្រីនិត ជាសិស្សឧស្សាហ៍ព្យាយាម និងរៀនពូកែ។ នាងជាប់ចំណាត់ថ្នាក់លេខ២នៅឆ្នាំនេះ។ នៅផ្ទះ នាងតែងតែជួយធ្វើម្ហូប ធ្វើកិច្ចការផ្ទះ និងមើលថែបងប្អូនបង្កើត។ លោកយាយរបស់នាងកាន់តែចាស់ទៅហើយ មិនអាចចិញ្ចឹមស្រីនិតឱ្យរៀននៅឆ្នាំក្រោយទៀតបានទេ។ នាងអាចនឹងឈប់រៀន ប៉ុន្តែស្រីនិតស្រឡាញ់ការសិក្សាណាស់។

### ករណីសិក្សាទី២

**សុខា** គឺជាក្មេងប្រុសម្នាក់កំពុងរស់នៅជាមួយជីដូនជីតាតាំងពីឪពុកម្តាយរបស់គាត់បានផ្លាស់ទៅធ្វើការនៅប្រទេសថៃ។ គាត់មានការលំបាកនៅសាលា ដោយសារគាត់ខ្មាស់អៀន ហើយក្មេងប្រុសមួយចំនួនដែលធំជាងសុខាបានធ្វើបាបគាត់ និងចំអកឡកឡើយដាក់គាត់។ រាល់ព្រឹក មុនពេលទៅសាលារៀន គាត់មានអារម្មណ៍មិនស្រួលខ្លួន និងព្រួយបារម្ភពេលជួបក្មេងៗទាំងនោះ។ គាត់មិនបានប្រាប់ជីដូនជីតាគាត់ទេ ព្រោះសុខាមិនចង់រំខានពួកគាត់។ សុខាកំពុងពិចារណាថា តើគួរបន្តការសិកក្សាឬចាប់ផ្តើមរកការងារធ្វើដើម្បីបញ្ចៀសបញ្ហាដែលកើតមាននៅសាលារៀន។

### ករណីសិក្សាទី៣

**ណារិន** អាយុ១៥ឆ្នាំ រៀនថ្នាក់ទី៩ កំពុងរស់នៅជាមួយម្តាយមីង ដោយសារឪពុកម្តាយមិនអាចចិញ្ចឹមកូនបានច្រើន។ ឪពុកម្តាយរបស់នាងគឺជាកសិករ។ ណារិន បានពោលថា ខ្ញុំស្រឡាញ់ការសិក្សា ហើយខ្ញុំចង់ក្លាយជាគ្រូបង្រៀននាពេលអនាគត។ ខ្ញុំឃើញឪពុកម្តាយខ្ញុំធ្វើការយ៉ាងលំបាកនិងមានប្រាក់ចំណូលតិចតួច ហើយពេលខ្លះយើងអត់មានបាយហូបផង។ ខ្ញុំជឿថា ការសិក្សាថ្នាក់ខ្ពស់របស់ខ្ញុំអាចជួយខ្ញុំឱ្យរួចផុតពីភាពក្រីក្រ។

### ករណីសិក្សាទី៤

**ភក្តី** ជាក្មេងប្រុសអាយុ១៦ឆ្នាំបានឈប់រៀនអស់រយៈពេល២ខែហើយ។ គាត់មកពីគ្រួសារមានកូន៧នាក់ ហើយឪពុកម្តាយធ្វើស្រែចម្ការ។ ទោះខំប្រឹងធ្វើការក៏ពិបាកដែរ ព្រោះរកប្រាក់កម្រៃមិនបានគ្រប់គ្រាន់ដើម្បីចិញ្ចឹមគ្រួសារទាំងមូល។ ភក្តី បានសម្រេចចិត្តចាប់ផ្តើមធ្វើការជាជាងជួសជុលម៉ូតូជាមួយពូរបស់គាត់។ គាត់ជួយឪពុកម្តាយនិងបងប្អូនរបស់គាត់ ប៉ុន្តែគាត់សោកស្តាយដែលមិនបានទៅសាលារៀនបន្តទៀត ហើយបើអាចគាត់ចង់ចូលរៀនវិញ។

### ករណីសិក្សាទី៥

**សារ៉ាឌី** កំពុងសិក្សានៅថ្នាក់ទី៨ ហើយគាត់ជាសិស្សពូកែ។ គាត់ដឹងថា កាសិក្សាគឺជាឱកាសសម្រាប់គាត់ក្នុងការធ្វើឱ្យប្រសើរឡើងនូវជីវភាពរស់នៅ និងគ្រួសាររបស់គាត់។ ម្តាយរបស់គាត់ពិការដោយសារគ្រោះថ្នាក់ចរាចរណ៍។ ឪពុករបស់គាត់ធ្វើការជាកម្មកររោងចក្រ ហើយជាអ្នករកប្រាក់ចំណូលតែម្នាក់គត់សម្រាប់សមាជិកក្នុងគ្រួសារ៥នាក់។ ជីវិតរបស់សារ៉ាឌីលំបាក ព្រោះក្រោយពីរៀនគាត់ត្រូវធ្វើការបន្ថែមដើម្បីបានចំណូលជួយគ្រួសារ។ សារ៉ាឌី ខ្លាចមិនអាចបន្តការសិក្សាបាន គាត់ត្រូវធ្វើការក្រៅម៉ោងដើម្បីរកប្រាក់ខ្លះសម្រាប់ផ្គត់ផ្គង់ការសិក្សារបស់គាត់ ព្រោះឪពុកម្តាយគាត់កមិនសូវគាំទ្រការសិក្សារបស់គាត់ទេ ដោយសារជីវភាពខ្វះខាត។

## ឯកសារចែក ៥.១.២ខ៖ ការវិភាគព័ត៌មានតាមរយៈករណីសិក្សាដើម្បីរកដំណោះស្រាយ






## ឯកសារចែក ៥.១.៣៖ការបង្កើតផែនការផ្សព្វផ្សាយដើម្បីបង្ហាញដំណោះស្រាយ

- **យើងផ្សព្វផ្សាយអ្វី?** យើងចង់បង្ហាញលទ្ធផលនៃគម្រោងដែលយើងបានបង្កើត៖ មូលហេតុចម្បង និងដំណោះស្រាយដែលកំណត់បាន។
- **តើយើងអាចផ្សព្វផ្សាយបាននៅពេលណា?** យើងអាចផ្សព្វផ្សាយព័ត៌មានអំពីគម្រោងរបស់យើងក្នុងអំឡុងពេលមានព្រឹត្តិការណ៍សាលាសំខាន់ៗមួយចំនួនដូចជា ទិវាកុមារអន្តរជាតិ ពិព័រណ៍សាលារៀន ថ្ងៃបើកបវេសនកាល។ យើងអាចរៀបចំសកម្មភាពរំអែងាសប្រាក់នៅពេលយើងត្រូវការប្រាក់ដើម្បីធ្វើសកម្មភាពជាក់លាក់មួយចំនួន និងបង្កើនការយល់ដឹងអំពីកម្មវិធីរបស់យើង។
- **តើយើងគួររៀបចំសកម្មភាពផ្សព្វផ្សាយនៅឯណា?** ធ្វើសកម្មភាពនេះនៅឯណា? នៅសាលារៀន សួនសាធារណៈ វត្តអារាម ក្នុងភូមិ។ល។
- **តើយើងគួររៀបចំដោយរបៀបណា?** ការបង្កើតប៉ុស្ទ័រ ខិត្តប័ណ្ណ វីដេអូពន្យល់អំពីគម្រោង និងបង្ហាញវា។
- **តើយើងគួរអញ្ជើញអ្នកណាខ្លះ?** តើអ្នកណាជាក្រុមគោលដៅ? សិស្សានុសិស្សផ្សេងទៀត ក្រុមដែលរងផលប៉ះពាល់ មាតាបិតា សមាជិកសហគមន៍ អាជ្ញាធរមូលដ្ឋាន និងអ្នកនយោបាយ ដើម្បីឱ្យពួកគេផ្តោតលើបញ្ហា និងមានទំនាក់ទំនងល្អជាមួយបុគ្គលដែលគេគោរពក្នុងសហគមន៍ ដើម្បីទទួលបានការគាំទ្រពីពួកគេ។ល។

### យុទ្ធនាការផ្សព្វផ្សាយ



យុទ្ធនាការផ្សព្វផ្សាយ គឺជាសកម្មភាពមួយដែលសិស្សគ្រោងធ្វើបទបង្ហាញដល់អ្នកដទៃទៀត ជាពិសេសសមាជិកសហគមន៍ឬមិត្តភក្តិ។ សកម្មភាពនេះទាមទារធនធាន ការរៀបចំផែនការ និងការត្រៀមយ៉ាងម៉ត់ចត់។ សកម្មភាពនេះអាចត្រូវបានអនុវត្តម្តង ឬពីរដងក្នុងមួយឆ្នាំ។ វាជួយទាក់ទាញចំណាប់អារម្មណ៍ប្រជាពលរដ្ឋដែលជាគោលដៅនៅក្នុងសហគមន៍ ក៏ដូចជាប្រជាពលរដ្ឋទូទៅ អាជ្ញាធរមូលដ្ឋាន អ្នកនយោបាយ និងពាណិជ្ជករ ជាដើម។



### ការអប់រំមិត្តភក្តិគ្នាឯងសម្រាប់ធ្វើការផ្សព្វផ្សាយ

ការអប់រំមិត្តភក្តិគ្នាឯង គឺជាទម្រង់នៃសកម្មភាពផ្សព្វផ្សាយរវាងមិត្តភក្តិមួយ និងមិត្តភក្តិម្នាក់ទៀត រវាងមិត្តភក្តិម្នាក់ និងក្រុមតូច ឬរវាងក្រុមតូច និងក្រុមធំ។ល។

### ពិព័រណ៍សាលារៀន



ពិព័រណ៍សាលារៀនគឺជាឱកាសដ៏ល្អសម្រាប់សិស្សានុសិស្សក្នុងការធ្វើបទបង្ហាញអំពីគម្រោងរបស់ពួកគេទៅកាន់សហគមន៍ ឪពុកម្តាយ ក៏ដូចជាអាជ្ញាធរមូលដ្ឋានផងដែរ។ ជាការពិត សិស្សមានឱកាសបង្ហាញគំនិត និងគម្រោងរបស់ពួកគេ និងរៀបចំសកម្មភាពសម្រាប់ការរំអែងាសប្រាក់ និងការស្វែងរកការគាំទ្រផងដែរ។

បន្ទាប់មក គ្រូសួរសំណួរឆ្លុះបញ្ចាំងខាងក្រោម៖
- តើប្អូនអាចយល់បានទេថាតើគម្រោងរបស់ពួកគេធ្វើអ្វី?
- តើប្អូនៗបានត្រៀមរៀបចំអ្វីខ្លះ?
- តើប្អូនៗមានទំនុកចិត្តក្នុងដំណើរការគម្រោងតូចមួយតាមរយៈវិធីសាស្ត្រ៦ដំណាក់កាលដែរឬទេ?
- តើប្អូនចង់ឱ្យសាលារៀនរបស់អនុវត្តសកម្មភាពនេះទៀតដែរឬទេ? ហេតុអ្វី?

## សេចក្តីសន្និដ្ឋានចុងក្រោយ

- សិស្សទាំងអស់អាចក្លាយជាពលរដ្ឋសកម្ម។
- ប្អូនអាចជួយសហគមន៍ ដោយចាប់ផ្តើមពីការកំណត់អត្តសញ្ញាណបញ្ហា ឬតម្រូវការរបស់សហគមន៍។
- នៅពេលដែលយើងយល់ពីបញ្ហានោះ យើងអាចស្វែងរកដំណោះស្រាយដែលអាចធ្វើបាន ដោយប្រើប្រាស់ដំណើរការ៦ជំហានដើម្បីបង្កើតគម្រោងរបស់យើង។
- តាមរយៈការផ្សព្វផ្សាយសកម្មភាពរបស់យើងទៅកាន់សហគមន៍ យើងអាចស្វែងរកការគាំទ្រ ការរួមចំណែក និងការយល់ដឹងពីអ្វីដែលយើងចង់សម្រេចបាន។

# ជំពូកទី៦

# ការបញ្ចប់មេរៀនអក្ខរកម្មហិរញ្ញវត្ថុ

## មេរៀនទី១ ការបញ្ចប់ដំណើរការមេរៀនស្ដីពីអក្ខរកម្មហិរញ្ញវត្ថុ

| | |
|---|---|
| | **រយៈពេល៖** ៤៥នាទី |
| | **ការត្រៀមខ្លួនរបស់គ្រូ មុនចូលបង្រៀន**<br>- អានមេរៀនទាំងមូល<br>- ថតចម្លងសន្លឹកកិច្ចការ ១.២.១៖ តេស្តមុន ឬក្រោយវគ្គ។ |
| | **សម្ភារៈ ធនធានដែលចាំបាច់**<br>- សន្លឹកកិច្ចការ ១.២.១៖ តេស្តមុន ឬក្រោយវគ្គ<br>- ក្រដាស និងប៊ិក។ |
| | **លទ្ធផលសិក្សា៖**<br>បន្ទាប់ពីបញ្ចប់មេរៀននេះ សិស្សនឹងអាច៖<br>- រាយការណ៍អំពីគំនិត និងអារម្មណ៍របស់ពួកគេ នៅចុងឆ្នាំ តាមរយៈដំណើរការឆ្លុះបញ្ចាំង។<br>- រាយការណ៍ពីរបៀបដែលចំណេះដឹង និងអាកប្បកិរិយារបស់ពួកគេស្ដីពីអក្ខរកម្មហិរញ្ញវត្ថុមានភាពប្រសើរឡើង។ |

### សេចក្ដីផ្ដើម៖

គ្រូចាប់ផ្ដើមមេរៀនដោយនិយាយថា ថ្ងៃនេះជាថ្ងៃចុងក្រោយនៃដំណើរក្នុងមេរៀនស្ដីពីអក្ខរកម្មហិរញ្ញវត្ថុ! គ្រូគួរតែរំឭកថាពួកគេបានរៀនសូត្រប្រធានបទផ្សេងៗ ហើយឥឡូវនេះជាពេលវេលាសម្រាប់វាយតម្លៃនូវអ្វីដែលសិស្សចងចាំតាមរយៈការធ្វើតេស្តក្រោយវគ្គ។

### សកម្មភាពសំខាន់ទី១៖តេស្តក្រោយវគ្គ (២០នាទី)

គ្រូចែកសន្លឹកកិច្ចការ ១.២.១៖ តេស្តក្រោយវគ្គ និងប្រាប់ឱ្យសិស្សធ្វើ ដើម្បីបញ្ចប់មេរៀនស្ដីពី អក្ខរកម្មហិរញ្ញវត្ថុ។ ការវាយតម្លៃនេះមានគោលបំណងផ្ដល់ការយល់ដឹងកាន់តែប្រសើរអំពីចំណេះដឹងបច្ចុប្បន្នរបស់សិស្សទាក់ទងនឹងអក្ខរកម្មហិរញ្ញវត្ថុ។ មុនពេលចាប់ផ្ដើមធ្វើ គ្រូប្រាប់ឱ្យសិស្សយករបស់របរផ្ទាល់ខ្លួនទាំងអស់ចេញពីតុ ហើយដាក់វានៅក្រោមតុរបស់ពួកគេ ឬនៅផ្នែកខាងក្រោយថ្នាក់រៀន។

នៅពេលតេស្តចាប់ផ្ដើម សិស្សនឹងមិនត្រូវបានអនុញ្ញាតឱ្យជជែកជាមួយសិស្សផ្សេងទៀតឡើយ។ ប្រសិនបើពួកគេមានសំណួរទាក់ទងនឹងតេស្ត ត្រូវលើកដៃដើម្បីសួរគ្រូ។ ពួកគេមិនអាចសួរមិត្តភក្ដិបានទេ។ សិស្សមានពេល១៥នាទីដើម្បីបញ្ចប់តេស្ត។ គ្រូសរសេរនៅលើក្ដារខៀន នៅពេលសល់ពេលវេលា៥នាទី។ ប្រសិនបើសិស្សធ្វើចប់មុនម៉ោងពួកគេអាចប្រគល់តេស្ត ហើយទៅរង់ចាំនៅខាងក្រៅថ្នាក់។ ឥឡូវនេះ សិស្សអាចចាប់ផ្ដើមធ្វើតេស្ត។

## សកម្មភាពសំខាន់ទី២៖ អក្ខរកម្មហិរញ្ញវត្ថុ និងខ្ញុំ (២០នាទី)

គ្រូសួរសំណួរខាងក្រោមដល់សិស្ស ដើម្បីជំរុញឱ្យពួកគេឆ្លុះបញ្ចាំងពីកម្មវិធីសិក្សាអក្ខរកម្មហិរញ្ញវត្ថុ។

បន្ទាប់ពីបញ្ចប់មេរៀនទាំងអស់ តើប្អូនមានអារម្មណ៍យ៉ាងណាចំពោះជំនាញផ្នែកអក្ខរកម្មហិរញ្ញវត្ថុ? តើប្អូនមានអារម្មណ៍ជឿជាក់ដែរឬទេក្នុងការគ្រប់គ្រងប្រាក់របស់ខ្លួនឯង ឬទៅធនាគារ? តើប្អូនគិតថាប្អូនអាចធ្វើការសម្រេចចិត្តល្អប្រសើរជាងមុនដែរឬទេ នៅពេលទិញអ្វីមួយដោយការបែងចែករវាងការចង់បាន និងតម្រូវការរបស់ខ្លួន? តើប្អូនចង់តបស្នងសងគុណដល់សហគមន៍ដែរឬទេ?

គ្រូនិយាយទៅកាន់សិស្សថា ពួកគេអាចសរសេរ ឬគូរពីអារម្មណ៍ និងការរៀនសូត្ររបស់ខ្លួននៅក្នុងថ្នាក់នេះនៅលើក្រដាសទទេមួយ។ ប៉ុន្មាននាទីក្រោយមក គ្រូសួរថា តើប្អូននៅចាំសំបុត្រ ដែលពួកគេបានសរសេរមកឱ្យខ្លួនឯងក្នុងមេរៀនទីមួយដែរឬទេ? គ្រូប្រាប់សិស្សឱ្យអានសំបុត្រឡើងវិញ ដើម្បីមើលការវិវត្ត ឬភាពប្រសើរឡើងដែលបានឆ្លងកាត់ ឬអ្វីដែលជាការរំពឹងទុករបស់ពួកគេ ហើយប្រៀបធៀបទៅនឹងអារម្មណ៍នាពេលបច្ចុប្បន្ននេះ។

គ្រូប្រាប់ឱ្យសិស្សមួយចំនួនចែករំលែកជាមួយសិស្សទាំងអស់ពីអារម្មណ៍ និងការរៀនសូត្ររបស់ខ្លួន។

ដើម្បីធ្វើសេចក្តីសន្និដ្ឋានបញ្ចប់កម្មវិធីសិក្សា គ្រូរៀបចំការប្រគល់វិញ្ញាបនបត្រ។ គ្រូពន្យល់ថា វិញ្ញាបនបត្រនេះបញ្ជាក់ថា សិស្សមានចំណេះដឹងមូលដ្ឋានផ្នែកអក្ខរកម្មហិរញ្ញវត្ថុ។ គ្រូសរសើរសិស្ស និងអាចនិយាយថាសិស្សអាចមានមោទនភាពលើខ្លួនឯង! គ្រូពន្យល់ទៀតថា សិស្សអាចបន្តរៀនសូត្រជារៀងរាល់ថ្ងៃ និងចែករំលែកជាមួយមិត្តភក្តិ ក្រុមគ្រួសារ ឬសាច់ញាតិនូវអ្វីដែលពួកគេបានរកឃើញ និងជួយអ្នកដទៃក្នុងការគ្រប់គ្រងប្រាក់។


ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ការិយាល័យអប់រំ យុវជន និងកីឡាស្រុក
ឈ្មោះសាលារៀន ..............................
លេខ ..................

**វិញ្ញាបនបត្របញ្ជាក់ការសិក្សា**

ការិយាល័យអប់រំ យុវជន និងកីឡា ស្រុក ......................................

សូមបញ្ជាក់ថា

**ឈ្មោះ**.............................................. **ថ្នាក់ទី**..............

បានចូលរួម និងបញ្ចប់ដោយជោគជ័យនូវកម្មវិធីសិក្សាអក្ខរកម្មហិរញ្ញវត្ថុសម្រាប់កម្រិតមធ្យមសិក្សា។

........................... ថ្ងៃទី...... ខែ...... ឆ្នាំ២០២...

**នាយកសាលា**

# ទម្រង់វាយតម្លៃឥរិយាបថសិស្ស

ឈ្មោះ៖ ______________________ ថ្នាក់ទី៖ ______________

សាលារៀន៖ ______________________ ស្រុក៖ ______________

| ធាតុដែលត្រូវដាក់ពិន្ទុ | | ពិន្ទុ (១-៥) | មតិយោបល់ |
|---|---|---|---|
| ១ | **ការប្រាស្រ័យទាក់ទង និងសហការ៖** ការពិភាក្សា និងសហការយ៉ាងសកម្មជាមួយសមាជិកទាំងអស់ក្នុងក្រុម។ សិស្សអាចស្ដាប់ និងប្រតិកម្មលើពាក្យរបស់ពួកគេ។ | | |
| ២ | **ការវិភាគ និងដោះស្រាយបញ្ហា៖** ផ្ដល់ចម្លើយដោយមានហេតុផល និងអំណះអំណាងច្បាស់លាស់ ហើយអាចកំណត់ដំណោះស្រាយចំពោះបញ្ហាសាមញ្ញៗដែលបានជួបប្រទះ។ | | |
| ៣ | **ការសម្រេចចិត្តដោយខ្លួនឯង៖** មានភាពរហ័សរហួនក្នុងការសម្រេចចិត្តលក្ខណៈបុគ្គល ហើយដឹងយ៉ាងច្បាស់អំពីអ្វីដែលនាង ឬគាត់កំពុងនិយាយ។ | | |
| ៤ | **ទំនុកចិត្ត៖** ក្នុងអំឡុងពេលធ្វើបទបង្ហាញ ឬការពិភាក្សា សិស្សមានទំនុកចិត្តក្នុងការនិយាយ និងចូលរួម។ | | |
| ៥ | **ការលើកទឹកចិត្ត និងការយល់ដឹង៖** សិស្សបង្ហាញពីការលើកទឹកចិត្តក្នុងការចូលរួមក្នុងប្រធានបទ។ គាត់ឬនាងបង្ហាញការយល់ដឹងយ៉ាងច្បាស់អំពីប្រធានបទនៅក្នុងមេរៀន និងអំឡុងពេលអនុវត្ត។ | | |
| ៦ | **ចរិតលក្ខណៈ៖** សិស្សមានភាពអត់ធ្មត់ និងមានអាកប្បកិរិយាវិជ្ជមានក្នុងថ្នាក់។ | | |
| ៧ | **ភាពច្នៃប្រឌិត៖** សិស្សបង្ហាញពីភាពច្នៃប្រឌិតក្នុងការធ្វើបទបង្ហាញ ផលិតផល និងអំឡុងពេលមេរៀន។ គាត់ឬនាងបង្កើតជាគំនិតជាច្រើន។ | | |
| ពិន្ទុសរុបលើការសង្កេតអាកប្បកិរិយារបស់សិស្ស។ មាន ៣៥ ពិន្ទុដែលត្រូវផ្ដល់ឱ្យ។(០-១៧: មិនល្អ / ១៨-២៣: មធ្យម / ២៤-៣៥: ល្អ) | | | |

# តារាងពិន្ទុវាយតម្លៃឥរិយាបថសិស្ស

សាលារៀន៖______________________ ថ្នាក់៖__________

| ល.រ. | ឈ្មោះសិស្ស | ភេទ | តេស្តសរសេរ | | ពិន្ទុវាយតម្លៃឥរិយាបថសិស្ស | ពិន្ទុសរុប |
|---|---|---|---|---|---|---|
| | | | ពិន្ទុតេស្តមុនវគ្គ | ពិន្ទុតេស្តក្រោយវគ្គ | | |
| ១ | | | | | | |
| ២ | | | | | | |
| ៣ | | | | | | |
| ៤ | | | | | | |
| ៥ | | | | | | |
| ៦ | | | | | | |
| ៧ | | | | | | |
| ៨ | | | | | | |
| ៩ | | | | | | |
| ១០ | | | | | | |
| ១១ | | | | | | |
| ១២ | | | | | | |
| ១៣ | | | | | | |
| ១៤ | | | | | | |
| ១៥ | | | | | | |
| ១៦ | | | | | | |
| ១៧ | | | | | | |
| ១៨ | | | | | | |
| ១៩ | | | | | | |
| ២០ | | | | | | |
| ២១ | | | | | | |
| ២២ | | | | | | |
| ២៣ | | | | | | |

រៀបចំដោយ៖ ____________________

កាលបរិច្ឆេទ៖ ____________________

# ការសង្កេតថ្នាក់រៀន - ស្វ័យវាយតម្លៃគ្រូបង្រៀន

| សាលារៀន | គ្រូបង្រៀន | អ្នកសង្កេត |
|---|---|---|
| | | |

| កាលបរិច្ឆេទ | មេរៀនចាប់ផ្តើម | មេរៀនបញ្ចប់ | ថ្នាក់ទី | ចំនួនសិស្សចុះឈ្មោះ/វត្តមាន |
|---|---|---|---|---|
| | | | | |

| តើមេរៀននិយាយអំពីអ្វី? |
|---|
| |

| លក្ខណៈវិនិច្ឆ័យ - ការត្រៀមខ្លួន - តើថ្នាក់រៀន | ពិន្ទុ | កំណត់ចំណាំពីភស្តុតាង |
|---|---|---|
| មានសម្ភារៈត្រៀមរួចសម្រាប់ប្រើក្នុងមេរៀននេះដែរឬទេ? | ១-២-៣-៤-៥ | |
| បង្ហាញដល់សិស្សនូវសម្ភារៈដែលបានបង្កើតពីមេរៀនមុនៗ? | ១-២-៣-៤-៥ | |
| **លក្ខណៈវិនិច្ឆ័យ - ការសិក្សា - តើសិស្ស...** | **ពិន្ទុ** | **កំណត់ចំណាំពីភស្តុតាង** |
| មើលទៅចាប់អារម្មណ៍ និងចូលរួមសកម្មក្នុងការងាររបស់ពួកគេដែរឬទេ? | ១-២-៣-៤-៥ | |
| ធ្វើការជាមួយក្រុមចម្រុះដែលមានក្មេងប្រុស និងក្មេងស្រីក្នុងអំឡុងពេលផ្នែកមួយនៃមេរៀនដែលមានតួនាទីក្នុងក្រុមច្បាស់លាស់? | ១-២-៣-៤-៥ | |
| បង្ហាញចំណេះដឹង ឬជំនាញពីមេរៀនមុនៗ? | ១-២-៣-៤-៥ | |

| លក្ខណៈវិនិច្ឆ័យ - ការបង្រៀន - តើគ្រូ | ពិន្ទុ | កំណត់ចំណាំពីភស្តុតាង | |
|---|---|---|---|
| អនុវត្តតាមផែនការជាគោលការណ៍ណែនាំដែរឬទេ? | ១-២-៣-៤-៥ | | |
| ប្រើប្រាស់ធនធានសហគមន៍ក្នុងមេរៀនឬវដ្តមេរៀន? | ១-២-៣-៤-៥ | | |
| ប្រើយុទ្ធសាស្រ្តបង្រៀនបែបអន្តរកម្ម? ឧ. ផែនទីគំនិត ករណីសិក្សា ដើរតួសម្តែង ល្បែងសិក្សា។ | ១-២-៣-៤-៥ | | |
| ប្រើសំណួរប្រភេទផ្សេងៗ? | ១-២-៣-៤-៥ | | |
| ប្រើធនធានដែលបង្កើតដោយខ្លួនឯង ឬធនធានបន្ថែមដើម្បីពន្យល់មេរៀន? | ១-២-៣-៤-៥ | | |
| ចាប់ផ្តើមទាន់ពេល និងប្រើប្រាស់ពេលវេលាប្រកបដោយប្រសិទ្ធភាព? | ១-២-៣-៤-៥ | | |

| | | | |
|---|---|---|---|
| បញ្ចេញយោបល់វិជ្ជមាន ដើម្បីជំរុញការសិក្សា និងទំនុកចិត្តរបស់សិស្ស? | ១-២-៣-៤-៥ | | |
| ជួយសិស្សម្នាក់ៗដែលមានការលំបាក? | ១-២-៣-៤-៥ | | |
| ដាក់បញ្ចូលវឌ្ឍនភាពនៃអាកប្បកិរិយាទៅក្នុងសន្លឹកវាយតម្លៃការសិក្សា? | ១-២-៣-៤-៥ | | |
| តាមដានត្រួតពិនិត្យឥរិយាបថក្នុងថ្នាក់រៀនរបស់ខ្លួន ភាសា កម្រិតសំឡេង និងការយល់ឃើញទូទៅដែលរើសអើងភេទ | ១-២-៣-៤-៥ | | |
| គ្រូធានាឱ្យមានការចូលរួមស្មើៗគ្នារបស់សិស្សប្រុស និងសិស្សស្រីនៅគ្រប់ដំណាក់កាលនៃសកម្មភាព។ | ១-២-៣-៤-៥ | | |

**គ្រូកំណត់ចំណុចល្អនៃមេរៀន** និងផ្ដល់យោបល់សម្រាប់ការផ្លាស់ប្ដូរ ឬកែលម្អ។ សូមផ្ដល់យោបល់អំពីគំនិតសម្រាប់អភិវឌ្ឍន៍។

| ចំណុចខ្លាំង | ចំណុចកែលម្អ |
|---|---|
| | |

